

# ទស្សនវិជ្ជាអត្ថាធិប្បាយ



# រំលឹកអត្ថាធិប្បាយ

តាមលក្ខណៈទូទៅ អត្ថាធិប្បាយត្រូវមានបែបផែនដូចតទៅនេះ ៖

- ផ្តើមសេចក្តី គឺជាចំណោទបញ្ហា ដោយយកប្រធានមកចោទបន្ទាប់ពីលំនាំសេចក្តី និង ចំណែកសេចក្តី ( មិនត្រូវដោះស្រាយ និងពន្យល់ទេ )
- តួសេចក្តី គឺជាសំរាយបញ្ហា ប៉ុន្តែត្រូវចេះស្រាយតាមគោលគំនិត នីមួយៗ ឲ្យបាន ច្បាស់លាស់ ដោយមានអំណាង ត្រឹមត្រូវពោលគឺមិនត្រូវសេរសេរតាមចិត្តនឹកឃើញទេ..... សរសេរយ៉ាងនេះ អាងអី ? សរសេរយ៉ាងនោះ អាងអី ? ត្រូវបញ្ជាក់អំណាងឲ្យបានច្បាស់លាស់ គឺមាននៅក្នុងសៀវភៅណា ? អ្នកនិពន្ធណា ? ទស្សវិទូណា ? ខែណា ? ឆ្នាំណា ? សតវត្សណា ?

ជួនកាល ប្រធានតម្រូវឲ្យពន្យល់ ? ប្រៀបធៀប ? ពិភាក្សា ? អត្ថាធិប្បាយរែកញែក ?

បើគេឲ្យរែកញែក ត្រូវចេះទាញគុណកថា មកបង្ហាញដោយបញ្ជាក់ប្រភពគុណកថានោះ និងអ្នកនិពន្ធ ហើយត្រូវជៀសវាងជាដាច់ខាតនូវអំណាងផ្ទាល់ខ្លួន និងចៀសវាងការប្រើប្រាសពាក្យ « ខ្ញុំ » ។

បញ្ចប់សេចក្តី ជាចំលើយបញ្ចប់បញ្ហាដែល បានដោះស្រាយរួច កមហើយដើម្បីកុំឲ្យអ្នកកែនៅឆ្ងល់តទៅទៀត ព្រមទាំងចេះទាញយកឧត្តមគតិណាមួយដែលកើតពីអត្ថធិប្បាយ ប៉ុន្តែត្រូវចៀសវាងពាក្យអួត សរសើរហួសហេតុ ពាក្យបញ្ចោរ ពាក្យជេរ ពាក្យត្រះតឹះដៀលដែលជាពាក្យផ្សារ ។

## ប្រធានទី១៖

*តើសីលធម៌ជាអ្វី ?*

*មនុស្សត្រូវមានសីលធម៌ដូចម្ដេចខ្លះ ?*

***ផ្ដើមសេចក្ដី***

ការរស់នៅរបស់មនុស្សក្នុងសង្គមតំរូវ ឲ្យមនុស្សស្វែងរកគោលការណ៍អ្វីមួយសំរាប់ការអនុវត្ត ឲ្យបានប្រសើរជាមួយមនុស្សផងគ្នាក្នុងសង្គម ខ្លះបង្កើតទំនៀមទំលាប់ ខ្លះបង្កើតជំនឿ ខ្លះស្វែងរកសាសនា ជាបង្អែកក្នុងគោលបំណងរៀបចំការរស់នៅឲ្យបានប្រសើរ មានន័យថាគេស្វែងរកសីលធម៌នេះឯង ។ តើសីលធម៌មានន័យដូចម្ដេច ? មនុស្សត្រូវមានសីលធម៌បែបណាខ្លះ ?

***តួសេចក្ដី***

តាមន័យទូទៅ សីលធម៌សំគាល់នូវទ្រឹស្ដី និងពាក្យទូន្មានទាំងឡាយណាដែលដឹកនាំទៅរកផ្លូវល្អ និង ចៀសវាងផ្លូវអាក្រក់សំរាប់ការរស់នៅ ។ តាមន័យពិសេស សីលធម៌សំគាល់ការអប់រំតាមផ្លូវចិត្តឲ្យបានប្រសើរ ។

ក្នុងការរស់នៅ សីលធម៌មានច្រើនយ៉ាងគឺ សីលធម៌ផ្ទាល់ខ្លួន សីលធម៌ក្នុងគ្រួសារ សីលធម៌ក្នុងវិជ្ជាជីវៈ សីលធម៌ក្នុងសង្គម សីលធម៌ក្នុងពិភពលោក និងសីលធម៌យល់តាមទស្សនៈអ្នកប្រាជ្ញនីមួយ ៗ :

### ១- សីលធម៌ផ្ទាល់ខ្លួន

- ដឹងខុសត្រូវ
- ស្គាល់ល្អ ស្គាល់អាក្រក់
- តាំងខ្លួនជាម្ចាស់ចិត្តបរស់ខ្លួន
- ទទួលខុសត្រូវនឹងអំពើរបស់ខ្លួន
- ក្លាហានក្នុងមផ្លូវត្រូវ

### ២-សីលធម៌ក្នុងគ្រួសារ

- ឪពុកម្ដាយចិញ្ចឹមកូន ដោយពុំនឹកគិតដល់ការសងគុណតមមកវិញព្រោះជាមុខងាររបស់ឪពុកម្ដាយ
- ធ្វើឲ្យមានភាពសុខដុម
- ស្រឡាញ់កូនស្មើគ្នា

- រៀបចំកូនឲ្យបានទៅជាពលរដ្ឋពេញលេញ

### ៣-សីលធម៌ក្នុងវិជ្ជាជីវៈ

- មនសិការការងារ
- រកស៊ីតាមសមត្ថភាព
- រកស៊ីតាមសម្មាជីវៅ
- មិនរំលោភលើអ្នកតូចជាងខ្លួន
- មិនធ្វើការហួសកម្លាំងខ្លួនដែលនាំឲ្យមានជំងឺឥតប្រយោជន៍

### ៤-សីលធម៌ក្នុងសង្គម

- មិនបែកបាក់គ្នា
- មិនមើលងាយមនុស្សផងគ្នា
- ស្រឡាញ់យុត្តិធម៌
- រាប់អានមនុស្សទូទៅ
- ទទួលស្គាល់ទុក្ខវេទនារបស់អ្នកដទៃ
- មិនឈ្លានពានអ្នកដទៃ

### ៥-សីលធម៌ក្នុងពិភពលោក

ការរួមរស់ ដោយសន្តិភាពជាមួយប្រទេសដទៃ ដែល អ.ស.ប បានប្រជុំគ្នានៅក្រុងបានឌុង នាប្រទេសឥណ្ឌូណេស៊ី ។

### ៦-សីលធម៌យល់តាមទស្សនៈអ្នកប្រាជ្ញនីមួយ ៗ

*ក/ សីលធម៌របស់សូក្រាត ទស្សនវិទូក្រិច សតវត្សទី៥* ( ៤៧០-៣៩៩ មុន គ.ស )ឋិតនៅលើការកសាងកុសលដើម្បីឲ្យបានសំរេចសុភមង្គល ប៉ុន្តែមិនត្រូវយល់ថាសុភមង្គលឋិតនៅលើទ្រព្យសម្បត្តិ អំណាចនិងកិត្តិយស ជាដាច់ខាត ។ ការសប្បាយតាមផ្លូវចិត្តប្រសើរជាងការសប្បានឹងទ្រព្យសម្បត្តិ ។ នេះហើយជាគុណធម៌របស់ព្រលឹង ប៉ុន្តែដើម្បីឲ្យមានសីលធម៌ និងគុណធម៌ ជាបឋមមនុស្សត្រូវមានពុទ្ធិ ដើម្បីរៀបចំខ្លួនបានចេះដឹងសិនព្រោះ អវិជ្ជា ឬភាពល្ងិតល្ងង់ពុំអាចឲ្យមនុស្សយល់តម្លៃសីលធម៌បានទេ ព្រមទាំងជាប្រភពនៃអំពើអាក្រក់ទៀតផង ។ សូក្រាត បានអះអាងទៀត មនុស្សធ្វើអំពើអាក្រក់មកពីពុំយល់ថាជាអំពើអាក្រក់ បន្ទាប់មកទៀតសូក្រាតអប់រំមនុស្សឲ្យតាំងជាម្ចាស់ចិត្តរបស់ខ្លួន ដូចជាពាក្យ ទូន្មានមួយរបស់សូក្រាតពោលថា ( Connais-toi toi méme ) មានន័យថាត្រូវស្គាល់ខ្លួន

ឯងសិន ។

ខ/ សីលធម៌របស់ប្លាតុង ដែលជាសិស្សរបស់សូក្រាត សតវត្សទី៥ មុន គ.ស គឺជា សីលធម៌មួយបែបប្លែកពីសូក្រាតត្រង់ ប្លាតុងបញ្ជាក់ថា ដើម្បីឲ្យមនុស្សមានសលីធម៌ គេត្រូវ ដកហូតទ្រព្យសម្បត្តិឯកជនឲ្យអស់ពីបុគ្គលគឺនៅសល់តែមនោ ពេលនោះទើបមនុស្សអាច យល់ពីតម្លៃសីលធម៌ ហើយបើមនុស្សនៅតែមានទ្រព្យ ទ្រព្យនោះនឹងក្លាយទៅជាមាយាបិទ បាំងមនុស្សមិនឲ្យមើលឃើញសីលធម៌ ។ សីលធម៌របស់ប្លាតុង គឺយុត្តិធម៌ ហើយដើម្បីស្វែងរក យុត្តិធម៌ មនុស្សត្រូវប្រកបដោយសមត្ថភាព ៣ប្រការ ៖

- ប្រការទី១ គឺមនុស្សត្រូវប្រកបដោយវិចារណៈដើម្បីស្វែងរកពុទ្ធិ
- ប្រការទី២ គឺមនុស្សមានចិត្តដើម្បីធ្វើចិត្តឲ្យមានសេចក្ដីក្លាហាន
- ប្រការទី៣ គឺមនុស្សត្រូវមានចំណូលចិត្ត ប៉ុន្តែពុំត្រូវចង់បានហួសប្រមាណ ។

គ/ សីលធម៌របស់អារីស្តូត ទស្សនវិទូក្រិចសតវត្សទី ៤ មុន គ.ស ឋិតនៅត្រង់ការ ស្វែងរកសុភមង្គល និងការចេះសប្បាយ ព្រោះបើមនុស្សមិនចេះសប្បាយ មនុស្សនឹងត្រូវ បាត់បង់តម្លៃរបស់ខ្លួនជាមនុស្ស ប៉ុន្តែសុភមង្គលនិងការសប្បាយត្រូវឋិតក្នុងផ្លូវត្រូវ ហើយ មិនត្រូវដូចសត្វទេ ។ សីលធម៌មួយបែបទៀតរបស់អារីស្តូត គឺការអប់រំឲ្យដើរផ្លូវកណ្ដាល ដូចជា ៖

- កុំក្លាហានពេក កុំកំសាកពេក
- កុំចង់បានពេក តែមិនត្រូវមិនរវីរវល់សោះនោះទេ
- កុំគិតប្រយោជន៍ផ្ទាល់ខ្លួន តែក៏មិនត្រូវភ្លេចខ្លួនឯងដែរ

ឃ/ សីលធម៌របស់ពួកខន្តីនិយម

ឋិតនៅត្រង់ û រស់នៅតាមធម្មជាតិ ™ និងតាំងចិត្តអត់ធន់ ហើយដើម្បីអត់ធន់បាន ត្រូវបំបាត់តណ្ហា រៀនផ្ដាច់ចិត្ត និងកុំរវើរវាយទៅលើអ្វីដែលពុំពិត ហើយដើម្បីសំរេចបំណង ទាំងអស់នេះបាន មនុស្សត្រូវមានពុទ្ធិជាគោលព្រោះអវិជ្ជាពុំអាចឲ្យមនុស្សយល់អ្វីបានឡើយ ។

ង/ សីលធម៌របស់អេពីគារ

ទស្សនវិទូក្រិច សតវត្សទី៤ មុន គ.ស ឋិតនៅត្រង់ការអប់រំមនុស្សឲ្យស្វែងរកការ សប្បាយតាមធម្មជាតិ ប៉ុន្តែត្រូវចេះជ្រើសរើសយកការសប្បាយសកម្ម ផ្ទុយនឹងការសប្បាយ ស្ងប់ស្ងាត់ អេពីគារ បានចែកការសប្បាយជា ៣ ផ្នែក :

- ការសប្បាយតាមធម្មជាតិ និងចាំបាច់
- ការសប្បាយតាមធម្មជាតិ និងមិនចាំបាច់

- ការសប្បាយមិនតាមធម្មជាតិ និងមិនចាំបាច់

ច/សីលធម៌របស់ពុទ្ធសាសនា ហិនយានឋិតនៅត្រង់

- ការកសាងកុសល ដូចជាចេះអាណិតអាសូរអ្នកខ្សត់ខ្សោយ ជាងខ្លួន តាមរយៈរឿងព្រះវេសន្តរ

- ភាពពុំ តបតនឹងបាតុភូតទាំងឡាយ ដែលកើតមានឡើងពោលគឺបើគេប្រឆាំងត្រូវថយខ្លួនចេញ និងមិនត្រូវតបតនឹងអ្នកប្រឆាំងទេ ទោះបីគេថាចាញ់ក៏ដោយ

- ពលិកម្មដើម្បីអ្នកដទៃ ដូចជាសុខចិត្តពិបាកខ្លួនឯង ដើម្បីឲ្យអ្នកដទៃបានសប្បាយ

- ការដោះស្រាយបញ្ហាផ្សេង ៗ ដោយសន្តិវិធី ទើបនៅគ្រប់ជាតិរបស់ព្រះពោធិសត្វដូចមានអធិប្បាយក្នុងគម្ពីរជាតក គេតែងសង្កេតឃើញការដោះស្រាយប្រកបដោយសន្តិវិធី ផ្ទុយពីយុទ្ធវិធី ដូចជាតាមរយៈរឿងព្រះវេស្សន្តរ ពេលត្រូវប្រជារាស្ត្របំបរបង់ព្រះអង្គយល់ព្រមតាមការបំបរបង់ ។

ឆ/សីលធម៌របស់ពុទ្ធសាសនាមហាយាន

- ការងារនិយម
- សង្គមនិយម ដោយយកសង្គមមនុស្សជាគោលដៅ
- មេត្តា ករុណា មុទិតា ឧបេក្ខា

ជ/សីលធម៌នៃសាសនាព្រាហ្មណ៍ ដែលចាប់កំណើតតាំងពីសតវត្សទី៩ មុន គ.ស ឋិតត្រង់

- ការគោរពព្រះអទិទេព
- ការគោរពពាក្យសច្ចៈ

ញ/ សីលធម្មនៃសាសនាគ្រីស្ត

- ព្រះអាទិទេពជួយមនុស្សទាំងអស់ ឲ្យមនុស្សប្រាប់ការពិតដល់ព្រះគ្រីស្ត ។

ឈ/ សីលធម្មនៃសាសនាអ៊ីស្លាម ដែលមានចែងក្នុងគម្ពីរកូរ៉ាន

- ផ្លូវគំនិតប្រសើរជាងផ្លូវកាយ
- ឲ្យបរិភោគចំពោះអ្នកណាដែលឃ្លាន
- ហាមមិនឲ្យសំលាប់មនុស្សម្នាក់ជាដាច់ខាត ព្រោះសំលាប់មនុស្សម្នាក់ដូចជាសំលាប់មនុស្សទាំងអស់គ្នា
- ស្រឡាញ់សន្តិភាព
- យកអំពើល្អឆ្លើយតបនឹងអំពើអាក្រក់

- ប៉ុន្តែលក្ខណៈដែលខុសសីលធម៌ត្រង់សាសនាអ៊ីស្លាម បង្ខំគេឲ្យជឿព្រះអាទិទេពរបស់ខ្លួនមួយឈ្មោះអាឡ្លាហ៍ ( Allah ) ហើយចាត់ទុកព្រះអាឡ្លាហ៍ជាព្រះអាទិទេពកំពូល
- អាឡ្លាហ៍ ជាអាទិទេពតែមួយអង្គគត់
- អាឡ្លាហ៍ គ្មាននរណាស្មើ
- អាឡ្លាហ៍ ជាអ្នកបង្កើតអ្វីសព្វយ៉ាង
- អាឡ្លាហ៍ គ្មាននរណាផ្ចាញ់បាន

ពិភាគ្សា :

តាមការអធិប្បាយរួចមកហើយ យើងសង្កេតឃើញថា សីលធម៌ នីមួយ ៗ សុទ្ធសឹងមានតម្លៃរបស់ខ្លួន ហេតុនេះយើងពុំអាចអះអាងថាសីលធម៌ ណាល្អ ឬសីលធម៌ណាអាក្រក់បានឡើយ អាស្រ័យលើការអនុវត្តក្នុងជីវភាពរស់នៅ បើការរស់នៅបានប្រសើរមានន័យថាសីលធម៌នោះប្រសើរ បើការរស់នៅពុំបានប្រសើរទេ គេត្រូវផ្លាស់ប្តូរសីលធម៌នោះ ។

<u>*បញ្ចប់សេចក្តី*</u>

តាមន័យទូទៅ គេពុំសូវជួបប្រទះសីលធម៌អាក្រក់ ទេព្រោះសីលធម៌តែងតែផ្តល់នូវការអប់រំល្អ ។ ទោះបីសីលធម៌ផ្ទាល់ខ្លួនក្តី សីលធម៌ក្នុងគ្រួសារក្តី សីលធម៌ក្នុងវិជ្ជាជីវៈក្តី សីសធម៌ក្នុងសង្គមក្តី និងសីលធម៌ក្នុងពិភពលោក ។ ប្រទេសណា សំបូណ៌ដោយសីលធម៌ គឺជាប្រទេសដែលមានការអប់រំប្រជាពលរដ្ឋក៏ប្រពៃ ព្រោះការចេះដឹងឯកឯងពុំគ្រប់គ្រាន់ទេ គឺត្រូវទទួលការអប់រំផងទៀតទើបគេចាត់ទុកថា ជាប្រទេសមានអរិយធម៌ខ្ពង់ខ្ពស់ ។

## ប្រធានទី២៖

***មនសិការការងារជាអ្វី ?***

***បុគ្គលជំពូកណាដែលគេចាត់ទុកថាមាន មនសិការការងារ ?***

*ផ្ដើមសេចក្ដី :*

ការងារទាំងពួងនឹងអាចសម្រេចប្រយោជន៍បាន អាស្រ័យលើការតស៊ូយ៉ាងមុះមុត ទើបសង្គមមនុស្សតម្រូវឲ្យបុគ្គល ស្គាល់ករណីយកិច្ច គឺករណីយកិច្ចក្នុងការងាររបស់ខ្លួន ដែលខ្លួនត្រូវបំពេញ ទើបគេចាត់ទុកថាបុគ្គលមាន មនសិការការងារ ។ តើមនសិការការងារជាអ្វី ?

*តួសេចក្ដី :*

តាមន័យទូទៅ មនសិការការងារសំគាល់ការភ្ញាក់រលឹកទៅរកការងារដែលខ្លួនបានធ្វើ ឬនឹងត្រូវធ្វើ ហាក់ដូចជាមានកម្លាំងអរូបីអ្វីមួយមកទាក់ទាញចិត្តបុគ្គល ឲ្យធ្វើអំពើ ។ គេអាចកត់សំគាល់

លក្ខណៈនៃ មនសិការការងារ ជាច្រើនប្រការ :

គឺហាក់ដូចជាមានការបង្ខិតបង្ខំពីសង្គម ដែលតម្រូវឲ្យបុគ្គលធ្វើការ ។ បើមិនខំរកស៊ី រស់នៅពុំបានព្រោះគ្មានប្រាក់កាសចិញ្ចឹមជីវិត ទោះបីចង់ក្តី ពុំចង់ក្តី ។ ក្រពះតម្រូវឲ្យបុគ្គលខំរកស៊ីទោះបីការងារនោះពុំឆ្លើយតបនឹង ឧបនិស្ស័យរបស់ខ្លួនក៏ដោយ មានន័យថាយើងពុំអាចជ្រើសរើសតាមចិត្តចង់បានទេ ។ បុគ្គលខ្លះប្រកបកិច្ចការហួសកម្លាំងរហូតដល់លះបង់កិច្ចការគ្រួសារ ស្ទើរទាំងអស់ បានលះបង់កិច្ចទទួលខុសត្រូវក្នុងគ្រួសារ ដោយអចេតនា លះបង់ករណីកិច្ចជាឪពុកម្តាយព្រោះឆ្លៀតអប់រំកូនពុំបាន ដោយវិជ្ជាជីវៈមានបន្ទុកធ្ងន់ពេក និងកិច្ចការមមាញឹក ។

- បុគ្គលខ្លះ យល់ព្រមប្រកបការងារដែលអ្នកដទៃខ្ពើមរអើម ដូចជា យាមសាលខ្មោច សំអាតបង្គន់ ចាក់សំរាម ជញ្ជូនលាមក... ដើម្បីរស់ ។

- បុគ្គលខ្លះទៀត ដោយខ្លាចថៅហ្វាយនាយពេកហ៊ានប្រព្រឹត្តអំពើបាបកម្មតាមបញ្ជា ឬក៏យល់ព្រមនឹងអំពើបាបកម្មដោយចេតនាដើម្បីញ៉ាំងការរស់នៅរបស់ខ្លួនឲ្យបានប្រសើរលើគំនរទុក្ខអ្នកដទៃ ដូចជាពេលច្បាំងឆ្លៀតឱកាសប្លន់កាប់សំលាប់អ្នកដទៃ ដើម្បីទ្រព្យសម្បត្តិ ប្រព្រឹត្តការរួមសង្វាសដោយបង្ខំ ឬដោយកំហែងគំរាមផ្តាច់ជីវិតអ្នកដទៃគ្មានធម៌មេត្តាសម្រាប់សេចក្តីសប្បាយផ្ទាល់ខ្លួន និងទ្រទ្រង់ជីវភាពរបស់ខ្លួនឲ្យបានប្រសើរ ។ មនសិការការងារ ជំពូកនេះពុំប្រកបដោយសីលធម៌ ទើបបញ្ហាចោទសួរឡើងថា *បុគ្គលជំពូកណាដែលអាចចាត់ទុកថាមានមនសិការការងារ ?*

តាមន័យទូទៅ បុគ្គលដែលអាចចាត់ទុកថាមាន មនសិការការងារ លុះត្រាតែប្រកបដោយលក្ខណៈ ៥ ប្រការ :

### ប្រការទី១ : បុគ្គលត្រូវមានសមត្ថភាព

សមត្ថភាពកើតឡើងដោយការសិក្សាអប់រំ ។ ប្រទេសខ្លះបានបង្កើតសញ្ញាប័ត្រច្រើនយ៉ាងសម្រាប់សម្គាល់សមត្ថភាពរបស់បុគ្គលម្នាក់ ៗ ក្នុងការងារ ដូចជាសញ្ញាប័ត្រខាងជំនាងចិញ្ចឹមសត្វ ថែរុក្ខជាតិ រីតទឹកដោះគោ រហូតដល់កិច្ចការទំនើបដែលជា តិចនិចវិទ្យាសាស្ត្រ ពហុបច្ចេកទេស ជាដើម ។ បើខ្វះសមត្ថភាព ទោះបីបុគ្គល មានមនសិការការងារ ក៏លទ្ធផលឥតមានន័យដែរ ។

### ប្រការទី២ : បុគ្គលត្រូវមានពិសោធន៍

ពិសោធន៍ ជាហេតុការណ៍មួយសម្រាប់បញ្ជាក់សមត្ថភាពរបស់បុគ្គល និងធ្វើឲ្យសមត្ថភាពមានរូបីយកម្ម ព្រោះជួនកាលបុគ្គលខ្លះ មានមនសិការការងារតែក្នុងវិស័យទ្រឹស្តី លុះមកដល់អនុវត្តន៍ បែរជាបាត់បង់មនសិការ ។

- ពិសោធន៍ អាចធ្វើឲ្យជួបប្រទះហេតុការណ៍ថ្មី ៗ ទៀតដែលនាំឲ្យបុគ្គលកាន់តែចូលចិត្ត ខ្លាំងឡើង ៗ ដូចជាអ្នកប្រាជ្ញវិទ្យាសាស្ត្រ អាចរកឃើញវិទ្យាសាស្ត្រទំនើបថែមទៀត វិស្វករ វេជ្ជបណ្ឌិតអារកឃើញក្បួនចិត្តសាស្ត្រដែលអាចដឹកនាំឲ្យមនុស្សធ្វើការបានចម្រើន និងសំរួល ការឈឺចាប់មួយភាគធំ គ្រូបង្រៀនលុះជួបប្រទះពិសោធន៍ ច្រើនឆ្នាំក៏អាចរកឃើញគរុកោសល្យ ទំនើបដើម្បីសំរួលវិធីបង្រៀនឲ្យមាន ប្រសិទ្ធិភាពដែលពីមុនមកពុំទាន់រកឃើញនៅឡើយ ។

- ពិសោធន៍ ដឹកនាំឲ្យមានការប្រុងប្រយ័ត្ន និងធ្វើការមិនមានគ្រោះថ្នាក់កាលណាគេ ស្គាល់មុខការនោះច្បាស់លាស់ ដូចជាអ្នកចេះបើកបរឡាននិង អ្នកចេះបរស្មាក់ស្មើរ ។ អ្នកចេះ បើកបរឡានពិតប្រាកដ ពុំសូវនឹងនាដល់ឧបសគ្គសោះ ផ្ទុយពីអ្នកចេះបើកបរស្មាក់ស្មើរហាក់ដូច ជាភ័យនឹងឧបសគ្គច្រើនប្រការពេលឡើងជិះឡានម្តង ៗ ទើបអ្នកមានពិសោធន៍ច្បាស់លាស់ ហាក់

ដូចជាមានអំណួតនឹងមុខការរបស់ខ្លួន ។

## ប្រការទី៣ : បុគ្គលត្រូវមានឧបនិស្ស័យ

បើបុគ្គលមានឧបនិស្ស័យនឹងការងារមួយ គឺជាករណីប្រសើរបំផុត ព្រោះឧបនិស្ស័យជា អំណោយធម្មជាតិដែលអាចដឹកនាំ ឲ្យបុគ្គលស្រឡាញ់ការងារនោះដោយស្មោះស្ម័គ្រ ស្មោះត្រង់ នឹងការងារព្រមទាំងដឹកនាំឲ្យការងារបានផលចម្រើនទៀតផង ។ ក្នុងករណីដែលបុគ្គលមាន ឧបនិស្ស័យចំណូលចិត្តរបស់បុគ្គលអាចមានចំណាប់ចិត្ត ពីសង្គមមនុស្សដូចជាឃើញគេឯងចូល ចូលចិត្ត ក៏ចូលចិត្តតាមគេព្រមទាំងមាន ការណែនាំឲ្យចូលចិត្តស្របនឹងការងារដែលមានចំណាប់ ចិត្ត ។ បើខ្វះខាតឧបនិស្ស័យ បុគ្គលនឹងមាន មនសិការការងារក្លែងក្លាយ ឬធ្វើការងារបណ្តោះ អាសន្ន ទំរាំរកបានការងារណាដែលឆ្លើយតបនិងឧបនិស្ស័យរបស់ខ្លួន ។ ហេតុនេះ ដើម្បីឲ្យ ការងារបានចម្រើន គួររៀបចំឲ្យបុគ្គលធ្វើការងារណាដែលឆ្លើយស្របនឹងឧបនិស្ស័យរបស់ខ្លួន ។

## ប្រការទី៤ : បុគ្គលត្រូវស្រឡាញ់ការងារ

- កាលណាគេស្រឡាញ់ការងារ គេពុំត្រូវធ្វើឲ្យការងារនោះឋិតនៅដដែល ៗ ទេ ពោល គឺប្រឆាំងនឹងភាពដដែល ៗ នេះជាកត្តាធ្វើឲ្យការងារមានថាមភាព និងចម្រើន ។

- កាលណាគេស្រឡាញ់ការងារ គេត្រូវធ្វើការងារដោយទៀងទាត់ពេលវេលា ព្រមទាំង ស្មោះត្រង់ និងការងារ ។

- កាលណាគេស្រឡាញ់ការងារ គេត្រូវខំបង្កើតឲ្យមាន សុឆន្ទៈ ។

- កាលណាគេស្រឡាញ់ការងារ គេធ្វើការងារនោះដោយសប្បាយរីករាយ ព្រមទាំងចេះ បង្កើតឲ្យមានបរិយាកាសរីករាយ ក្នុងការងារនោះទៀតផង ។

- កាលណាគេស្រឡាញ់ការងារ គេត្រូវខំរកមធ្យោបាយថ្មី ៗ ទៀតដើម្បីញ៉ាំងការងារឲ្យបានល្អឥតលាស់ ។

- ប៉ុន្តែកាលណាគេស្រឡាញ់ការងារ គេពុំត្រូវធ្វើការងារនោះរហូតដល់ធ្លាក់ខ្លួនឈឺ បណ្តាលឲ្យខូចពេលវេលា ខាងមុខទៀត ឥតប្រយោជន៍ ព្រមទាំងមិនត្រូវភ្លេចមុខងារគ្រួសារទេ ព្រោះឪពុកម្តាយត្រូវចេះឆ្លៀតពេលវេលាខ្លះអប់រំកូនឲ្យបានល្អដោយដំបូន្មានល្អ ៗ ឆ្លៀតស្និទ្ធស្នាលនឹងកូន ដើម្បីឲ្យកូនមានទំនុកចិត្តលើឪពុកម្តាយ ប៉ុន្តែមិនត្រូវអត់ឱន កំហុស របស់កូនដែលធ្វើឡើងដោយចេតនាទេ ធ្វើយ៉ាងនេះដើម្បីឲ្យកូនស្គាល់អំពើល្អ និងអំពើអាក្រក់ ខុសនិងត្រូវ ជាដើមព្រោះ *នៅសាលារៀន ការអប់រំកូនពុំទាន់ដល់ទេ គឺបានមួយភាគតូចប៉ុណ្ណោះ* ។

### ប្រការទី៥ : បុគ្គលត្រូវមានមនសិការសីលធម៌

មនសិការសីលធម៌ជាអ្វី ?

គឺជាការភ្ញាក់រលឹកទៅរកសីលធម៌ ពោលគឺរកអ្វីដែលប្រសើរ ថ្លៃថ្នូរ យុត្តិធម៌ មនុស្សធម៌ សម្រាប់ខ្លួនឯងផង និងអ្នកដទៃផង ព្រមទាំងចៀសវាងអំពើអាក្រក់សព្វបែបយ៉ាងដែលជាប្រភពនៃវិនាសកម្ម មានន័យថា មនសិការសីលធម៌ បង្កើតឲ្យមាន បះទត្ថភាព ប៉ុន្តែមតិខ្លះបានអត់ឱន ចំពោះអំពើអសីលធម៌ណា ដែលមានកម្រិតទាបដូចជាលួចគេដោយគ្រាន់តែបានចំអែតមួយពេល ឬអំពើដោយគ្រាន់តែសុំរស់ ស្របនឹងគំនិតរបស់ វិចទ័រ ហ៊ុយគ្កោ ( Victor Hugo ) អ្នកនិពន្ធបារាំង
សតវត្សទី ១៩ ក្នុងស្នាដៃមួយឈ្មោះ des Misérahles ឬជនទុរគិត ដែលមានតួអង្គមួយរូបដាច់ចិត្តលួច នំប៉័ង គេដើម្បីរស់ ក៏ត្រូវអាជ្ញាធរចាប់ដាក់គុកជាច្រើនឆ្នាំ ។ វិចទ័រ ហ៊ុយគ្កោ សន្តោសចំពោះបុគ្គលប្រភេទនេះ ប៉ុន្តែមិនសន្តោសចំពោះបុគ្គលដែលយកអំពើលួចប្លន់ឆក់ប្រវញ្ចធ្វើជាមុខរបររកស៊ីជាដាច់ខាត ។

### *បញ្ចប់សេចក្តី :*

មនសិការការងារ ដូចបានរៀបរាប់រួចមកហើយ ដើម្បីឲ្យបានល្អប្រសើរត្រូវប្រកបដោយលក្ខណៈប្រាំប្រការគឺ សមត្ថភាព ពិសោធន៍ ឧបនិស្ស័យ ស្រឡាញ់ការងារ និងសីលធម៌ ។ បើខ្វះខាតប្រការណាមួយ ការងារអាចមានទំនោរទៅរកការខាតបង់ និងវិនាសកម្ម ។ ហេតុនេះ ដើម្បីឲ្យកិច្ចការប្រទេសជាតិបានល្អប្រសើរ រដ្ឋាភិបាលគួរតម្រង់ការងារបុគ្គលម្នាក់ ៗ ឲ្យស្របទៅនឹងទ្រឹស្តី មនសិការការងារ ដែលយើងអាចសង្ខេបបានដូចតទៅនេះ ៖

**មនសិការការងារ = សមត្ថភាព + ពិសោធន៍ + ឧបនិស្ស័យ + ស្រឡាញ់ការងារ + សីលធម៌ ។**

## ប្រធានទី៣៖

*អ្វីទៅសេរីភាព ?*

*តើសេរីភាពអាចចាត់ទុកជាព្រលឹងរបស់ខ្មែរបាន ឬទេ ?*

*ពន្យល់ ពិភាក្សា និងឧទាហរណ៍ ។*

### ផ្ដើមសេចក្ដី :

សេរីភាព ជាវត្ថុសិក្សានៃទស្សនវិជ្ជា ចាប់តាំងពីសតវត្សទី១៨ មក ព្រមទាំងបិតនៅជាកម្មវត្ថុនៃការពិចារណារបស់អ្នកប្រាជ្ញធំ ៗ ក្នុងសកលលោកជាពិសេសអ្នកប្រាជ្ញទស្សនវិជ្ជា ។

តើខ្មែរយល់ព្រមទទួលសេរីភាពជាព្រលឹងរបស់ខ្មែរឬទេ ?

### តួសេចក្ដី :

តើសេរីភាពមានន័យដូចម្ដេច ?

- តាមន័យទូទៅ សេរីភាពសំគាល់ភាពធ្វើអ្វី ៗ បានតាមចិត្តគ្មានការបង្ខិតបង្ខំទោះបី ក្នុងផ្លូវគំនិតក្ដី ជំនឿក្ដី និងសកម្មភាពសព្វយ៉ាងធ្វើបានតាមចិត្ត ។
- ដេកាត យល់ថាសេរីភាពបិតនៅត្រង់ការបានទទួលស្គាលការពិត ព្រោះជនគ្មានសេរីភាព ពុំបានទទួលស្គាល់ការពិតទេ ឃើញអាក្រក់ថាល្អ ឃើញសថាខ្មៅ ឃើញបាបថាបុណ្យជាដើម... ។
- បូ ស៊ុយអេ យល់ថា សេរីភាពគឺជាសិទ្ធិធ្វើអ្វី ៗ ដែលច្បាប់អនុញ្ញាតឲ្យធ្វើ ។

- ពួកបណ្ឌិត យល់ថា សេរីភាព គឺភាពមិននៅក្រោមបង្គាប់តណ្ហា ភាពមិននៅក្រោម អវិជ្ជា

នេះជាសេរីភាពយល់តាមសាសនា ទោះបីសាសនាគ្រីស្តគ្គី អ៊ីស្លាមគ្គី ព្រះពុទ្ធគ្គី ។

- ឡេប នីស យល់ថា សេរីភាព គឺភាពធ្វើអ្វី ៗ សមប្រកបតាមវិចារណៈ ។

- Fustel de Coulanges បានពន្យល់សង្កត់លើសេរីភាពបុគ្គលដោយអះអាងថា កាល កាលណាគេនិយាយពីច្បាប់សង្គម គេត្រូវដកហូត សេរីភាពពីបុគ្គល ។

- ពួកខន្តិនិយម យល់ថាសេរីភាព គឺជាសកម្មភាពមួយកើតឡើងដោយឆន្ទៈ របស់បុគ្គលម្នាក់ ៗ ហាក់ដូចជាសកម្មភាពនោះកើតឡើងដោយស្វ័យប្រវត្តិ ពុំមានទទួលឥទ្ធិពលពីកម្លាំងក្រៅខ្លួន មានន័យថា អ្វី ៗ ទាំងអស់អាស្រ័យនៅលើយើងជាអ្នកសំរេច ។ គ

- ឡាគ័រឌែរ ( Lacordaire ) យល់ថាធ្វើច្បាប់ហើយគោរពច្បាប់ ដោយពិតប្រាកដ ស្របនឹងឆន្ទៈរបស់យើង គឺជា បកាសនសព្ទ័ នៃសេរីភាព ។

- មីសែល ( Michel ) យល់ថា ការគ្រប់គ្រងរដ្ឋ គឺជាលក្ខ័ណ្ឌមួយចាំបាច់ដែលត្រូវធ្វើឲ្យមានសេរីភាព ។

- អាលប៊ែរកាមុស ( A.Camus ) យល់ថា សេរីភាពគឺជាការភ្ញាក់ខ្លួនដោយដឹងថា ជីវិតរបស់យើងទាំងអស់គ្នាសព្វថ្ងៃ គឺជាជីវិតឥតន័យ ហេតុនេះត្រូវបះបោរឡើងដើម្បីស្វែងរកន័យពិតប្រាកដរបស់ជីវិត ។

- ហ្សង់ប៉ូលសាត្រ យល់ថា សេរីភាពគឺភាពធ្វើអ្វី ៗ ដោយគ្មានលក្ខ័ណ្ឌ ។

- ឌៀរខេម យល់ថា នឹងមានសេរីភាព លុះត្រាតែមានយុត្តិធម៌ក្នុងសង្គម ព្រោះបើគ្មានយុត្តិធម៌ក្នុងសង្គមទេ គេប្រើមធ្យោបាយបំបិទសេរីភាពឲ្យខាងតែបាន ហើយដើម្បីឲ្យមានយុត្តិធម៌ក្នុងសង្គម គេត្រូវរកវិធីបំបាត់កុំឲ្យមានអ្នកមាន និងអ្នកក្រពីកំណើតមក ។

- អូគ្គូសកុង យល់ថា សេរីភាពគឺជាការរំដោះមនុស្សចេញពីនឹម របស់សង្គម គឺនឹមរបស់អ្នកខ្លាំងលើអ្នកខ្សោយ ព្រោះក្នុងលោកយើងនេះ មនុស្សដែលស្មានថាខ្លួនមានសេរីភាព តាមពិតគឺឥតមានសេរីភាពទេ អ្នកខ្លាំងសង្កត់សង្កិនលើអ្នកខ្សោយជានិច្ច ។

- កាន្ត ( Kant ) ទស្សនវិទូអាល្លឺម៉ង់ យល់ថា សេរីភាព គឺជាស្វ័យសត្យនៃកិច្ចការពោលគឺកិច្ចការដែលយើងត្រូវធ្វើ គឺយើងត្រូវតែប៊ានធ្វើដោយមិនភ័យខ្លាចមានអ្នកដទៃរិះគន់ ព្រោះស្វ័យសត្យសំគាល់ទ្រឹស្តីមួយប្រភេទដែលប្រាប់គេហើយពន្យល់បាន ។ កាន្តបានបញ្ជាក់ទៀតថា សេរីភាព គឺជាសកម្មភាពណាដែលប្រឆាំងនឹងគំនិតថាចាំបាច់និយម មានន័យថា កាលណាយើងយល់ថាអ្វី ៗ មានលក្ខណៈចាំបាច់ ឬពុំចាំបាច់ យើងហាក់ដូចជាបាត់បង់សេរីភាព

ពីព្រោះកាលណាគេនិយាយពីសេរីភាព គេពុំត្រូវនិយាយពីអ្វីដែលចាំបាច់ទេ ។

- បូស៊ុយអេ បានពន្យល់ទៀតថា សេរីភាពត្រូវមានន័យជាកាយវិការព្រងើយកន្តើយពុំពឹងពាក់អ្នកដទៃពុំចេះចុះញ៉ូមអ្នកដទៃ ។ គេយល់ថា បុគ្គលម្នាក់ ៗ ដែលដឹងថាខ្លួនមានសេរីភាព គឺបុគ្គលដែលមានអាកប្បកិរិយាព្រងើយកន្តើយ ពើងទ្រូង ពុំចុះញ៉ូម បុគ្គលrបែបនេះជាបុគ្គលដែលគួរគោរព ប៉ុន្តែខ្មែរយើងច្រើននិយមថាឈ្លើយទៅវិញ ។ បូស៊ុយអេ បានបង្កើតទ្រឹស្តីមួយឈ្មោះ សេរីកម្ម ( le Jidre arbiter ) ។ លោក ពោលថា សេរីកម្ម គឺជាកម្លាំងមួយរបស់យើងដែលដឹកនាំឲ្យយើងធ្វើអ្វីមួយ ឬមិនធ្វើអ្វីមួយពុំមែនបានសេចក្តីថា ធ្វើអ្វីមួយដោយមិនដឹងខ្លួន ឬគេបញ្ជាឲ្យធ្វើ ឬកម្លាំងក្រៅខ្លួនដឹកនាំឲ្យធ្វើ ឬធ្វើដោយចៃដន្យ ដូចក្នុងករណីទុំក្នុងរឿងទុំទាវ ។ ទុំពុំព្រម

យករាជសារទៅបង្ហាញអរជូន ។ តើទុំភ្លេច ឬជាដំណោះស្រាយរបស់ទុំ ។ បើយើងយល់ថាភ្លេច គឺទុំឥតមានសេរីកម្មទេ ។ បើទុំដឹងខ្លួនថា ដំណោះស្រាយបែបនេះគឺជាការសំរេចចិត្តដោយពុំពឹងពាក់លើកម្លាំងអ្នកដទៃ ហើយជាដំណោះស្រាយដែលធ្លាប់មានពីមុនមកដូចជាទុំហ៊ាន ប្រឆាំងនឹងស្តេចដោយពឹងផ្អែកលើមធ្យាបាយផ្ទាល់ខ្លួន ។ ចំណុចនេះអាចចាត់ទុកថាជាសេរីកម្មរបស់ទុំ មានន័យថា ទុំធ្វើដោយដឹងខ្លួនជាការឆ្លុះបញ្ជាក់ បុគ្គលិកលក្ខណៈរបស់ទុំ ដែលមាន អត្តៈជាញាណ

- ប៊ែរសុន ( Bergson ) យល់ថា សេរីភាព គឺជាសកម្មភាពអ្វី ៗ ដែលយើងធ្វើដោយមិនបាច់គិត ព្រោះកាលណាយើងគិត យើងនឹកទៅដល់អ្វីដែលគួរធ្វើ មិនអ្វីដែលមិនគួរធ្វើ ។ ដូចនេះ លោក ប៊ែរសុន គឺ សហជញាណ ប៉ុន្តែទស្សនវិទូដទៃទៀតពុំយល់ស្របតាមដោយ ហេតុថា អ្វី ៗ ដែលយើងធ្វើដោយពុំបានគិត ពុំមែនសុទ្ធតែត្រូវទាំងអស់ទេ ឯលោក ប៊ែរសុន ឆ្លើយទៅវិញថា អ្វី ៗ ដែលយើងគិតក៏ពុំមែនសុទ្ធតែត្រូវទាំងអស់ទេ ហេតុនេះតាមលោក ប៊ែរសុន អ្វី ៗ ដែលយើងធ្វើដោយពុំបានគិតឬពុំប្រើគំនិត គឺជាន័យពិតប្រាកដរបស់សេរីភាព ។

ទាំងអស់នេះសុទ្ធសឹងជានិយមន័យប្លែក ៗ គ្នាអំពីសេរីភាព ។ តើសេរីភាពមានបិតនៅក្នុងវិស័យណាខ្លះ ?

### ក/ សេរីភាពតាមធម្មជាតិ

- គ្មានការកំហែងគំរាម
- អាចធ្វើអ្វី ៗ តាមធម្មជាតិ ឬតាមឆន្ទៈរបស់មនុស្សម្នាក់ ៗ
- មនសិការហាក់ដូចជាគ្មានឧបសគ្គរាំង
- ធ្វើកិច្ចការដោយសេរី

### ខ/ សេរីភាពពលរដ្ឋ

ពលរដ្ឋម្នាក់ ៗ អាចធ្វើអ្វីតាមចិត្តដោយមានច្បាប់អនុញ្ញាតឲ្យធ្វើ ស្របនឹងគំនិតរបស់លោក ម៉ុងតេស្គីយើ ប៉ុន្តែច្បាប់ត្រូវប្រកបដោយ លក្ខណៈត្រឹមត្រូវនិងប្រជាធិបតេយ្យ ។

គ/ សេរីភាពនយោបាយ

ពលរដ្ឋម្នាក់ ៗ មានសេរីភាពធ្វើនយោបាយបានតាមចិត្ត ឲ្យតែនយោបាយនោះអាចធ្វើឲ្យប្រជាពលរដ្ឋបានសេចក្ដីសុខចម្រើន សំបូណ៌សប្បាយ ក្នុងស្ថានភាពមួយដ៏ប្រសើរ ប៉ុន្តែត្រូវរៀបច្បាប់ឲ្យបានត្រឹមត្រូវដើម្បីចៀសវាងប្រជភិថុតសព្វយ៉ាង ដោយគ្រាន់តែដណ្ដើមយកអំណាចហើយដេកស៊ីលើអំណាច ។ ម្យ៉ាងទៀត សេរីភាពនយោបាយឋិតលើការអនុញ្ញាតឲ្យប្រជាពលរដ្ឋប្រជុំគ្នាបាន អាចបង្កើតសមាគម មានសិទ្ធិបញ្ចេញយោបល់ និងសិទ្ធិសរសេរ ។

ឃ/ សេរីភាពសេដ្ឋកិច្ច

ពលរដ្ឋម្នាក់ ៗ អាចប្រកបវិជ្ជាជីវៈ បានតាមចំណូលចិត្តដោយគ្មានអន្តរាគមន៍ពីរដ្ឋដូចជាទំនិញតិចលក់ថ្លៃ ទំនិញច្រើនលក់ថោក ប៉ុន្តែរដ្ឋត្រូវទទួលខុសត្រូវក្នុងករណីខ្វះខាត ។

តាមការអធិប្បាយរួចមកហើយអំពីសេរីភាព តើសេរីភាពអាចចាត់ទុកជាព្រលឹងរបស់ខ្មែរឬទេ ?

បន្ទាប់ពីឋិតក្រោមអំណាច សៀម យួន បារាំង មកខ្មែរចង់បានសេរីភាពដោយចង់រស់នៅជាអ្នកជា មានន័យថាខ្មែរស្រឡាញ់សេរីភាព ប៉ុន្តែក្នុងការរស់នៅ ខ្មែរពុំយល់សេរីភាពច្បាស់លាស់ផង ច្រើនអនុវត្តសេរីភាពហួសព្រំដែនច្បាប់ ឬបង្វែរន័យ សេរីភាពឲ្យប្រាសចាកន័យដើមដូចជាខ្មែរពោលថា « *ពលរដ្ឋម្នាក់ ៗ អាចធ្វើអ្វីៗ បានតាមចិត្តកុំឲ្យតែប៉ះពាល់ដល់សេរីភាពអ្នកដទៃ ឬកុំឲ្យខូចរបៀបរៀបរយ...* » ។

តាមន័យនេះ ពុំដឹងជាសេរីភាពខ្មែរមានន័យដូចម្ដេចទេ ព្រោះបើហាមមិនឲ្យនិយាយប៉ះពាល់អ្នកដទៃ មានតែនិយាយខ្លួនឯង បើនិយាយតែខ្លួនឯងគឺជាជំងឺខួរក្បាល បើភ័យខ្លាចខូចរបៀបរៀបរយ តើរបៀបរយរបស់នរណា ? របស់បុគ្គលឬរបស់សង្គម ឬរបស់ជាតិ ?

ពលរដ្ឋខ្មែរចេះតែទទួលអនុវត្តសេរីភាព ទោះបីគេបង្វែរន័យរបស់សេរីភាពដូចម្ដេច ក៏ដោយ ជាការបញ្ជាក់ថាខ្មែរយល់ន័យសេរីភាពពុំច្បាស់លាស់ទេ រហូតដល់សព្វថ្ងៃតាំងពីការបិទមាត់ការសែតឯកជនពីសម័យព្រឹត្តិការណ៍ ១៧ មីនា ១៩៧៣ មកម្ល៉េះ ។

តាមន័យខាងលើនេះ សេរីភាពពុំមែនជាព្រលឹងរបស់ខ្មែរទេ ព្រោះខ្មែរទាមទាតែយុត្តិធម៌ពោលគឺយុត្តិធម៌សង្គម ។ បើបានយុត្តិធម៌សង្គមហើយ ទោះបីគេបិទសេរីភាពក៏បិទទៅចុះឲ្យតែនៅក្នុងផ្លូវយុត្តិធម៌ ព្រោះយុត្តិធម៌ជាគ្រឹះនៃការរីកចម្រើនទាំងឡាយក្នុងប្រទេសជាតិ ។ អ្នកស្រឡាញ់របបប្រជាភិថុតពុំនិយមប្រើពាក្យយុត្តិធម៌ទេ គេបែរជាប្រើពាក្យ សេរីភាព វឌ្ឍនភាព សុភមង្គល

ដែលជាផលកើតចេញពីយុត្តិធម៌ ។ បើគ្មានយុត្តិធម៌ជាគ្រឹះ គ្មានទេសេរីភាព គ្មានទេសមភាព គ្មានទេភាតរភាព គ្មានទេវឌ្ឍនភាព គ្មានទេសុភមង្គល គឺមានតែវិនាសកម្ម និង ភ័យន្តរាយ សព្វយ៉ាង ។

**បញ្ចប់សេចក្តី :**

រួមសេចក្តីមក សេរីភាពគឺជាផល នៃអំពើដែលគួរចង់បាន ប៉ុន្តែពុំមានសារៈសំខាន់ចំពោះខ្មែរស្រេទ្បាញ់តែយុត្តិធម៌ ឲ្យតែបានយុត្តិធម៌ ខ្មែរឈប់មាត់កហើយដូចជាការបិទសេរីភាព សារព័ត៌មាន ពុំបានធ្វើឲ្យខ្មែរភ្ញាក់ផ្អើលប៉ុន្មានទេ ប៉ុន្តែខ្មែរភ្ញាក់ផ្អើលតែអំពើអយុត្តិធម៌ ។

## ប្រធានទី៤៖

*ឆន្ទៈជាអ្វី ? ប្រភពនៃឆន្ទះ ? ផលដែលកើតមកពីឆន្ទៈ ?*

*តើត្រូវធ្វើដូចម្តេចដើម្បីឲ្យខ្មែរមានឆន្ទៈ ?*

## ផ្តើមសេចក្តី :

ឆន្ទៈជាវត្ថុសិក្សាចិត្តវិជ្ជាផ្នែកសកម្ម ក្នុងករណីដែលគេលើកយក សកម្មភាពរបស់បុគ្គលម្នាក់ ៗ មកពិចារណាថា តើជាសកម្មភាពប្រភេទណា ? តើជាសកម្មភាពធ្វើដោយចំណង់ចំណូលចិត្ត ឬដោយការបង្ខិតបង្ខំ ? តើត្រូវធ្វើដូចម្តេចដើម្បីឲ្យខ្មែរមានឆន្ទៈល្អ ?

## តួសេចក្តី :

១- តាមន័យទូទៅ ឆន្ទៈសំគាល់កំលាំងអ្វីដែលដឹកនាំឲ្យ បុគ្គលធ្វើអំពើរ ។ គេសង្កេតឃើញឆន្ទៈតាមផ្លូវកាយ និងឆន្ទៈតាមផ្លូវចិត្ត ។ តាមចិត្តវិជ្ជា ឆន្ទៈតាមផ្លូវកាយកើតមកពីការបញ្ជានៃខួរឆ្អឹងខ្នង និងកើតមកពីកាយសញ្ញា របស់បុគ្គលដែលធ្វើឲ្យគេដឹង ប៉ុន្តែមិនត្រូវច្រឡំឆន្ទៈ និងអចេតនកម្មទេ ព្រោះអចេតនកម្ម គឺជាអញ្ញាណដែលជាអំពើធ្វើដោយពុំដឹងខ្លួន ដូចជា ព្រិចភ្នែក លើកដៃរង ប្រឹងទប់ខ្លួនមិនឲ្យដួល និងអំពើផ្សេង ៗ ទៀតធ្វើដោយអចេតនា ។ មិនត្រូវច្រឡំឆន្ទៈ នឹងសភាវគតិ ដែលជានិឆន្ទៈ ពុំតំណាងគោលគំនិតរបស់បុគ្គលទេ ព្រមទាំងមិនត្រូវច្រឡំនឹងទំលាប់ដែលមានលក្ខណៈស្វ័យភាព ។ ម្យ៉ាងទៀត ឆន្ទៈមិនត្រូវរាប់បញ្ចូលក្នុងពពួកអំពើដែលធ្វើដោយដឹងខ្លួន ប៉ុន្តែគ្មានបំណង ដូចជាគ្រោះថ្នាក់ ចំគង និងអំពើខកខាន ទាំងអស់នេះត្រូវគេចាត់ទុកជាអំពើអឆន្ទៈជាមួយនិងការបង្ខិតបង្ខំសព្វយ៉ាង ។

ឆន្ទៈតាមផ្លូវចិត្តកើតមកពី

- អំពើធ្វើដោយដឹងខ្លួន
- អំពើធ្វើដោយត្រិះរិះ
- អំពើធ្វើដោយមានបំណងច្បាស់លាស់

ហេតុនេះ ឆន្ទៈតាមផ្លូវកាយក្តី ផ្លូវចិត្តក្តី បង្កើតឲ្យមានសកម្មភាពដែលបុគ្គលធ្វើដោយដឹងខ្លួន ប៉ុន្តែនឹងអាចធ្វើបានលុះត្រាតែបុគ្គលមានលទ្ធភាពធ្វើ ព្រោះមនុស្សពុំអាចមានឆន្ទៈហួសពីសមត្ថភាពរបស់ខ្លួនទេ ។

២-ប្រភពនៃឆន្ទៈ

- ឆន្ទៈអាចកើតមកពីជំរើស ដូចជាពេញចិត្តនឹងស្រី ណាមួយក៏យល់ព្រមរៀបការជា

មួយស្រីនោះ ពោលគឺជ្រើសហើយទើបសំរេចចិត្តឯការសំរេចចិត្តជាន័យរបស់ឆន្ទៈ ។

- ឆន្ទៈអាចកើតមកពីទំលាប់ ដូចជាធ្លាប់ធ្វើអ្វីមួយបានទទួលជោគជ័យ ក៏ចង់ធ្វើតទៅទៀត បើទទួលបរាជ័យ នឹងអស់មានឆន្ទៈហើយ ។

- ឆន្ទៈអាចមានប្រភពមកពីសុខភាព តាមផ្លូវកាយរបស់បុគ្គលព្រោះបើបុគ្គលអស់កម្លាំងហត់នឿយ ឈឺច្រើន បុគ្គលពុំសូវមានឆន្ទៈទេរ ។

- ឆន្ទៈអាចមានប្រភពមកពីច្បាប់សង្គម ព្រោះបើសង្គមពុំមានច្បាប់ទំលាប់ត្រឹមត្រូវ ខ្វះមធ្យោបាយអប់រំ ខ្វះកិច្ចការពារសន្តិសុខរបស់បុគ្គល ខ្វះការធានារ៉ាប់រងអាយុជីវិតរបស់បុគ្គល បុគ្គលពុំមានឆន្ទៈទេ ពោលគឺគ្មានសុឆន្ទៈដូចជាពេលចាប់ពលរដ្ឋធ្វើទាហាននៅភ្នំពេញ កាលព្រឹត្តិការណ៍ថ្ងៃទី ៣០ កក្កដា បរិយាកាសភ្នំពេញស្ងាត់ជ្រងំ ។ ហេតុអ្វីបានជាខ្មែរពេលនោះប្រាសចាកឆន្ទៈ ? ព្រោះគេយល់ថា ជាការស្លាប់គ្មានន័យ សង្គមពុំអាចផ្តល់ឲ្យគេនូវការធានាខុសត្រូវដល់គ្រួសារ បើគេស្លាប់នៅសមរភូមិ គេជឿជាក់ក្នុងចិត្តថា គ្រួសារគេនឹងត្រូវវេទនាពុំខាន ប្រាក់ជំនួយពីរដ្ឋមានចំនួនពុំគ្រប់គ្រាន់ ហើយពិបាកបើកទៀតផង ជួនកាលសូកលុយគេអស់ប្រាំម៉ឺនរៀលដើម្បីបើកប្រាក់បីម៉ឺនរៀល ។ ម្យ៉ាងទៀតសេចក្តីស្លាប់ហាក់ដូចជាងាយ ៗ ពេក... ទាំងអស់នេះហើយដែលធ្វើឲ្យខ្មែរបាត់បង់ឆន្ទៈ ។

### ៣- ផលដែលកើតមកពីឆន្ទៈ

- អំពើប្រកបដោយឆន្ទៈ ទោះបីតាមផ្លូវកាយក្តី ផ្លូវចិត្តក្តី មានឈ្មោះថា ឆន្ទៈកម្ម ។ បើជាឆន្ទៈល្អនឹងមានឈ្មោះថា សុឆន្ទៈ បើជាឆន្ទៈអាក្រក់នឹងមានឈ្មោះថា ទុឆន្ទៈ ។

- ឆន្ទៈប្រឆាំងនឹងអំពើទោះបីតាមផ្លូវចិត្តក្តី ផ្លូវកាយក្តី មានឈ្មោះថា បដិឆន្ទៈ ពោលគឺឆន្ទៈដែលឆ្លើយជំទាស់នឹងអ្វីមួយ ប៉ុន្តែពុំមែនជា ទុឆន្ទៈ ទេ ។

- ឆន្ទៈមួយបែបទៀតមានឈ្មោះថា និឆន្ទៈ ករណីដែលបុគ្គលដឹងខ្លួនថាខុសដែរ ប៉ុន្តែនៅធ្វើ ដូចដឹងថាស្រីណាម្នាក់ពុំព្រមស្រឡាញ់យើងដោយប្រការណាមួយ ប៉ុន្តែយើងនៅតែតាមអង្វរករសុំសេចក្តីស្នេហាពីស្រីនោះទៀត ។ ទុំដឹងថាទៅជួបអជូនពិតជាត្រូវស្លាប់ ប៉ុន្តែ ទុំនៅតែទៅ ។

### ៤ - តើត្រូវធ្វើដូចម្តេចដើម្បីឲ្យខ្មែរមានឆន្ទៈល្អ ឬ សុឆន្ទៈ ?

ខ្មែរក៏ដូចជាបុគ្គលដទៃទៀតដែរ ដើម្បីឲ្យមាន សុឆន្ទៈ :

- ត្រូវមានការរស់នៅបង្គួរ ដែលអាចចិញ្ចឹមជីវិតបាន
- ត្រូវមានច្បាប់ទំលាប់ដែលគួរឲ្យទុកចិត្តបាន
- អ្នកដឹកនាំរដ្ឋពិតជាមានគំនិតស្នេហាជាតិឥតក្លែងក្លាយ
- អាជ្ញាធរ ទាំងអស់ពិតជាធ្វើការបម្រើរដ្ឋ

- សំខាន់ជាគេគឺ យុត្តិធម៌ ព្រោះបើមានអំពើអយុត្តិធម៌នៅទីណា គ្មានទេសុឆន្ទៈ ទោះបីគេយកកាំភ្លើងមកភ្ជង់ដើមទ្រូងក៏ដោយ ។
- ចំណុចខ្សោយមួយដែល អាចធ្វើឲ្យខ្មែរមាន សុឆន្ទៈ គឺ*ចេះបញ្ជោរ និងចេះសរសើរ* ព្រោះអំបូរខ្មែរមនចូលចិត្តពាក្យបញ្ជោរ និងពាក្យសរសើរ ។

## បញ្ចប់សេចក្តី:

រួមសេចក្តីមក ការអធិប្បាយរួចមកហើយ បានបង្ហាញឲ្យឃើញថា ឆន្ទៈ ជាសមត្ថភាពមួយទាក់ទងជិតស្និទ្ធទៅនឹងផ្លូវចិត្ត ផ្លូវសកម្មរបស់បុគ្គលក្នុងវិស័យចិត្តវិជ្ជា ក៏ដូចជាវិស័យទស្សនវិជ្ជាដែរ ។ ហេតុនេះដើម្បីបណ្តុះទឹកចិត្តបុគ្គលឲ្យមាន សុឆន្ទៈ ព្រមទាំងចៀសវាង ទុឆន្ទៈ គេត្រូវយល់ឲ្យបានច្បាស់លាស់អំពីបញ្ហាបុគ្គលប្រឈមមុខ នឹងសង្គមដែលខ្លួនរស់នៅ ដើម្បីទាក់ទាញឆន្ទៈបុគ្គលនីមួយ ៗ ឲ្យមានទំនោរទៅរក សីលធម៌ សមប្រកបតាមគោលដៅរបស់មនុស្សទូទៅ ឯឆន្ទៈដែលមានទំនោរទៅរក អសីលធម៌ ត្រូវចៀសវាង ក្នុងន័យដឹកនាំប្រទេសជាតិនីមួយ ៗឲ្យបានសម្រេចសុភមង្គល ។

## ប្រធានទី៥៖

*អ្វីខ្លះជាសម្បត្តិវប្បធម៌លទ្ធកម្ម និងសម្បត្តិវប្បធម៌ធម្មជាតិរបស់ខ្មែរ ?*

*តើសម្បត្តិវប្បធម៌អាចបណ្តុះគំនិតជាតិនិយម ឬគំនិតមាតុភូមិនិយម ?*

**ផ្តើមសេចក្តី :**

ប្រទេសទាំងឡាយដែលគេទទួលស្គាល់ថា មានវប្បធម៌ និងអរិយធម៌រុងរឿងដោយសារតែសម្បត្តិវប្បធម៌របស់ខ្លួន យ៉ាងណាមិញប្រទេសខ្មែរ ក៏សំបូរដោយសម្បត្តិវប្បធម៌ដែលជាកេរដំណែល និងមត៌ករបស់បុព្វបុរសជាភស្តុតាងនៃដួងព្រលឹងជាតិ ទោះបីជាសម្បត្តិវប្បធម៌លទ្ធកម្មក្តី សម្បត្តិវប្បធម៌ធម្មជាតិក្តី ។ តើសម្បត្តិវប្បធម៌ទាំងពីរយ៉ាងនេះអាចបណ្តុះគំនិតជាតិនិយម ឬគំនិតមាតុភូមិនិយម ?

**តួសេចក្តី :**

*អ្វីខ្លះជាសម្បត្តិវប្បធម៌លទ្ធកម្មរបស់ខ្មែរ ?*

សម្បត្តិសំគាល់នូវភោគទ្រព្យទាំងឡាយ សំរាប់បណ្តុះចំណេះដឹង បណ្តុះគំនិតពិចារណា បណ្តុះទឹកចិត្តស្រឡាញ់រាប់អានចង់បាន និងចង់រក្សាទុកឲ្យបានប្រពៃពោលគឺជាឃ្លាំងនៃពុទ្ធិ ។ សម្បត្តិវប្បធម៌លទ្ធកម្ម សំគាល់ភោគទ្រព្យទាំងឡាយ ដែលជនជាតិណាមួយ បានបង្កើតឡើង កសាងឡើង បណ្តុះបណ្តាលឡើងជាសមិទ្ធិសំរាប់ជាមត៌កដល់កូនចៅសម័យក្រោយ ។ តើខ្មែរមាន

សម្បត្តិវប្បធម៌លទ្ធកម្មអ្វីខ្លះ ?

យើងអាចស្រាវជ្រាវរកសម្បត្តិវប្បធម៌លទ្ធកម្ម របស់ខ្មែរតាមវិស័យនីមួយ ៗ ដូចជា វិស័យអក្សរសាស្ត្រ វិស័យវិទ្យាសាស្ត្រ វិស័យតិចនិច វិស័យជំនឿ វិស័យសិល្បះ និង វិស័យស្ថាបត្យកម្ម ។

ក្នុងវិស័យអក្សរសាស្ត្រ ខ្មែរមានសំណេរយ៉ាងច្រើន សរសេរលើស្បែកសត្វ លើបន្ទះក្តារ លើផ្ទាំងថ្ម ដែលគេហៅថាសិលាចារឹក ដូចជា សិលាចារឹកនៅភ្នំដា ស្តុកកក់ធំ វ៉ាកាញ់ ប្រាសាទប្រាំល្វែង និងសិលាចារឹកនៅប្រាសាទដទៃទៀតយ៉ាងច្រើន រាប់ក្នុងចំណោមរចនាបថទាំង១២ ដូចជា រចនាបថ សំបូរ ព្រៃក្មេង កំពង់ព្រះ គូលែន ព្រះគោ បាខែង កោះកេរ បន្ទាយស្រី ឃ្លាំង បាពួន អង្គរវត្ត បាយ័ន . . . ។

ខ្មែរមានសំណេរលើសាស្ត្រាស្លឹករឹតដែលមានតំកល់ទុកនៅវត្តអារាមរហូតមកដល់សព្វថ្ងៃ ព្រមទាំងសំណេរលើក្រដាសដូចមានបោះពុម្ពសព្វថ្ងៃនេះ ។ ទាំងអស់នេះគឺជាសម្បត្តិវប្បធម៌ផ្នែកអក្សរសាស្ត្រ របស់ខ្មែរ ដែលមានតាំងពីបុរាណកាលរហូតដល់សព្វថ្ងៃ ជាកេរ្តិ៍ដំណែលដ៏មានតម្លៃ

ក្នុងវិស័យវិទ្យាសាស្ត្រ គេកត់សំគាល់ឃើញថា ខ្មែរចេះគន់គូរដំណើរគោចរព្រះអាទិត្យ ព្រះចន្ទតាមរនោច តាមខ្នើត ដើម្បីកំណត់សូរ្យគ្រាស និងចន្ទគ្រាស គ្រាន់តែវិធីពន្យល់លេខប្លែកពីអឺរ៉ុបបន្តិច ។

ក្នុងវិស័យតិចនិច ខ្មែរចេះធ្វើសិប្បកម្មដូចជាចេះធ្វើកញ្ច្រែង ត្រក់ បង្គី ឈ្នាង ទ្រូ ធ្នូ ស្នា ចង្អេរ ត្បាល់កិនស្រូវ ក្អម ឆ្នាំង . . . ។

ក្នុងវិស័យជំនឿ ខ្មែរជឿហោរា ជឿធម្មជាតិ ជឿគុណម្តាយឪពុក ជឿខ្មោចព្រាយ ជឿអ្នកតា និងជឿអាទិទេពដែរ ព្រមទាំងជឿថាមនុស្សស្លាប់ទៅកើតវិញ ។

ក្នុងវិស័យសិល្បៈ ខ្មែរមាន ភ្លេង របាំ ចំរៀង ល្ខោន និងគ្រឿងភ្លេងយ៉ាងច្រើន ។ ខ្មែរមាន ភ្លេងប្រជាប្រិយ ភ្លេងការ ភ្លេងមហោរី ភ្លេងខ្មែរ . . . ខ្មែរមានរបាំងក្ងោក របាំទន្សោង របាំមេអំបៅ

របាំអាយ៉ៃ របាំរាំវង់ របាំរាំក្បាច់ របាំត្រុត របាំកាប់ក្របីផឹកស្រា របាំឃីកេ . . . ដែលគេប្រទះឃើញរបហូតមកដល់សព្វថ្ងៃនេះ ។ ខ្មែរមានចំរៀងចាប៉ីសំរាប់និទានរឿង ចំរៀងប្រកកែសំរាប់ឆ្លើយឆ្លងគ្នា ចំរៀងបំពេរ ចំរៀងលួងលោម ចំរៀងស្នេហា. . . ។ ខ្មែរមាន ល្ខោនខោល ល្ខោនត្រាប់ ល្ខោននិយាយ ល្ខោនបាសាក់ដែលមានជីវិតរហូតមកដល់សព្វថ្ងៃតំណាងវប្បធម៌ និងអរិយធម៌ខ្មែរ ។ ខ្មែរមានគ្រឿងភ្លេងច្រើនទៀត ដូចជា រនាតឯក រនាតដែក រនាតធុង ទ្រខ្មែរ ទ្រសោរ ទ្រអ៊ូ ទ្រឆេ តាខេ ខ្លុយ ឃឹម ស្គរ សំភោរ ប៉ីកែវ ប៉ីបបុស ប៉ីអ ប៉ីពក ស្រឡៃ គងតូច គងធំ ចាប៉ី ឆៃយ៉ាំ ក្រាប សាដៀវ . . . ដែលមានរូបរាងរហូតមកដល់សព្វថ្ងៃ ហើយជាសម្បត្តិវប្បធម៌ពិសេសសំរាប់បញ្ជាក់នូវលក្ខណៈភ្លេងខ្មែរ ។

ខ្មែរមានល្បែងប្រជាប្រិយយ៉ាងច្រើនដូចជា ប្រណាំងទូក ប្រណាំងសេះ ប្រណាំងរទេះគោ ប្រជល់មាន់ ប្រជល់ងំរី ប្រជល់ជ្រូក ប្រជល់គោ ប្រជល់ត្រី បោះអង្គុញ ចោលឈូង លាក់កន្សែង បិតពួន ស្តេចចង់ អ៊ូ ចោលងំបង វាយឆ្នាំង ទាញព្រ័ត្រ ហ៊ឹង ដែលមានជីវិតរហូតមកដល់សព្វថ្ងៃ ប៉ុន្តែមានល្បែងខ្លះហាក់ដូចបាត់បង់ខ្លះដែរព្រោះយើងលែងនឹកនា ។

ក្រៅពីសម្បត្តិវប្បធម៌លទ្ធកម្មដូចបានអធិប្បាយរួចមកហើយ ខ្មែរមានសម្បត្តិវប្បធម៌ធម្មជាតិច្រើនទៀត ។

*អ្វីខ្លះជាសម្បត្តិវប្បធម៌ធម្មជាតិរបស់ខ្មែរ ?*

សម្បត្តិវប្បធម៌ធម្មជាតិសំគាល់នូវភោគទ្រព្យទាំងឡាយ របស់ជនជាតិណាមួយដែលកើតពីធម្មជាតិ ផ្ទុយពីអ្វីដែលមនុស្សបង្កើតឡើង ។ សម្បត្តិវប្បធម៌ធម្មជាតិរបស់ខ្មែររាប់តាំងពីព្រំដែនទឹកដីនៃប្រទេសខ្មែរ អាកាសធាតុ ព្រៃព្រឹក្សា ភ្នំ សមុទ្រ ឆ្នេរខ្សាច់ ស្ទឹង បឹងបួ ព្រែក ត្រពាំង ស្រះ កោះ . . . ។

តើមនុស្សខ្មែរ គួររាប់បញ្ចូលក្នុងសម្បត្តិវប្បធម៌ណាមួយ ?

មនុស្សខ្មែរក៏ជាសម្បត្តិវប្បធម៌ដែរ ព្រោះមនុស្សខ្មែរអាចឲ្យបរទេសស្គាល់ប្រទេសខ្មែរ

ស្គាល់វប្បធម៌ និងអរិយធម៌ខ្មែរ ស្គាល់អ្វី ៗ ដែលជាខ្មែរ ហើយលើសពីនេះទៅទៀត មនុស្សខ្មែរជាអ្នកថែរក្សាសម្បត្តិវប្បធម៌ដទៃទៀតឲ្យបានគង់វង់ មានន័យថា មនុស្សមានកំណើតចេញពីសម្បត្តិវប្បធម៌លទ្ធកម្មផង និង សម្បត្តិវប្បធម៌ធម្មជាតិផង ។ បើខ្វះមនុស្សខ្មែរ ឬមនុស្សខ្មែរកាន់តែវិនាសអន្តរធាន ដោយសារសង្គ្រាម ដណ្តើមអំណាចគ្នាពុំឈប់ឈរ ដោយសារការកែនខ្មែរទៅស្លាប់គ្មានន័យ ខ្លះពុំដឹងស្លាប់ដោយហេតុអ្វីផង . . . ទាំងអស់នេះនិងនាំឲ្យវិនាសដល់សម្បត្តិវប្បធម៌ធម្មជាតិ យូរ ៗ ទៅវិនាសដល់ជនជាតិ ទីបំផុតគឺរលាយប្រទេស ។

តើសម្បត្តិវប្បធម៌បណ្តុះគំនិតជាតិនិយម ឬគំនិតមាតុភូមិនិយម ?

ដើម្បីដោះស្រាយបញ្ហានេះ យើងគួរយល់ គំនិតជាតិនិយមជាអ្វី ? គំនិតមាតុភូមិនិយមជាអ្វី ?

- គំនិតជាតិនិយម ជាគំនិតស្រឡាញ់ប្រទេសជាតិរបស់ខ្លួន ស្រឡាញ់ជនជាតិ ស្រឡាញ់ទឹកដី ស្រឡាញ់ប្រវត្តិសាស្ត្រ ស្រឡាញ់វប្បធម៌ទាំងអស់របស់ជាតិ ទោះបីជាសម្បត្តិវប្បធម៌លទ្ធកម្មក្តី សម្បត្តិវប្បធម៌ធម្មជាតិក្តី ប៉ុន្តែគំនិតជាតិនិយមសង្កត់លើការកសាងដើម្បីឲ្យ សម្បត្តិវប្បធម៌ទាំងអស់បានលូតលាស់ឡើង ព្រមទាំងមានគំនិតកែទម្រង់ ឬគំនិតបដិវត្តន៍ឆ្ពោះទៅរកគោលដៅរីកចម្រើនទៀតផង ដើម្បីឲ្យប្រទេសរបស់ខ្លួនមានល្បឿនស្របតាមចង្វាក់សកលលោកដែលកំពុងបិតនៅក្នុងសតវត្ស នៃល្បឿន ។

- គំនិតមាតុភូមិនិយម ជាគំនិតស្រឡាញ់ប្រទេសជាតិដែរ ព្រោះប្រទេសជាតិជាស្រុកកំណើតបង្កើតសរីរៈ និងព្រលឹង ស្រឡាញ់ព្រំដែនទឹកដី ស្រឡាញ់អាកាសធាតុ ស្រឡាញ់វាលស្រែ ស្រះត្រពាំង ទន្លេ សមុទ្រ ឆ្នេរខ្សាច់ ដោយជាប់ជំពាក់ នឹងអនុស្សាវរីយមុនមក ប៉ុន្តែគំនិតមាតុភូមិនិយមពុំសង្កត់លើការកសាងប្រទេសទេ គឺសង្កត់លើសញ្ចេតនាជាប់ជំពាក់ ស្រណោះអាលោះអាល័យមិនចង់ឃ្លាត មិនចង់ឲ្យគេដណ្តើមយក ។

តាមការអធិប្បាយអំពីគំនិតជាតិនិយម និងគំនិតមាតុភូមិនិយម យើងអាចកត់សំគាល់បាន

ថា សម្បត្តិវប្បធម៌លទ្ធកម្មអាចបណ្តុះគំនិតជាតិនិយមច្រើនជាង ព្រោះសម្បត្តិវប្បធម៌លទ្ធកម្មកើតមកពីការកសាង ស្របគ្នានឹងការកសាងក្នុងគំនិតជាតិនិយម ។ ចំណែកឯសម្បត្តិវប្បធម៌ធម្មជាតិបណ្តុះគំនិតមាតុភូមិនិយមច្រើនជាង ព្រោះគំនិតមាតុភូមិនិយមសង្កត់លើសញ្ចេតនាជាប់ជំពាក់ចំពោះសម្បត្តិវប្បធម៌ធម្មជាតិផ្សេង ៗ ដែលមានរួចមកហើយ ប៉ុន្តែពុំសង្កត់លើការកសាងទេ គឺនិយមអ្វី ៗ ដែលបិតនៅដដែល ៗ ពោលឲ្យខ្លីទៅគំនិតជាតិនិយម មានទំនោរទៅរកគំនិតចម្រើននិយម ឯគំនិតមាតុភូមិនិយមមានទំនោរទៅរកគំនិតថែរក្សានិយម ឬអភិរក្សនិយម ។

## បញ្ចប់សេចក្តី :

សរុបសេចក្តីទៅ ការអធិប្បាយរួចមកហើយបង្ហាញឲ្យឃើញថា សម្បត្តិវប្បធម៌លទ្ធកម្ម បណ្តុះគំនិតជាតិនិយម ឯសម្បត្តិវប្បធម៌ធម្មជាតិ បណ្តុះគំនិតមាតុភូមិនិយម បានសេចក្តីថា សម្បត្តិវប្បធម៌ទាំងពីរយ៉ាងនេះបណ្តុះគំនិតជាតិនិយមផង និងគំនិតមាតុភូមិនិយមផង ។ ហេតុនេះ យើងជាខ្មែរត្រូវទ្រទ្រង់ថែរក្សា បណ្តុះបណ្តាលសម្បត្តិវប្បធម៌ជាតិ ប៉ុន្តែមិនត្រូវបណ្តុះបណ្តាល វប្បធម៌ហួតដល់ទៅស្អប់សម្បត្តិវប្បធម៌ជនជាតិដទៃទេ ដែលអាចបណ្តាលឲ្យក្លាយទៅជាមានគំនិតជ្រុល និយម និងគំនិតជោរជាតិនិយម ។ ដរាបណាសម្បត្តិវប្បធម៌ទាំងនេះរលត់រលាយបាត់បង់អស់ពី ទឹកដីខ្មែរទៅ ខ្មែរអស់ហើយគំនិតជាតិនិយម អស់ហើយគំនិតមាតុភូមិនិយម ព្រោះសម្បត្តិទាំង នេះជាមូលដ្ឋាននៃការអប់រំ និងបណ្តុះគំនិតស្រឡាញ់ជនជាតិខ្មែរ ពោលឲ្យចំទៅគឺសម្បត្តិវប្បធម៌ បណ្តុះគំនិតស្នេហាជាតិ ។ ទន្ទឹមនឹងការគាំពារសម្បត្តិវប្បធម៌ ដូចបានអធិប្បាយរួចមកហើយ គេ មិនត្រូវបំភ្លេចមនុស្សខ្មែរទេ ព្រោះមនុស្សខ្មែរជាសម្បត្តិវប្បធម៌ផង និងជាអ្នកការពារសម្បត្តិវប្ប ធម៌ដទៃទៀតផង ។ អាស្រ័យហេតុនេះ យើងប្រឆាំងដាច់ខាតនឹងសង្គ្រាមសព្វយ៉ាងដែលនាំឲ្យ វិនាសដល់សម្បត្តិវប្បធម៌ខ្មែរ និងនាំឲ្យស្លាប់បាត់បង់ជីវិតដល់ជនជាតិខ្មែរសូម្បីតែម្នាក់ ព្រោះ សម្បត្តិវប្បធម៌លទ្ធកម្មក្តី សម្បត្តិវប្បធម៌ធម្មជាតិក្តី រួមជាមួយនឹងមនុស្សខ្មែរដែលនៅគង់វង់រហូត មកដល់សព្វថ្ងៃនេះតំណាងដួងព្រលឹងខ្មែរពិតប្រាកដ ។

**ប្រធានទី៦ ៖**

***អ្វីខ្លះជាសម្បត្តិវប្បធម៌ខ្មែរ ?***

***តើត្រូវធ្វើដូចម្តេច ដើម្បីថែរក្សាសម្បត្តិវប្បធម៌ ?***

***ផ្តើមសេចក្តី***

ជនជាតិនីមួយៗ ដែលគេទទួលស្គាល់ថាត្រឹមត្រូវតាមច្បាប់លុះត្រាតែមានពលរដ្ឋ មានប្រទេសដែលមានព្រំដែនទឹកដីច្បាស់លាស់ មានប្រវត្តិសាស្ត្ររបស់ខ្លួន ជាពិសេស គឺមានវប្បធម៌ផ្ទាល់ខ្លួន ។ វប្បធម៌មានភស្តុតាងបិតនៅលើសម្បត្តិវប្បធម៌។ តើខ្មែរមាន វប្បធម៌ឬទេ ? អ្វីខ្លះជាសម្បត្តិវប្បធម៌ ? តើត្រូវធ្វើដូចម្តេច ដើម្បីថែរក្សាសម្បត្តិវប្បធម៌ ?

***តួសេចក្តី***

វប្បធម៌សំគាល់អ្វី ដែលផ្តល់ចំណេះចេះដឹងគ្រប់វិស័យទោះបីចេះដឹងតាមផ្លូវកាយ ផ្លូវចិត្ត ផ្លូវបញ្ញា ផ្លូវបញ្ញា ផ្លូវសម្ភារៈដែលមានក្នុងលោកយើងនេះក្តីបរលោកក្តី ។ សម្បត្តិវប្បធម៌សំគាល់ កេរ្តិ៍ដំណែលទាំងឡាយដែលផ្តល់ចំណេះដឹងក្នុងវិស័យអក្សរសាស្ត្រក្តី វិទ្យាសាស្ត្រក្តី តិចនិច ជំនឿ សាសនា សិល្បៈ ...

គេនិយមចែកវប្បធម៌ជាពីផ្នែកគឺ សម្បត្តិវប្បធម៌លទ្ធកម្ម និង សម្បត្តិវប្បធម៌ ធម្មជាតិ៖

*១- សម្បត្តិវប្បធម៌លទ្ធកម្ម*

**ផ្នែកអក្សរសាស្ត្រ**

សម្បត្តិវប្បធម៌ខ្មែរមាន :

- សរសេរលើស្បែកសត្វនៅសម័យហ្វូណន់ ពីសតវត្សទី ១ ដល់ទី ២

- សរសេរលើបន្ទះក្តារ ពីសតវត្សទី២ ដល់ ទី ៣
- សរសេរលើសិលាចារឹកនៅ វ៉ូកាញ់ ខេត្ត ញ៉ាត្រាង វៀតណាមខាងត្បូង នាសតវត្សទី៣
- សិលាចារឹក អ្នកតាដំបងដែក ខេត្ត តាកែវ សតវត្សទី៦
- សិលាចារឹក ប្រាសាទប្រាំល្វែងនៅកម្ពុជាក្រោម សតវត្សទី៦
- សិលាចារឹក ប្រាសាទតាព្រហ្មទន្លេបាទី ខេត្ត តាកែវ សតវត្សទី៦
- សិលាចារឹក សម័យអង្គរ ពីសតវត្សទី៩ ដល់ ១៣
- សព្វថ្ងៃនេះ យើងមានសាស្ត្រាស្លឹករឹត និង សៀវភៅល្អៗ បោះពុម្ពយ៉ាងច្រើនរាប់ពុំអស់ ។

## ផ្នែកវិទ្យាសាស្ត្រ

សម្បត្តិវប្បធម៌ខ្មែរផ្នែកនេះពុំមានអ្វីជាដុំកំភួនទេ ព្រោះខ្មែរមើលជំងឺដោយឫសឈើវល្លិឈើ មើមឈើ សត្វស្រុក សត្វព្រៃ និងមន្តអាគមខ្លះ យកតាមគម្ពីរវេទ ប៉ុន្តែខ្មែរចេះគន់គូរដំណើរគោចរព្រះអាទិត្យ ព្រះច័ន្ទ ដូចជាគន់គូរសូរ្យគ្រាស ចន្ទគ្រាស ... បែបតារាវិទ្យា ។ ឯវិទ្យាសាស្ត្រសព្វថ្ងៃជាឥទ្ធិពលរបស់ពួកអឺរ៉ុប ។

## ផ្នែកតិចនិច

ខ្មែរមានសិប្បកម្ម ដូចជាចេះធ្វើកញ្ច្រែង ត្រក់ បង្គិ អង្រុត គោក តុ ទូ រទេះគោ និងរបស់ប្រើប្រាស់ផ្សេង ៗ ទៀតសម្រាប់សេចក្តីត្រូវការក្នុងគ្រួសារ ។ ខ្មែរស្លដែកតាំងពីមុនសម័យអង្គរ ចេះលាយលោហ:ធាតុនៅសតវត្សទី១១ ដូចបដិមា ព្រះនរាយណ៍ផ្ទុំ ធ្វើពីសំរិទ្ធិសបានមួយចំហៀតខ្លួននៅបារាយណ៍ខាងលិច យកមកតំកល់ទុកនៅ សារមន្ទីរជាតិសព្វថ្ងៃ ។

## ផ្នែកជំនឿ

ខ្មែរមានទំនៀមទំលាប់ចូលម្លប់ចំពោះកូនស្រី ឯកូនប្រុសត្រូវទៅបួសមុនប្រកបកិច្ចការផ្សេង ៗ ដើម្បីសងគុណឪពុកម្តាយតាមឥទ្ធិពលនៃរឿង សុបិនកុមារ ។ ខ្មែរមានប្រពៃណីប្រជាប្រិយ ដូចជាប្រណាំងទូក អាពាហ៍ពិពាហ៍ ត្រុតសុំភ្លៀងជំនឿហោរា ។ ខ្មែរមានប្រពៃណីសាសនា ដូចជា បុណ្យភ្ជុំបិណ្ឌ កឋិន បុណ្យផ្កា បំបួសនាគ សំពះព្រះខែ... ។

## ផ្នែកសិល្បៈ

ខ្មែរមានរបាំជាច្រើនដូចជារបាំភួងផ្កា ផ្សំនឹងតន្ត្រីយ៉ាងច្រើន ។

ខ្មែរមាន រនាតឯក រនាតដែក រនាតធុង ទ្រខ្មែរ ទ្រសោ ទ្រអ៊ូ ទ្រឆេ តាខេ ខ្លុយ ស្គរ សំភោរ ឬ ស្គរមុខពីរ ប៉ីកែវ ប៉ីបបុស ប៉ីអ ប៉ីពក ស្រឡៃ គងធំ គងតូច ចាប៉ី ឆៃយ៉ាំ ក្រាប សាដៀវ...។ ខ្មែរមានល្ខោននិយាយ ល្ខោនបាសាក់ ល្ខោនខោល ល្ខោនត្រាប់ ណាំងស្បែក យីកេ និង របាំសកម្ម ( សូមពិនិត្យមើលក្រដាស់ប្រាក់ ៥០០រៀល រូបក្អម ) ។ ឆៃយ៉ាំច្រើនលេងនៅចន្លោះឆាកល្ខោននីមួយ ៗ ដើម្បីបង្កើតបរិយាកាសរីករាយ ម៉្យាងទៀត គេច្រើនយកឆៃយ៉ាំជាមធ្យោបាយទាក់ទាញសប្បុរសជន ឲ្យចូលបច្ច័យជាសទ្ធាជ្រះថ្លាពេលបុណ្យផ្កា បុណ្យកឋិន បុណ្យបំបួស ។

ខ្មែរមានទំលាប់មួយយ៉ាងសំខាន់គឺ ខ្មែរចូលចិត្តឆ្លាក់ ហើយឆ្លាក់តាំងពីជញ្ជាំងប្រាសាទ ខ្លោងទ្វារ ហោជាងផ្តែបង្កាន់ដៃ របូតឯលជណ្តើរ ព្រោះខ្មែរពុំចូលចិត្តផ្ទៃទំនេរ ជាការបញ្ជាក់ថា ខ្មែរឧស្សាហ៍ ប៉ុន្តែផ្នត់គំនិតខ្មែរបែរជានិយម មនុស្សខ្ជិលជាងមនុស្សឧស្សាហ៍ (១) ។

ខ្មែរមានស្ថាបត្យកម្មយ៉ាងច្រើន បានកសាងជាង ២០០ ប្រាសាទសម្រាប់ឧទ្ទិសទេវសាសនា ។ ស្ថាបត្យកម្មចែកតាមរចនាបថ ទាំង១២ ៖

- រចនាបថសំបូរ
- រចនាបថព្រៃក្មេង
- រចនាបថកំពង់ព្រះ
- រចនាបថគូលែន
- រចនាបថព្រះគោ
- រចនាបថបាខែង
- រចនាបថកោះកេរ
- រចនាបថបន្ទាយស្រី
- រចនាបថឃ្លាំង
- រចនាបថបាពួន
- រចនាបថអង្គរវត្ត
- រចនាបថបាយ័ន

ការតុបតែងខ្លួនរបស់ស្ត្រីខ្មែរគឺលាបធ្មេញឲ្យខ្មៅ លាបម្រក្សណ៍ និងប្រេងដូងដើម្បីឲ្យបានរលោង ។ ការអនុវត្តចាប់ផ្តើមក្រោយពេលចូលម្លប់ ឬក្រោយអាពាហ៍ពិពាហ៍ ។ ខ្មែរនិយមធ្មេញខ្មៅតាំងពីសម័យមុនអង្គរមកម្លេះ ហើយសព្វថ្ងៃនេះខ្មែរនៅនិយមខ្លះដែរ ដូចជាស៊ីស្លាម្លូដើម្បីឲ្យ បានធ្មេញខ្មៅ ពេលក្រោយអាពាហ៍ពិពាហ៍ ចំពោះគ្រួសារស្រែចំការ ។

នៅទីក្រុង ការនិយមស៊ីស្លាម្ធូមានចំនួនតិចណាស់ ប៉ុន្តែនៅមានជីវិតនៅឡើយ ។

រួមសេចក្តីមក ការអធិប្បាយខាងលើនេះសុទ្ធសឹងជាសម្បត្តិវប្បធម៌លទ្ធកម្មដែល ដែលជាសម្បត្តិមនុស្សកសាងឡើង មនុស្សខំសន្សំបន្តិចម្តង ៗ ប្រមូលពីនេះបន្តិចពីនោះបន្តិចកែច្នៃ ឲ្យបានជាសម្បត្តិវប្បធម៌ឡើង ។ គេត្រូវបញ្ចូលសម្បត្តិវប្បធម៌ធម្មជាតិផងទៀត ។

## ២-សម្បត្តិវប្បធម៌ធម្មជាតិ

*អ្វីខ្លះជាសម្បត្តិវប្បធម៌ធម្មជាតិរបស់ខ្មែរ ?*

ដែលហៅថាសម្បត្តិវប្បធម៌ធម្មជាតិរបស់ជនជាតិនីមួយ ៗ គឺជាភោគទ្រព្យ និងជាអ្វីទាំងអស់ទោះបីរូបីក្តី អរូបីក្តី ដែលកើតតាមធម្មជាតិមក ផ្ទុយពីសម្បត្តិវប្បធម៌លទ្ធកម្មដែលមនុស្សកសាងបង្កើតឲ្យមានឡើង សម្បត្តិវប្បធម៌ធម្មជាតិរបស់ខ្មែរមានច្រើន :

- ព្រំដែនទឹកដីខ្មែរ
- សមុទ្រខ្មែរ
- ទន្លេ ស្ទឹង បឹងបួ ស្រះ ត្រពាំងរបស់ខ្មែរ
- ភ្នំទាំងឡាយរបស់ខ្មែរ ដូចជាភ្នំដងរែក ភ្នំក្រវាញ ភ្នំគូលែន ភ្នំបូកគោ ភ្នំពកកវិល ភ្នំខ្មោច ភ្នំប្រុស ភ្នំស្រី ភ្នំជីសូរ ភ្នំស្រង់ ភ្នំពេជ្រនិល ភ្នំគីរីរម្យ ភ្នំស្រួច ភ្នំទំពរ ភ្នំក្រចៅ ភ្នំសំកុស ភ្នំធំ ភ្នំទឹកព្រិល ភ្នំសំពៅ ភ្នំថ្មកែស ភ្នំស្វាយ ភ្នំគីរីវង្ស ភ្នំក្រោម
- កោះរបស់ខ្មែរមានច្រើនដែរ ដូចជា កោះត្រល់ ( ត្រូវយួនខាងត្បូងប្លន់យក នៅ គ. ស ១៩៤៩ ) កោះទន្សាយ កោះត្បាល់ កោះពោធិ កោះអង្រ្គង កោះសេះ កោះថ្មី កោះស្រមោច កោះឫស្សី កោះតាគាវ កោះច្រឡុស កោះពស់ កោះកោងកាង កោះរុង កោះរុងសំឡឹម កោះឌុយកូន កោះសីណាល់ កោះកណ្តាល កោះស្ទាច់ កោះសាមិត កោះកុង កោះមូល
- ឆ្នេរខ្សាច់ខ្មែរមានឆ្នេរខ្សាច់កែប កំពង់សោម កំពង់សិលា
- រុក្ខជាតិ របស់ខ្មែរមានដើមត្នោត ដែលអាចមានអាយុ ជាងមួយរយឆ្នាំ ដើមដូង ដើមទូរេន ដើមកៅស៊ូ ដើមស្វាយ ដើមស្រូវ ... ដែលសុទ្ធសឹងជាសម្បត្តិវប្បធម៌ ផ្តល់សេដ្ឋកិច្ចឲ្យខ្មែរ
- ក្រៅពីនេះ ខ្មែរមានសត្វស្រុក សត្វព្រៃយ៉ាងច្រើនដែលខ្មែរអាចបញ្ជូនទៅលក់ នៅបរទេសទៀតផង ។

ចុះបើសម្បត្តិទាំងអស់នេះវិនាសហិនហោចអន្តរធានអស់ទៅដោយសារសង្គ្រាម ខ្មែរនឹងត្រូវបាត់បង់ព្រលឹងរបស់ខ្លួន រាប់បញ្ចូលជាព្រលឹងរូបីទៅជាមួយនឹងជនជាតិរបស់

ខ្លួន ។ តើគេធ្វើសង្គ្រាមសព្វថ្ងៃដើម្បីឲ្យតែបានឈ្នះ តាមអស្មិមានៈនៃបុគ្គលភាព ហើយគេមិនញញើតនឹងបំផ្លាញសម្បត្តិធម្មជាតិ តើផលប្រយោជន៍របស់អ្នកឈ្នះនៅត្រង់ណា ? តើជាទឹកចិត្តជាតិនិយម បំផ្លិចបំផ្លាញ ឬទឹកចិត្តជាតិនិយមកសាង ?

- សម្បត្តិវប្បធម៌ធម្មជាតិសំខាន់ជាងគេគឺ មនុស្សខ្មែរ ព្រោះមនុស្សខ្មែរនេះហើយជាអ្នកការពារសម្បត្តិវប្បធម៌ទាំងអស់ របស់ខ្មែរ មនុស្សខ្មែរតំណាងវប្បធម៌និង អរិយធម៌របស់ខ្មែរ ព្រោះនៅក្នុងខ្លួនមនុស្សខ្មែរមានព្រលឹងខ្មែរ នៅក្នុងព្រលឹងខ្មែរមានខ្លឹមខ្មែរ ។ ហេតុនេះ ត្រូវរក្សាមនុស្សខ្មែរឲ្យគង់វង់ ត្រូវជៀសវាងសង្គ្រាមសំលាប់ខ្មែរគ្នាឯង ។

ការបាត់បង់ជីវិតនៃពលរដ្ឋខ្មែរ គឺជាការវិនាសនៃសម្បត្តិវប្បធម៌ធម្មជាតិរបស់ខ្មែរ ក៏ដូចជាការវិនាសនៃព្រលឹងខ្មែរ ។

## *តើត្រូវធ្វើដូចម្តេចដើម្បីថែរក្សាសម្បត្តិវប្បធម៌ ?*

### ចំពោះសម្បត្តិវប្បធម៌លទ្ធកម្ម :

- គួរកសាងសិមិទ្ធិឲ្យបានច្រើនទោះបីក្នុងវិស័យ អក្សរសាស្ត្រ វិទ្យាសាស្ត្រ តិចនិចសិល្បៈ ជំនឿ សាសនា ...
- បណ្តុះគំនិតស្នេហាវប្បធម៌ ប៉ុន្តែមិនត្រូវបណ្តុះគំនិតស្អប់វប្បធម៌ជាតិដទៃទេ ត្រូវទទួលស្គាល់វប្បធម៌បរទេសណាដែលអាចនាំមកនូវការចំរើនដល់ជនជាតិរបស់ខ្លួន ព្រមទាំងចៀសវាងការអួតអាងវប្បធម៌ជាតិរបស់ខ្លួនហួសហេតុ ។
- ផ្សាយវប្បធម៌ជាតិ

ចំពោះសម្បត្តិវប្បធម៌ធម្មជាតិ

- ត្រូវថែរក្សារុក្ខជាតិ ព្រៃឈើ សត្វស្រុកសត្វព្រៃកុំឲ្យវិនាស ហិនហោចឥតប្រយោជន៍
- កុំសំលាប់ខ្មែរគ្នាឯងផុយពេក ប៉ុន្តែមិនត្រូវអត់ឱនដល់អ្នកសំលាប់ជីវិតគេទេ ដើម្បីចៀសវាងកុំឲ្យអ្នកក្រោយយកគំរាប់តាម ។ ការសំលាប់ខ្មែរគ្នាឯងគឺជាគុរម្នាន់ របស់ប្រទេសជិតខាង ព្រោះកាលណាប្រជាជនខ្មែរកាន់តែមានចំនួនតិចទៅ ៗ យើងនឹងក្លាយទៅជាជនជាតិភាគតិចដូចមានជាឧទាហរណ៍ នៅកម្ពុជាក្រោមសព្វថ្ងៃ ។ សភាបារាំងចុះហត្ថលេខានៅថ្ងៃទី ២១ ឧសភា ១៩៤៩ ប្រគល់ទឹកដីកម្ពុជាក្រោម ឲ្យទៅយួនខាងត្បូងក៏ព្រោះតែឃើញខ្មែរពលរដ្ឋខ្មែរ នៅកម្ពុជាក្រោមមានចំនួនតិចជាងយួនច្រើនពេក ។ នេះជាកល្បិចរបស់យួនដែល បោកប្រាសខ្មែរឲ្យរត់ពួនពេលបារាំងទៅពិនិត្យមើលដល់ទីកន្លែង ។ គួរកុំឲ្យព្រឹត្តិការណ៍បែបនេះកើតមានឡើងម្តងទៀត ប៉ុន្តែព្រឹត្តិការណ៍នេះកំពុងលេចរូបរាង

ឡើងវិញទៀតហើយ ។ បើខ្មែរខ្វះសមត្ថភាពការពារទឹកដី ទឹកដីត្រូវតែរលាយ ។ ***ខ្មែរបាក់ស្បាតត្រង់ខ្មែរមិនប៉ាននិយាយការពិតឃើញបែបនេះទៅនិយាយបែបនោះ ឃើញបែបនោះទៅនិយាយបែបនេះ*** ។

*( បើដឹងថាខ្វះសមត្ថភាពហើយ ដើរចេញជាការប្រសើរ យ៉ាងហោចណាស់ ...* )

## ប្រធានទី៧៖

តើអរិយធម៌ឥណ្ឌាកាត់ឡែអរិយធម៌ខ្មែរ ឬ អរិយធម៌ខ្មែរកាត់ឡែអរិយធម៌ឥណ្ឌា ?

ពន្យល់ ពិភាក្សា និង ឧទាហរណ៍ ។

***ផ្ដើមសេចក្ដី*** :

ប្រជាពលរដ្ឋនីមួយ ៗ ដែលប្រមូលផ្ដុំគ្នាជាជនជាតិមួយបាន លុះត្រាតែមានប្រទេសមួយដែលមាព្រំដែនទឹកដីច្បាស់លាស់រួមជាមួយនឹងព្រលឹងនៃជនជាតិនោះក្រោមរបបគ្រប់គ្រងមួយដូចគ្នា ប្រពៃណីដូចគ្នាជំនឿសាសនាដូចគ្នា មានមនោគមន៍ របៀបរៀបចំសង្គមដូចគ្នា រួមបានជាអរិយធម៌របស់ជនជាតិនោះប៉ុន្តែអរិយធម៌របស់ជនជាតិនីមួយ ៗ រមែងទទួលឥទ្ធិពល ពីប្រទេសដទៃដែលមានកម្លាំងខ្លាំងជាង ទើបមតិមួយចោទសួរថា តើអរិយធម៌ឥណ្ឌាកាឡៃអរិយធម៌ខ្មែរ ឬ អរិយធម៌ខ្មែរកាឡៃអរិយធម៌ឥណ្ឌា ?

***តួសេចក្ដី*** :

ពន្យល់ពាក្យអរិយធម៌

តាមន័យទូទៅ អរិយធម៌សំគាល់មែកធាងទាំងឡាយក្នុងសង្គម ដែលមានលក្ខណៈជាជំនឿ សាសនា សិល្បៈ អក្សរសិល្ប៍ ប្រពៃណី របបគ្រប់គ្រង មនោគមន៍ សម្រាប់ធ្វើឲ្យរចនាសម្ព័ន្ធសង្គម មានទំនាក់ទំនងទៅវិញទៅមក ។

តាមន័យពិសេស អរិយធម៌សំគាល់ការជឿនលឿននៃប្រទេសនីមួយ ៗ ក្នុងវិស័យវប្បធម៌ និងសង្គមធម៌ ហើយដែលអាចបន្តជីវិតទៅសម័យកាលខាងមុខទៀត ។

មតិទី១ : អរិយធម៌ឥណ្ឌាកាឡៃអរិយធម៌ខ្មែរ

អរិយធម៌ឥណ្ឌាចូលមកកាឡៃអរិយធម៌ខ្មែរ តាមរយៈពលរដ្ឋឥណ្ឌាម្នាក់ឈ្មោះ កៅណ្ឌិន្យ ប្រហែលនៅពាក់កណ្ដាលសតវត្សទី១ នៃ គ . ស ក្នុងរាជ្យព្រះនាងសោមា ឬ លិវយី ឬ នាងនាគ សម័យហ្វូណន់ ។ ទំនាក់ទំនងនេះពុំបញ្ជាក់ថា អរិយធម៌ខ្មែរ គឺអរិយធម៌ឥណ្ឌាទេ ព្រោះមានមតិខ្លះច្រើនភាន់ច្រឡំដោយស្មានថា ឥណ្ឌាជាបុរសរបស់ខ្មែរ ឬ ឥណ្ឌាជាខ្មែរដើម ។ តាមពិតឥណ្ឌា

ចូលមកដល់ប្រទេសខ្មែរសម័យហ្វូណន់ វត្តមាននៃប្រទេសខ្មែរមានរួចមកហើយ ឯអរិយធម៌ខ្មែរក៏មានរួចហើយដែរ ទ្រទ្រង់នូវការគ្រប់គ្រងមួយរបស់ខ្មែរ គឺ របបមាតាធិបតេយ្យ ។

តើអរិយធម៌ឥណ្ឌាបានកាឡៃអរិយធម៌ខ្មែរដូចម្ដេច ក្នុងវិស័យវប្បធម៌ និងសង្គមធម៌ ?

១/ ក្នុងវិស័យវប្បធម៌

ក/ ឥណ្ឌាបញ្ចូលជំនឿបូជាយញ្ញតាមលទ្ធិវេទ ដូចមានអធិប្បាយក្នុងគម្ពីរវេទទាំងបួន គឺ :

- ឫគវេទ : ផ្ដល់ជំនឿបន់ស្រន់ទេវតាក្នុងធម្មជាតិ
- យជុវេទ : បន់ស្រន់ទេវតាឋានលើ ឲ្យចុះមកជួយមនុស្សដែលទទួលរងគ្រោះដោយអំពើផ្សេង ៗ
- សាមវេទ : ផ្ដល់ជំនឿអប់រំមនុស្សឲ្យសិក្សាមន្តអាគមសម្រាប់ការពារខ្លួន ដូចក្បាច់គុណ ក្បាច់គុណដំបង ក្បាច់ក្រពើហា.........
- អថិវវេទ : ផ្ដល់ជំនឿឲ្យចេះការពារជំងឺផ្សេង ៗ ដូចស្ដោះពិសពស់ ចុក រាគ មួល លើករាសីរហូតដល់មន្តអាគមស្នេហ៍ សម្រាប់ព្យាបាលជំងឺស្នេហា ។

ខ/ បន្ទាប់ពីសម័យវេទ ខ្មែរបានកាន់សាសនាព្រាហ្មណ៍ដូចឥណ្ឌាដែរ ប៉ុន្តែខ្មែរបានកាន់សាសនាព្រះឥសូរ មុនតាំងពីពាក់កណ្ដាលសតវត្សទី១ រហូតដល់សតវត្សទី១០ ។ ពីសតវត្សទី១០ ដល់ទី ១១ ខ្មែរបានកាន់សាសនា ព្រះវិស្ណុ ឬព្រះនារាយណ៍ ព្រោះសាសនានេះជួយមនុស្សច្រើនប្រការឲ្យបានធូរស្បើយពីទុក្ខសោក ។ ពីសតវត្សទី១២ ដល់ទី១៤ ខ្មែរកាន់ពុទ្ធសាសនាមហាយាន ចំណែកឯលទ្ធិហិនយានជាឥទ្ធិពលរបស់សៀមព្រោះសៀមបង្ខំខ្មែរឲ្យកាន់ហិនយានតាមឧបាយកលរបស់ព្រះបាទឥន្ទ្រវរ្ម័នទី៣ គិតយ៉ាងណាឲ្យតែបានសោយរាជ្យជាការបញ្ជាក់ថា ខ្មែរឋិតនៅក្រោមចំណុះសៀម ហើយចាប់តាំងពីពេលនោះមក សម័យមហានគរ
របស់ខ្មែរត្រូវស្រុតចុះឥទ្ធិពលរបស់ខ្លួនមកដល់សម័យបាក់ស្បាត ដើម្បីប្រលោមខ្មែរឲ្យចូលក្នុងពូជអំបូរថៃ ជាការងាយស្រួលប្រមូលយកទឹកដីខ្មែរ តាមនយោបាយប្រមូលជនជាតិរបស់ថៃរៀបចំឡើងដោយហ្លួងវិជិត្រវ៉ាតកាន ។

គ/ ប្រពៃណីរំលាយសព ដោយយកសពទៅដុត ហើយរើសយកធាតុមកទុកក្នុងថូមួយតំណាងព្រលឹងនៃអ្នកស្លាប់ ចំណែកឯការរំលាយសព ខ្មែរបុរាណគឺគេយកសពទៅទីកន្លែងមួយសំរាប់ត្មាតស៊ី ឬបោះចោលក្នុងទឹកឲ្យត្រីស៊ី ឯការកប់ខ្មោចឥទ្ធិពលរបស់ចិន ។

ឃ/ ទ្រឹស្ដីគម្ពីរវេទបានចែងថា មនុស្សត្រូវរស់នៅដោយចែកជាវណ្ណៈទើបអាចសំគាល់មនុស្សល្អ ឬអាក្រក់ ។

ង/ ចំពោះភាសានិងអក្សរ ខ្មែរបានទទួលឥទ្ធិពលច្រើនពីឥណ្ឌា ក្នុងករណីដែលខ្មែរខ្វះពាក្យប្រើប្រាស ដូចជាពាក្យ សុខ ទុក្ខ យក្ស សីលធម៌ ... នៅមានសាខានៃវប្បធម៌ច្រើនទៀតក្នុងវិស័យទ្រឹស្ដី ចិត្តគំនិត ដែលឥណ្ឌាកាឡៃវប្បធម៌ខ្មែរ ។

### ២/ ក្នុងវិស័យសង្គមធម៌

សង្គមធម៌សង្កត់ទៅលើច្រើស្ដីរបស់សង្គម និងការរៀបចំសង្គម ឲ្យមានទំនាក់ទំនងទៅវិញទៅមកតាំងពីវិស័យសេដ្ឋកិច្ច នយោបាយ សង្គមកិច្ច ជីវភាពទូទៅ សន្តិសុខជាដើម:

- ក្នុងវិស័យសេដ្ឋកិច្ច ខ្មែរធ្វើកសិកម្មប៉ុន្តែគេហាមប្រាមមិនឲ្យសំលាប់សត្វដែល ជាបទបញ្ញត្តិក្នុងពុទ្ធសាសនា ។
- ក្នុងផ្នែកនយោបាយ ខ្មែរពុំចេះធ្វើនយោបាយទេ ក្រៅពីគោរពបូជាសាសនា ហើយយកសាសនាជំនួសនយោបាយ បើសាសនាពុំត្រូវគ្នា គឺឈប់រាប់រកគ្នារហូតដល់យក សង្គ្រាមផ្ទាល់ខ្លួនដាក់ជា សង្គ្រាមសាសនា ។
- ក្នុងជីវភាពរស់នៅ ខ្មែរនិយមធ្វើបុណ្យ និងនិយមបួស បួសរួចហើយទើបប្រកបជីវភាព ។
- ក្នុងផ្នែកសន្តិសុខ ខ្មែរនិយមការសន្តោសតាមបែបពុទ្ធសាសនា ប៉ុន្តែតាមខ្មែរបុរាណ អ្នកប្រព្រឹត្តបទល្មើស ត្រូវមានទោសពុំនិយមការសន្តោសទេ ។

### មតិទី២ : អរិយធម៌ខ្មែរកាឡៃអរិយធម៌ឥណ្ឌា

\+ ក្នុងវិស័យវប្បធម៌

- ជំនឿបូជាយញ្ញដែលឥណ្ឌាតំរូវឲ្យអនុវត្តរហូត ដល់សំលាប់ជីវិតមនុស្ស ខ្មែរបានកាឡៃពីបូជាយញ្ញនេះ ឲ្យនៅត្រឹមតែការសែនព្រេន និងសំលាប់ជីវិតសត្វជំនួសជីវិតមនុស្ស ។
- ព្រះឥសូរ ព្រះវិស្ណុដែលជាព្រះអាទិទេពឥតកំហុស ខ្មែរបានកាឡៃឲ្យអាទិទេពទាំងនេះ បែរជាមានកំហុសខ្លះក្នុងសាសនារបស់ខ្មែរ តារយ:រឿងរាមកេរ្តិ៍ខ្មែរ ។
- បដិមាតំណាងព្រះឥសូរ ព្រះវិស្ណុ ព្រះពុទ្ធដែលមានមុខមាត់ជាឥណ្ឌា នៅប្រទេសឥណ្ឌា ខ្មែរបានកាឡៃឲ្យមានមុខមាត់បែបខ្មែរវិញ ដូចជាបដិមាលោកេស្វរ: ព្រះពោធិសត្វនៃពុទ្ធសាសនា មហាយានកើតនៅតំបន់កស្មីរ ( Cachemire ) សតវត្សទី២ នៃ គ. ស មានមុខមាត់ជាឥណ្ឌាសុទ្ធសាធ ប៉ុន្តែព្រះបាទជ័យវរ្ម័នទី៧ បានឲ្យគេច្នៃមុខមាត់លោកេស្វរ:នៅប្រទេសខ្មែរឲ្យមានរូបរាងប្រហែលគ្នា នឹងព្រះភក្ត្រព្រះអង្គដែរ ដើម្បីបញ្ជាក់ឲ្យដឹងថាព្រះអង្គជាអ្នកផ្ដើមកាន់សាសនាមហាយានមុនគេនៅប្រទេសខ្មែរ ( ប្រហែលគ្នា នឹងលទ្ធិទេវរាជដែរ ) ។
- ខ្មែរសម័យហ្វូណន់ បានធ្វើឲ្យឥណ្ឌាគោរព របបមាតាធិបតេយ្យដូចជាពេលរៀបអភិសេកនាងសោមា ខ្មែរបានតំរូវឲ្យកៅណ្ឌិន្យ តោងស្បៃដើរតាមក្រោយនាងសោមា ហើយពិធីនេះបានធ្លាក់ឡើងវិញនៅប្រាសាទយ័ន ។
- ព្រះពុទ្ធសាសនា នៅស្រុកខ្មែរមានលក្ខណ:ប្លែកគ្នាពីពុទ្ធសាសនានៅឥណ្ឌា និង នៅសិរីលង្កា ភាគច្រើននៃអ្នកកាន់ពុទ្ធសាសនា ខ្មែរច្រើនយកសាសនាជាមធ្យោបាយសំរាប់ដោះស្រាយបញ្ហាជីវភាព បញ្ហាក្រពះ បញ្ហាសិក្សា ព្រោះនៅគ្រូហស្ថពិបាករៀនសូត្រ ហើយខ្វះខាតប្រាក់
កាសផង ឯខ្លះទៀតអាយុច្រើនហួសពុំមានសិទ្ធិចូលរៀនសូត្រតាមធម្មតា ។ ពេលបួសរៀន

ព្រះសង្ឃមានលទ្ធភាពបង្កើនចំណេះវិជ្ជារហូតដល់បានចេះដឹងច្រើនហើយ ក៏លាចាកសិក្ខាបទ ដើម្បីកសាងជីវភាពដូចគេឯង ។

សព្វថ្ងៃនេះ ការបួសរៀនក្នុងសំណាក់ពុទ្ធសាសនាជាមធ្យោបាយមួយដ៏ប្រសើរដើម្បីចៀសវាងកុំឲ្យគេចាប់ធ្វើទាហាន ។ ភាគតិចណាស់នៃអ្នកកាន់ពុទ្ធសាសនាខ្មែរដែលគោរពតាមឱវាទព្រះពុទ្ធសាសនាទាំងស្រុង ។

ក្នុងផ្នែកនយោបាយ ខ្មែរយល់ថាសាសនា គ្រាន់តែជាឈ្នាន់ដើម្បីទៅកាន់អំណាច ព្រោះខ្មែរយល់នយោបាយពុំច្បាស់លាស់ ។ លុះបានអំណាចហើយ គេច្រើនយកអំណាច ធ្វើជាឈ្នាន់ស្វែងរកប្រយោជន៍ ហើយប្រយោជន៍ភាគច្រើន ជាប្រយោជន៍ផ្ទាល់ខ្លួន ។

ចំពោះការរស់នៅ ខ្មែរបានកាឡៃវណ្ណៈទាំងបួនរបស់ឥណ្ឌាឲ្យនៅត្រឹមតែវណ្ណៈពីរ គឺ អ្នកមាន និងអ្នកក្រ ។ វណ្ណៈទាំងពីរអាចរលាយចូលគ្នាបានពេលគឺអ្នកក្រអាចខំរកស៊ីទៅជាអ្នកមាន ឯអ្នកមានបើមិនខំរកស៊ី ឬមានគ្រោះថ្នាក់ចៃដន្យកើតឡើងដូចជាភ្លើងឆេះផ្ទះទ្រព្យសម្បត្តិត្រូវលិចលង់ ក្នុងទឹក ពេលទឹកជំនន់ ឬលិចសំពៅ លិចកប៉ាល់ អ្នកមានអាចធ្លាក់ខ្លួនទៅជាអ្នកក្រ ។

ក្នុងវិស័យសេដ្ឋកិច្ច ឥណ្ឌាពុំមានលក្ខណៈច្បាស់លាស់ទេ ។ ឥណ្ឌាសម័យបុរាណច្រើនលក់វត្ថុធាតុដើម ឯខ្មែរក៏ចូលចិត្តលក់វត្ថុធាតុដើមដែរ ពុំសូវប្រសព្វធ្វើឈ្មួញកណ្តាលដូចចិនទេ ។

ក្នុងផ្នែកសង្គមកិច្ចនិងការរៀបចំសង្គមទូទៅ ខ្មែរច្រើនទទួលឥទ្ធិពលអរិយធម៌បច្ចិមប្រទេស ។

ការសង្កេតទូទៅ ទំនាក់ទំនងរវាងខ្មែរ និងឥណ្ឌាច្រើនមាននៅក្នុងវិស័យវប្បធម៌ ឯវិស័យសង្គមធម៌របស់ឥណ្ឌា ពុំសូវមានឥទ្ធិពលមកលើសង្គមខ្មែរទេព្រោះឥណ្ឌាពុំសូវយល់ទ្រឹស្តីសង្គម ។

ពិភាក្សា :

ការទទួលឥទ្ធិពលរបស់ប្រទេសដែលមានអរិយធម៌ខ្ពស់ជាង ជាករណីធម្មតារបស់ប្រទេសទូទៅក្នុងសកលលោក ហើយពុំអាចចាត់ទុកជាភាពអន់ថយនៃប្រទេសដែលទទួលឥទ្ធិពលពីគេនោះឡើយ សូម្បីតែឥណ្ឌាសោតក៏ទទួលអរិយធម៌ពីពួកអារ្យ៉ង ( les aryens )ដែលភាគ
ច្រើនមកពីតំបន់សមុទ្រ **មេឌីទែរ៉ាណេ** និងតំបន់ **មេសូប៉ូតាមី** ប្រហែលសតវត្សទី១២ មុន គ. ស ហើយនៅសតវត្សទី១៩ ឥណ្ឌាធ្លាប់នៅក្រោមអរិយធម៌របស់អង់គ្លេស ឯអង់គ្លេសក៏ធ្លាប់នៅក្រោមអរិយធម៌បារាំងកាលសតវត្សទី១១ ជំនាន់ស្តេចបារាំងឈ្មោះ(Guillaume le Conquérant ) ។

បញ្ចប់សេចក្តី :

រួមសេចក្តីមក ឥណ្ឌាកាឡៃអរិយធម៌ខ្មែរ និង ខ្មែរកាឡៃអរិយធម៌ឥណ្ឌា ជាករណីធម្មតារបស់ប្រទេសក្នុងសកលលោក ប៉ុន្តែ អរិយធម៌ជនជាតិណាមួយដែលមានព្រលឹងរបស់ខ្លួនពុំងាយ

នឹងទទួលការប្រែប្រួលតាមអរិយធម៌បរទេសបានឡើយ ប៉ុន្តែអរិយធម៌ទន់ខ្សោយត្រូវតែជំនួស ដោយអរិយធម៌ខ្លាំងជានិច្ចទប់ទល់ពុំបាន វិស័យដូចជាចរន្តទឹក ហើយក៏មិនត្រូវតូចចិត្ត នឹង
អរិយធម៌ដែលមានកម្លាំងខ្លាំងជាងនោះដែរ ។ អរិយធម៌ជនជាតិនីមួយ ៗ សុទ្ធសឹងកើតមកពីទំនាក់ទំនង រវាងអរិយធម៌របស់ជនជាតិដទៃទៀតជាដរាប ប៉ុន្តែជនជាតិនីមួយ ៗ រមែងមានអរិយធម៌ពិសេសរបស់ខ្លួនដែលគេហៅថា ព្រលឹងរបស់ជនជាតិនោះ ។

# ប្រធានទី៨៖

តើវិទ្យាសាស្ត្រអាចធ្វើឲ្យមនុស្ស មានសីលធម៌ ឬទេ ?

ពន្យល់ ពិភាក្សា និងឧទាហរណ៍

## ផ្តើមសេចក្តី

ការរស់នៅរបស់មនុស្សក្នុងសង្គមដឹកនាំមនុស្សឲ្យស្វែងរកការចំរើនលូតលាស់សំរាប់សេចក្តីត្រូវការរបស់មនុស្សផងគ្នា ទន្ទឹមគ្នានឹងការស្វែងរកសេចក្តីសុខរបស់មនុស្សដែរ ទើបមនុស្សខំស្វែងរកតំលៃសីលធម៌ផង និងខំបង្កើតវិទ្យាសាស្ត្រផង ។ តំលៃ សីលធម៌កើតមានឡើងអាស្រ័យលើការអនុវត្ត ។ ខ្លះគោរពតំលៃសីលធម៌ ខ្លះទៀតពុំគោរពតំលៃ សីលធម៌ទេ ទើបមានមតិចោទសួរឡើងថា តើវិទ្យាសាស្ត្រអាចឲ្យមនុស្សមានសីលធម៌ឬទេ ?

## តួសេចក្តី

វិទ្យាសាស្ត្រ និងសីលធម៌មានន័យដូចម្តេច ?

មុនដំបូង វិទ្យាសាស្ត្រសំគាល់ចំណេះវិជ្ជាទូទៅដែលមនុស្សត្រូវចេះដឹង និងចំណេះវិជ្ជាទាំងឡាយដែលកើតមកពីការស្រាវជ្រាវ ។ បន្ទាប់មក វិទ្យាសាស្ត្រសំគាល់មធ្យោបាយ សកម្មសំរាប់កែប្រែធម្មជាតិ និងត្រួតត្រាលើធម្មជាតិ មតិខ្លះថា វិទ្យាសាស្ត្រជាវិធីសំរាប់ស្វែងរកការពិតទៅវិញស្របតាមគំនិតវិទ្យាសាស្ត្រ ។

សីលធម៌សំគាល់ទ្រឹស្តី និង ពាក្យទូន្មានទាំងឡាយណាដែលដឹកនាំទៅរកផ្លូវល្អ និងជៀសវាងផ្លូវអាក្រក់ ជាពិសេសសីលធម៌ ច្រើនសំគាល់ទ្រឹស្តីសំរាប់អប់រំទាក់ទងទៅនឹងផ្លូវចិត្ត :

**មតិទី១ :** *វិទ្យាសាស្ត្រធ្វើឲ្យមនុស្សមានសីលធម៌ខ្លះ ?*

- ដឹកនាំមនុស្សឲ្យ ស្រឡាញ់ សច្ចភាព គឺស្រឡាញ់ការពិតជាទូទៅ
- ដឹកនាំមនុស្សឲ្យ បណ្តុះគំនិតពិចារណា មិនឲ្យមនុស្សជឿផ្តេសផ្តាស
- ដឹកនាំមនុស្ស មិនឲ្យលុះតាមដំបូន្មានអ្នកដទៃបានដោយងាយ
- ដឹកនាំមនុស្សឲ្យ ជឿលើអំពើរបស់ខ្លួន ច្រើនជាងជឿលើអាទិទេព
- ដឹកនាំមនុស្សឲ្យ លះបង់ប្រយោជន៍ផ្ទាល់ខ្លួន ព្រោះវិទ្យាសាស្ត្រឥតមានមាតុភូមិទេ ហើយមានគោលដៅដឹកនាំមនុស្សទាំងអស់ទៅរកសេចក្តីសុខ សុខតាមផ្លូវកាយ សុខតាមផ្លូវចិត្ត សុខតាមផ្លូវសម្ភារៈ ដូចការលូតលាស់នៃវិទ្យាសាស្ត្រសព្វថ្ងៃ អាចធ្វើឲ្យមនុស្សយកជ័យជំនះលើធម្មជាតិបានច្រើនមិនសូវចុះញ៉មធម្មជាតិ ។

**មតិទី២ :** *វិទ្យាសាស្ត្រពុំអាចធ្វើឲ្យមនុស្សមានសីលធម៌បានទេ*

- វិទ្យាសាស្ត្រ ជាមធ្យោបាយធ្វើឲ្យលូតលាស់ តាមផ្លូវសម្ភារៈដើម្បីស្វែងរកភោគទ្រព្យ បែរជាឲ្យមនុស្សមានមហិច្ឆតាលោភលន់ពុំចេះចប់ បានហើយចង់បានទៀត មានទ្រព្យសម្បត្តិច្រើនកាន់តែចង់បានច្រើនទៀត
- វិទ្យាសាស្ត្រ ជាមធ្យោបាយបំរើអ្នកមានជាងអ្នកក្រ
- វិទ្យាសាស្ត្រ ជាមធ្យោបាយសង្កត់សង្កិនអ្នកទន់ខ្សោយ គ្រប់ប្រភេទ ក្នុងសកលលោក ដូចជាសំដីរបស់លោក អាល់ប៊ែរ អាំងស្តាំង ( Albert Einstcin ) ថា « le progress scientifique menacc tragiquement l’ humanité » មានន័យថា ការចំរើននៃវិទ្យាសាស្ត្រ កំហែងគំរាមពិភពលោកគួរឲ្យតក់ស្លុត
- វិទ្យាសាស្ត្រ ជាអាវុធមុខពីរដែលអាចឲ្យមនុស្សរងគ្រោះច្រើនដោយសារតែ មនុស្សយកវិទ្យាសាស្ត្រ ទៅប្រើសំរាប់តែប្រយោជន៍ផ្ទាល់ខ្លួន ។

ពិភាក្សា :

វិទ្យាសាស្ត្រ អាចធ្វើឲ្យមនុស្សមានសីលធម៌ផង និងប្រាសចាកសីលធម៌ផង អាស្រ័យលើការប្រតិបត្តិឬការអនុវត្ត ។ បើយកវិទ្យាសាស្ត្រទៅប្រើសំរាប់សេចក្តីសុខសេចក្តីចំរើន សេចក្តីត្រូវការរបស់មនុស្សពិត ៗ ទើបវិទ្យាសាស្ត្រធ្វើឲ្យមនុស្សមានសីលធម៌ ។ ផ្ទុយទៅវិញបើយក
វិទ្យាសាស្ត្រទៅប្រើសំរាប់ប្រយោជន៍ផ្ទាល់ខ្លួនសំរាប់កំហែងគំរាមអ្នកទន់ខ្សោយ វិទ្យាសាស្ត្រនឹងក្លាយជាអាវុធប្រល័យលោក និងក្លាយទៅជាពិសពុល ប្រហារជីវិតមនុស្សជាតិ ដូចជាករណីដែលគេយកគ្រាប់បែកទៅប្រើសំរាប់ប្រហារជីវិតគូសត្រូវ ដើម្បីដោះស្រាយបញ្ហាដែលគេចង់បាន

ករណីគ្រូពេទ្យចិញ្ចឹមអ្នកជំងឺ ករណីអ្នកលក់ថ្នាំពេទ្យបន់ស្រន់ឲ្យមនុស្សឈឺច្រើន . . . សុទ្ធសឹងជាអំពើអមនុស្សធម៌ខ្លាំងណាស់ ក្បត់សីលធម៌មនុស្សលោក ក្បត់ពាក្យសំបថរបស់ខ្លួនពេលសិក្សាវិទ្យាសាស្ត្រគឺសំបថ ចំពោះអ៊ីប៉ូក្រាត ( scrment d'Heppocrate ) ដែលអប់រំមិនឲ្យគ្រូពេទ្យមានគំនិតជំនួញគ្របដណ្តប់លើគំនិតមនុស្សធម៌ ។

ដោយហេតុថា មានមនុស្សយកវិទ្យាសាស្ត្រទៅប្រើក្នុងផ្លូវខុសប្រាសចាកសីលធម៌បាត់បង់មនសិការទើបលោក រ៉ាប៊ីឡេ ( Rabelais ) អ្នកប្រាជ្ញបារាំង សតវត្សទី១២ បានប្រកាសជាសកលមានន័យថា « *វិទ្យាសាស្ត្រខ្វះមនសិការ ឬខ្វះសីលធម៌ ឬខ្វះការវិនិច្ឆ័យ នាំឲ្យវិនាសដល់ព្រលឹង ពោលគឺវិនាសដល់មនុស្សទូទៅ* » ។ អ្នកប្រាជ្ញខ្លះទៀតអស់សង្ឃឹមលើមហិច្ឆតា របស់មនុស្សដែលចង់បានហើយចង់បានទៀត មិនឈប់ឈរ ព្រោះមនុស្សជាខ្ញុំកញ្ជះនៃសភាវគតិរបស់ខ្លួន ឬ មនុស្សបថុជ្ជន មុខជាឆ្លៀតយកវិទ្យាសាស្ត្រទៅបង្កើនភោគទ្រព្យរបស់ខ្លួន ទើបលោក

រូស្សូ អ្នកប្រាជ្ញបារាំងសតវត្សទី១៨ បានប្រឆាំងជាដាច់ខាតនឹងការចំរើននៃវិទ្យាសាស្ត្រហើយរៀបចំមនុស្សឲ្យរស់នៅតាមបែបធម្មជាតិ វិញតាមរយៈស្នាដៃមួយរបស់លោកឈ្មោះ Emile ។

នៅសតវត្សទី២០ អ្នកប្រឆាំងនឹងវិទ្យាសាស្ត្រម្នាក់ទៀត ឈ្មោះលោក ហ្សង់ប៉ូលសាត្រ ( Jean Paul Sartre ) តាមរយៈស្នាដៃដទៃទៀតឈ្មោះស្ថានភាព ( situation 12-3 45-6-7-8 9…)

បើយើងស្រាវជ្រាវអតីតកាលនៅប្រទេសឥណ្ឌា សាសនាផ្តើមប្រឆាំងនឹងវិទ្យាសាស្ត្រមុនគេគឺសាសនាជេន ( Jainisme ) ព្រោះអ្នកកាន់សាសនានេះពុំព្រមប្រើប្រាស់វត្ថុទាំងឡាយដែលកើតឡើង ដោយវិទ្យាសាស្ត្រ ឬវត្ថុផលិតចេញពីឧស្សាហកម្ម ហើយយល់ព្រមប្រើប្រាស់ តែវត្ថុទាំងឡាយធ្វើដោយដៃ ព្រមទាំងហាមប្រាមមិនឲ្យឧបាសក និង ទេសចរណ៍ទាំងឡាយយកប្រដាប់ប្រដាផ្សេង ៗ ធ្វើដោយលោហធាតុ ចូលក្នុងព្រះវិហារជាដាច់ខាត។

*បញ្ចប់សេចក្តី :*

តាមការអធិប្បាយរួចមកហើយឃើញថា វិទ្យាសាស្ត្រអាចធ្វើឲ្យមនុស្សប្រកបដោយសីលធម៌ និងប្រាសចាកសីលធម៌ផង អាស្រ័យលើអ្នកប្រើប្រាស់វិទ្យាសាស្ត្រ ។ យើងពុំប្រឆាំងជាដាច់ខាតនឹងការចំរើននៃវិទ្យាសាស្ត្រទេ យើងយល់ព្រមទទួលវិទ្យាសាស្ត្រណាដែលដឹកនាំទៅរកការចំរើន ប្រកបដោយសីលធម៌ប៉ុន្តែយើងប្រឆាំងនឹងវិទ្យាសាស្ត្រដែលធ្វើឲ្យវិនាសហិនហោចដល់មនុស្សជាតិ ។

## ប្រធានទី៩៖

ហេតុអ្វីបានជាការស្រាវជ្រាវរកព្រលឹងជនជាតិណាមួយត្រូវជាប់ទាក់ទងទៅនឹងមូលដ្ឋានភូមិសាស្រ្ត និងប្រវត្តិការណ៍ ?
ចូរលើកយកករណីនៃការស្រាវជ្រាវរកព្រលឹងខ្មែរមកបញ្ជាក់

***ផ្តើមសេចក្តី:***

ការស្រាវជ្រាវរកព្រលឹងនៃជនជាតិណាមួយ ជាករណីមួយធំ ដែលត្រូវពឹងផ្អែកលើឯកសារត្រឹមត្រូវនិងច្បាស់លាស់ ព្រោះម្យ៉ាងទៀតយើងពុំស្គាល់មជ្ឈដ្ឋានដែលជនជាតិនោះរស់នៅ ពុំដឹងមានជីវិតឡើងពីសម័យណា ប៉ុន្តែដើម្បីឲ្យមានលក្ខណ:ជាជនជាតិមួយលុះត្រាតែគេចេះរស់នៅជា
សង្គមមានអង្គការ ច្បាប់ទំលាប់ ជំនឿសាសនា មនោគមន៍ របបគ្រប់គ្រងពោលគឺមានវប្បធម៌ និងអរិយធម៌របស់ខ្លួនទើបគេត្រូវស្គាល់មូលដ្ឋានភូមិសាស្រ្ត និងប្រវត្តិការណ៍ ។

តើការស្រាវជ្រាវរកព្រលឹងខ្មែរឋិតនៅក្នុងករណីណាខ្លះ ?

***តួសេចក្តី:***

កាលណាគេស្រាវជ្រាវរកព្រលឹងនៃជនជាតិណាមួយ គេត្រូវយល់ ថាព្រលឹងនៃជាតិនោះជាអ្វី ?

ការសិក្សាព្រលឹងជនជាតិណាមួយតំរូវឲ្យស្គាល់របស់មនុស្សនៃជនជាតិនោះជាអ្វី ?

ព្រលឹងអក្សរសិល្ប៍ជាអ្វី ? ទើបអាចយល់ព្រលឹងជនជាតិនីមួយ ៗ ។ ព្រលឹងរបស់មនុស្សសំគាល់នូវធាតុអរូបីម៉្យាងឋិតនៅជានិច្ចក្នុងសរីរៈរបស់បុគ្គល ហើយបញ្ជាឲ្យសរីរៈ ធ្វើតាមបំណងរបស់ខ្លួន ។ ព្រលឹងនេះជាសារជាតិដើមផ្តល់អំពើល្អឬ អាក្រក់ទៅលើសរីរៈ របស់បុគ្គល ។ ព្រលឹងនេះពុំផ្លាស់ប្តូរទេ ។ ពិតមែនតែសរីរៈត្រូវចាស់ទ្រុឌទ្រោម ប្រើការពុំកើតហើយប្រគល់ជូនធម្មជាតិវិញក៏ព្រលឹងនៅមានជីវិតអមតៈ ធ្វើដំណើរវិលវល់ ដើម្បីរកចាប់ភពថ្មីទៀត ។ មានកម្លាំងក្រៅខ្លួនជាច្រើនផ្តល់ឥទ្ធិពលទៅលើព្រលឹង ព្រលឹងអាច កាឡៃភាពដើមរបស់ខ្លួនខ្លះប៉ុន្តែនៅរក្សាខ្លឹមរបស់ខ្លួនជានិច្ច ។ ខ្លឹមសំគាល់ធាតុដែលមានសារៈសំខាន់ជាងគេហើយពុំចេះប្រែប្រួលដូចជាខ្លឹមរបស់ ស្ករគឺផ្អែម ខ្លឹមរបស់អំបិលគឺប្រៃ ។ បើស្ករឈប់ផ្អែម អំបិលឈប់ប្រៃ ស្ករ និង អំបិល នឹង ត្រូវបាត់បង់ខ្លឹមរបស់ខ្លួន

ខ្លឹម → ស្ករ → ផ្អែម

ខ្លឹម → អំបិល → ប្រៃ

ស្ករ និងអំបិល អាចប្រែរូបរាងបានដូចមានរាងជាគ្រាប់ធំ គ្រាប់ល្អិត ម្សៅ ធាតុរាវ ប៉ុន្តែបើ
មានជាតិស្ករត្រូវតែមានរសជាតិផ្អែម ឯអំបិលរសជាតិប្រៃ ។

មតិខ្លះចោទសួរថា ព្រលឹងរបស់ជនជាតិនីមួយ ៗ អាចផ្លាស់ប្តូរតាម ចលនាប្រវត្តិសាស្ត្រ តើនៅមានឈ្មោះថាជាព្រលឹងឬទេ ?

ការប្រែប្រួលនៃព្រលឹងតាមចលនាប្រវត្តិសាស្ត្រ មានពិតប្រាកដប៉ុន្តែ ចលនាប្រវត្តិសាស្ត្រ កាឡៃបានត្រឹមតែរូបរាងក្រៅនៃព្រលឹង ចំណែកឯខ្លឹមវិញពុំអាចកែប្រែបានទេ យ៉ាងណាមិញ ព្រលឹងរបស់អក្សរសិល្ប៍ អាចសំគាល់ចិត្តគំនិតនោះពុំឋិតនៅក្រោមកត្តានៃកាលអាកាស គឺមាន
តំលៃគ្រប់សម័យកាល ប៉ុន្មានឆ្នាំទៅមុខទៀតនៅតែត្រូវ ដូចព្រលឹងអក្សរសិល្ប៍ក្នុងសៀវភៅល្បើកលោកឡាហ្វុងតែនជាដើម ។

ដើម្បីស្រាវជ្រាវ រកព្រលឹងជនជាតិណាមួយ គេត្រូវសិក្សាមូលដ្ឋានភូមិសាស្ត្រ និង ប្រវត្តិការណ៍ ។ មូលដ្ឋានភូមិសាស្ត្រឋិតនៅលើការសិក្សាអំពីទឹកតាំងនៃជនជាតិ ធាតុអាកាស រង្វង់ កំណើនប្រជាជន ដង់ស៊ីតេ ឯមនុស្សដែលរស់នៅក្នុងមូលដ្ឋានភូមិសាស្ត្រផ្សេងគ្នា អាចមានចិត្តគំនិត មតិយោបល់ ដំណោះស្រាយបញ្ហាផ្សេងគ្នាដែរដូចជាមនុស្សដែលរស់នៅក្នុង

អាកាសធាតុក្តៅច្រើនមានកាយវិការទំរន់ បង្អួស ខ្ជិល ពុំសូវស្វាហាប់ដូចមនុស្សដែលរស់នៅក្នុងអាកាសធាតុត្រជាក់ទេ តាំងពីការអប់រំសិល្បះ ច្រើនមានដំណើរយឺត ។ ប្រវត្តិការណ៍ សំគាល់នូវហេតុការណ៍ ទាំងឡាយដែលកើតមានតាមប្រវត្តិសាស្ត្រពីមុនមក ដូចជាប្រវត្តិរបស់ខ្មែរ អាចជាប់ទាក់ទងតាំងពីសម័យហ្វូណន់មកម្លេះ ។

ចំពោះការស្រាវជ្រាវរកព្រលឹងខ្មែរ តើយើងសិក្សាតាមមូលដ្ឋានភូមិសាស្ត្រនិងប្រវត្តិការណ៍

ដូចម្តេចខ្លះ ?

ព្រលឹងខ្មែរសំគាល់នូវសង្គមការណ៍របស់ខ្មែរដែលមានរូបរាងជា ចិត្តគំនិត មតិយោបល់ ជំនឿសាសនា ប្រពៃណី មនោគមន៍ ច្បាប់ទំលាប់ របបគ្រប់គ្រង ចំណង់ចំណូលចិត្តរបស់ខ្មែរ តាំង

ពីបុរាណកាលរហូតមកដល់សព្វថ្ងៃនេះ ទោះបីមានកំលាំងក្រៅខ្លួនពីបរទេសផ្តល់ឥទ្ធិពល កាឡៃព្រលឹងនោះក៏ដោយ ក៏ព្រលឹងខ្មែរនៅរក្សាខ្លឹមរបស់ខ្លួន ហើយនឹងអាចទទួលស្គាល់ព្រលឹងដទៃទៀតបានលុះត្រាតែមានទំរង់ថ្មី សមប្រកបនឹងចំណង់ចំណូលចិត្តរបស់ខ្លួនដែរ ។

## តាមមូលដ្ឋានភូមិសាស្ត្រ

ព្រលឹងខ្មែរ ឋិតនៅត្រង់ខ្មែរជាជនជាតិមួយចូលចិត្តអួតព្រោះខ្មែរ ឋិតនៅក្នុងអំបូរខ្មែរ មន ឯអំបូរខ្មែរមន មានទីតាំងនៅជ្រោយឥណ្ឌូចិនសព្វថ្ងៃ ប៉ុន្តែសម័យនោះមានឈ្មោះថាជ្រោយ « សុវណ្ណភូមិ » ដែលមានព្រំដែនជាប់នឹងប្រទេសចិន ។ ហេតុអ្វីបានជាគេឲ្យឈ្មោះថាសុវណ្ណភូមិ ?

សុវណ្ណ ( បាលី ) = មាស

ភូមិ ( បាលី ) = ទឹកដី ឬប្រទេស

ប្រជាជនដែលរស់នៅក្នុងជ្រោយសុវណ្ណភូមិ រមែងសប្បាយចិត្ត និងអោគទ្រព្យធម្មជាតិរបស់ខ្លួន ហើយញ៉ាំងទឹកចិត្តខ្លួនឲ្យមានអំណួត អួតមិនដឹងខ្លួន ។ ប្រជាជនដែលរស់នៅជ្រោយសុវណ្ណភូមិ គឺ មន ចាម និងខ្មែរ ប៉ុន្តែសម័យនោះពុំមានកំណត់ព្រំដែនទេ ។ គេរស់នៅតាម បែបកុលសម្ព័ន្ធ ។ គេរកស៊ីជួញមាសជាមួយពួកព័រទុយគ្គេដែលឧស្សាហ៍ធ្វើដំណើរតាមសំពៅ មកកាន់សមុទ្រចិន និងតាមអូកែវ ។ គេពុំសូវខ្វល់ខ្វាយពីការរកស៊ីប៉ុន្មានទេ ក្រៅពីជំនួញមាស ជាហេតុធ្វើឲ្យជនជាតិទាំងនេះមានអំណួតច្រើន ឯជនជាតិអួតខ្លាំងជាគេគឺ មន បន្ទាប់មក ចាម បន្ទាប់មកទៀតគឺខ្មែរ ។ ខ្មែរអួតតិចជាងគេក្នុងចំណោមជនជាតិទាំង ៣ ប៉ុន្តែក៏និយមអួតដែរ ទោះបីតិចក្តីច្រើនក្តី ទើបបុព្វបុរសខ្មែរចងក្រងជាពាក្យដាស់សំរាប់ សំគាល់ផ្នត់គំនិតជនជាតិទាំង ៣នេះ

- មន យកមេឃទ្រាប់អង្គុយ
- ចាម ខ្វះមួយចំអាមដល់មេឃ
- ខ្មែរ កប់ពពកជ្រអាច័ជន្លេន

តាមពាក្យចាស់ទាំង ៣ ខាងលើនេះ យើងសង្កេតឃើញថាខ្មែរអ្នកកប់ពពក គឺពុំទាន់ដល់មេឃទេ ហើយឆាប់វិលមកកាន់ភាពដើមខ្លួនវិញ មានន័យថាអ្នកហើយច្រើនភ្ញាក់ខ្លួន ។ ខ្មែរនិយាយជាមួយខ្មែរពុំដឹងថា ខ្មែរចូលចិត្តអ្នកទេព្រោះផ្នត់គំនិតអ្នកប្រហែលគ្នា បើខ្មែរនិយាយជាមួយចាម ដែលអ្នកខ្លាំងជាងខ្មែរទើបខ្មែរចាប់អារម្មណ៍ថាចាមចូលចិត្តអ្នក យ៉ាងណាមិញ ចាមនិយាយជាមួយចាម ផ្នត់គំនិតស្របគ្នាពុំដឹងខ្លួនជាជនជាតិអ្នកទេ ប៉ុន្តែបើចាមនិយាយជាមួយមនទើបចាមដឹងថាមនជាជនជាតិអ្នកខ្លាំង ។

- មន អ្នកខ្លាំងជាងគេរហូតដល់បាត់បង់ដីអស់ទឹកដី ។
- ចាម អ្នកខ្លាំងគួរសមដែរក៏ត្រូវបាត់បង់អស់ទឹកដី ។
- ខ្មែរ អ្នកល្មមទើបនៅសល់ទឹកដីខ្លះ ប៉ុន្តែយើងពុំមាន សុទិដ្ឋិនិយមដែរថា ទឹកដីខ្មែរពិតជានៅគង់វង់រហូតដែរ ពីព្រោះសព្វថ្ងៃនេះប្រទេសខ្មែរកំពុងធ្វើដំណើរ ទៅកាន់ភាពអន្តរាយ ។

ហេតុអ្វីបានជាជនជាតិទាំង៣ នេះបាត់បង់ទឹកដី ឬបាត់បង់ខ្លះនៅខ្លះ ?

ព្រោះជាជនជាតិអ្នកអាង នឹងធនធានធម្មជាតិ របស់ខ្លួនរហូតដល់ សប្បាយភ្លេចខ្លួនមិននឹងថា មានជនជាតិដទៃចង់ដណ្តើមយកទឹកដីខ្លួនសោះ ។

ជនជាតិថៃដែលមានអំបូរខ្សែស្រឡាយជាមួយនឹងចិន ព្រោះមានទីតាំនៅប្រទេសចិនប៉ែកខាងត្បូងឆៀងខាងលិច ក្នុងខេត្ត យូណាន់ហើយគេស្គាល់នៅសតវត្សទី៨ ក្រោយការវាយលុក
នៃជនជាតិ ម៉ុងគ្គោល នៅសតវត្សទី១៣ ក៏ឆ្លៀតសំរុកកងទ័ពមកទិសខាងត្បូង តាមក្រុងសុខោទ័យ ដណ្តើមយកទឹកដីមនអស់ និងទឹកដីខ្មែរខ្លះដែលជាខណ្ឌ នៅខាងជើងជួរភ្នំដងរែកតាមទន្លេសេមូន
ដូចជាខេត្ត នគររាជ សូរិន សង្កាស គោកខាន់ស៊ីសាកេត បុរីរម្យ រហូតដល់ដែនដីម៉ាឡាយូទៀតផង ដែលសុទ្ធសឹងជាទឹកដីក្នុងជ្រោយសុវណ្ណភូមិ ។

នៅឆ្នាំ១៧៩៤-៩៥ មន្ត្រីខ្មែរបីនាក់ដណ្តើមគ្នាធ្វើធំ ម្នាក់អ្នកថាគ្រាន់បើជាងម្នាក់ ព្រោះខ្លួនជាពូជអំបូរអ្នក ។ មន្ត្រី បែន ប្រើល្បិចឲ្យមន្ត្រី សួស សំលាប់មន្ត្រីបូ រួចហើយក៏សំលាប់មន្ត្រីសួសវិញ ប៉ុន្តែដោយមន្ត្រីសួស មានបក្សពួកច្រើន មន្ត្រី បែន ក៏បើកដៃឲ្យសៀមលើកទ័ពវាយប្រហារ

ប្រទេសខ្មែរបានដោយងាយ ហើយយល់ព្រមប្រគល់ខេត្តខ្លះឲ្យសៀម ជាការតបស្នងសងគុណ ដូចខេត្ត បាត់ដំបង មង្គលបុរី និងសិរីសោភ័ណ ។

ហេតុអ្វីបានជានៅសម័យនោះមន្ត្រីខ្មែរឡើងចាងខ្លាំងម្លេះ ?

ព្រោះនៅសម័យនោះការអួតអាងដណ្តើមអំណាចគ្នាមានកម្រិតខ្លាំងក្លាណាស់ដោយមានទ័ពបរទេសជាបង្អែក ។ គេបង្ខំឲ្យព្រះអង្គ អេង ដែលជាបុត្រព្រះឧទ័យទី២ ឡើងសោយរាជ្យ
ពីអាយុ ៦ ឆ្នាំឥតដឹងខ្យល់អ្វីសោះមន្ត្រីធ្វើអ្វី ៗ បានតាមចិត្ត ។

*តាមឧទាហរណ៍ ប្រវត្តិសាស្ត្រខាងលើនេះ ហើយអាចយល់បានថាទ័ពបរទេស ដែលអាចឈ្លានពានទឹកដីខ្មែរ បានដោយសារតែការឲ្យដៃពីមន្ត្រីខ្មែរដែលជាអ្នកមានអស្មិមានៈអួតអាងថាខ្លួនគ្រាន់បើជានិច្ចទោះបីប្រទេសជាតិរលត់រលាយក៏ដោយ ។*

មានឯកសារច្រើនណាស់ដែលលាតត្រដាងបង្ហាញថា ខ្មែរចូលចិត្តអួត ដូចជាច្បាប់ផ្សេង ៗ របស់ខ្មែរ តាំងពីច្បាប់បណ្តាំបិតា ច្បាប់កូនចៅ ច្បាប់កូនចៅល្បើក ច្បាប់ប្រុស..... សុទ្ធសឹងអប់រំកុំឲ្យខ្មែរចូលចិត្តអួតពេកដូចមានឧទាហរណ៍តទៅនេះ :

### ច្បាប់បណ្តាំបិតា

កុំអួតកំលាំង កុំអាងខ្លួនខ្លាំងរត់នឹងស្រមោល
កុំអាងជាធំ កុំងាយពាក្យពោល........
...រីឯកង្អែប មុខដូចគេពេប ហាឡើងស្រដី អួតឯងកំលាំង
ជល់នឹងដំរី ទោះទាំងរាជសីហ៍ ក៏អញមិនខ្លាច ។

### ច្បាប់កូនចៅល្បើក

...រីឯគីង្គក់ លោតឡើងពីភក់ មើលទៅគួរស្អប់ អួតខ្លួនថាល្អ
ដូចមាសទឹកដប់ រាងអញចំប្រប់ដូចជារាជសីហា

### ច្បាប់កូនចៅ

....កុំអាងស័ក្តិបុណ្យ
....កុំអាងមានទ្រព្យ
....កុំអាងចំណេះ អុំអួតថាចេះ....
....កុំអួតភ្លេចខ្លួន
....ចូរចេះដាក់ខ្លួន គួរគិតក្តីស្ងួន

ព្រលឹងខ្មែរ មួយបែបទៀតតាមមូលដ្ឋាន ភូមិសាស្ត្រឋិតនៅត្រង់កសិកម្ម ព្រោះប្រទេសខ្មែរ
តាំងពីដូនតាមក រស់នៅដោយសារតែកសិកម្ម ហើយខ្មែរក៏យកជាមូលដ្ឋានគ្រឹះមានន័យថាការអប់រំសព្វសារពើមានប្រភពចេញពីកសិកម្ម ដូចការរៀបចំទុកដាក់កូនចៅខ្មែរ កូនប្រុសត្រូវចេះធ្វើកសិកម្ម ឬ សិប្បកម្ម ខ្មែរនិយមយកការធ្វើស្រែចំការជាមូលដ្ឋាន :

ក/ ក្នុងវិស័យគ្រួសារ

« ធ្វើស្រែឲ្យមើលស្មៅ ទុកដាក់កូនចៅឲ្យមើលផៅសន្តាន »

« ធ្វើស្រែទាន់ក្ដៅដី ចង់ស្រីទាន់ក្ដៅចិត្ត »

« សំណាបយោងដី ស្រីយោងប្រុស »

ខ/ ក្នុងវិស័យយោធា

« ធ្វើស្រែនិងទឹក ធ្វើសឹកនឹងបាយ »

គ/ ក្នុងវិស័យកសាងជាតិ

« កសិកម្មជាឆ្អឹងខ្នងនៃរដ្ឋ »

ឃ./ក្នុងវិស័យអប់រំទូទៅ

« តក់ ៗ ពេញបំពង់ »

« ដើយវាស្អក ខិនវាដាក់គ្រាប់ »

« សប្បាយធ្វើស្រែ ចំការជួញប្រែ នោះមានគេរាប់ សប្បាយបានស៊ី សប្បាយបានទ្រព្យ

សប្បាយនោះគាប់ សប្បាយឺនយូរ »

- ព្រលឹងខ្មែរ មួយបែបទៀតតាមមូលដ្ឋានភូមិសាស្ត្រឋិតនៅត្រង់ខ្មែរ ជាជនជាតិពុំសូវចេះគោរពច្បាប់ ព្រោះអ្វី ?

ប្រទេសខ្មែរឋិតនៅទីតាំងមួយ ដែលពុំសូវមានការកំហែងគំរាមពីធម្មជាតិ ឬឧបសគ្គធម្មជាតិ ដូចជាប្រទេសជប៉ុន និង ប្រទេសអឺរ៉ុប :

- ត្រជាក់ខ្លាំង
- រញ្ជួយព្រះធរណី
- ផ្ទុះភ្នំភ្លើង
- ខ្យល់ព្យុះ
- ខ្យល់ព្យុះសមុទ្រ

- ខ្យល់ព្យុះសមុទ្រខ្សាច់
- ទឹកជំនន់

ប្រទេសខ្មែរមានឧបសគ្គធម្មជាតិស្តួចស្តើងណាស់ ស្ទើរតែគ្មានផងក្រៅពី ទឹកជំនន់ បួនដប់ឆ្នាំទើបមានម្តង ហើយពុំសូវសាហាវទៀតផង ចំណែកឯធាតុអាកាសវិញ ខ្មែរស្ទើរតែរស់នៅស្រោតននលក៏មិនស្លាប់ដែរ ចំពោះការរញ្ជួយផែនដីប្រទេសខ្មែរពុំដែលជួបប្រទះសោះក្រៅពីការទំលាក់គ្រាប់បែក បេ៥២ រញ្ជួយផ្ទះរាល់ថ្ងៃ រាល់យប់វិនាសអស់ភូមិអ្នកស្រុកនិងចំការ ។

ដោយហេតុតែប្រទេសខ្មែរពុំសូវជួបប្រទះឧបសគ្គធម្មជាតិ ទើបខ្មែរពុំសូវខ្លាចធម្មជាតិ ហើយក៏ពុំគោរពច្បាប់ធម្មជាតិដែរ ។ ការពុំចេះគោរពច្បាប់ធម្មជាតិបានទំលាប់ឲ្យខ្មែរ ពុំសូវចេះគោរពច្បាប់សំរាប់ស្រុក លុះត្រាតែមានការបង្ខំទើបគោរព ផ្ទុយពីប្រទេសត្រជាក់ដែលខ្លាចធម្មជាតិខ្លាំងណាស់ បើគ្មានសំលៀកបំពាក់គ្រប់គ្រាន់ទេ ពុំអាចនៅបានឡើយ ។ ប៉ុន្តែពលរដ្ឋនៅប្រទេសត្រជាក់បើបានមករស់នៅស្រុកខ្មែរយូរទៅក៏មានចិត្តគំនិតប្រហែលនឹងខ្មែរដែរ ។ យ៉ាងណាមិញពលរដ្ឋខ្មែរទៅរស់នៅស្រុកត្រជាក់មានស្រុកបារាំង ជាដើមក៏នឹងផ្លាស់ប្តូរចិត្តគំនិតទៅរកជាតិគេដែរ ។ នេះជាការវិនិច្ឆ័យព្រលឹងខ្មែរ តាមមូលដ្ឋានភូមិសាស្ត្រ ។

ព្រលឹងខ្មែរ មួយបែបទៀត ឋិតនៅត្រង់ខ្មែរជា ជនជាតិអសកម្ម ព្រោះខ្មែររស់នៅក្នុងទីតាំងប្រទេសក្តៅជាហេតុធ្វើឲ្យខ្មែរក្លាយជាជនជាតិពុំសូវមានសកម្មភាពច្រើន ព្រលឹងសិល្បះខ្មែរ ឋិតនៅត្រង់ភាពទន់ភ្លន់ ល្វតល្វើយ អណ្តែតអណ្តូង ពុំស្វាហាប់ទេ បទភ្លេងលន្លង់លន្លោចគួរឲ្យចង់ងុយដេក ដំណើរខ្មែរមួយ ៗ ដើរទៅធ្វើការដូចដើរលេង... ទាំងអស់នេះបានដឹកនាំខ្មែរឲ្យនិយមមនុស្សខ្ជិលជាងមនុស្សឧស្សាហ៍ មនុស្សមានគំនិតរក្សានិយមជាងមនុស្សមានគំនិតបដិវត្តន៍និយម ឲ្យខ្មែរសសើរមនុស្សធ្វើការតិច តែបានប្រាក់ខែច្រើនជាងមនុស្សធ្វើការច្រើនបានប្រាក់ខែរតិច ។ គេសរសើរបុគ្គលិករដ្ឋម្នាក់ដែលគ្រាន់តែចុះហត្ថលេខាបន្តិចបានប្រាក់រាប់លានរៀល ជាងបុគ្គលិកដែលខំធ្វើការពីព្រលឹមដល់ល្ងាច ហើយបានលុយស្ទើរមិនគ្រប់គ្រាន់ចាយ ។ តាមពិត គួរតែសរសើរបុគ្គលិកចុងក្រោយនេះដែលបានបំពេញពលិកម្ម ហើយពុំសូវធ្វើឲ្យខូចថវិកាជាតិ ។ បុគ្គលិកគ្រូបង្រៀនម្នាក់ និងបុគ្គលិក ក្រសួងគយម្នាក់ចូលស្តីដណ្តឹងកូនក្រមុំគេដូចគ្នា បុគ្គលិកគ្រូបង្រៀនពុំមានសង្ឃឹមទេ... ទាំងអស់នេះកើតមកពីអ្វី ?

នេះហើយជាអយុត្តិធម៌ក្នុងសង្គមនៃប្រទេសក្តៅ ! តើត្រូវរស់នៅតាមធម្មជាតិតទៅទៀត ឬត្រូវយកជ័យជំនះលើធម្មជាតិ ? តើត្រូវរំលាយព្រលឹងនេះចោលឬទេ ? ទាំងអស់នេះនឹងធ្វើទៅបានអាស្រ័យលើស្មារតីភ្ញាក់រលឹករបស់កូនខ្មែរប៉ុន្តែនឹងភ្ញាក់រលឹកបាន លុះត្រាតែចេះដឹងសិន

ពោលគឺត្រូវមានពុទ្ធិ បើខ្វះពុទ្ធិយើងអាចភ្ញាក់រលើកទៅរកផ្លូវខុសដោយអចេតនា ព្រោះភាពល្ងិតល្ងង់ឬអវិជ្ជាចង្រៃណាស់ គេអាចធ្វើអាជីវកម្មលើខួរក្បាលយ៉ាងងាយបំផុត ។

ឧ : ក្នុងរឿងព្រេងខ្មែរ ក៏អ្នកនិពន្ធខ្មែរធ្លាប់លើកយកគំនិតនេះមកបង្ហាញដែរដូចជា ៖

- មនុស្សល្ងង់ខ្លៅម្នាក់បានកំណប់មាស២ពាង
- មនុស្សភ្លីភ្លើច្រើនបានប្រពន្ធជាស្រីគ្រប់លក្ខណ៍
- មនុស្សចំកួតច្រើនបានវត្ថុសក្តិសិទ្ធិ
- មនុស្សឥតចេះដឹងអ្វីសោះបានឡើងឋានៈជាសេដ្ឋី
- គង់ ហ៊ាន បានឡើងឋានៈជាវីរជនខ្មែរដោយសារលាមក របស់ខ្លួន ។

ឧ : ពាក្យចាស់ខ្មែរអប់រំថា ៖

« អ្នកប្រាជ្ញធ្លាក់រណ្តៅ អ្នកខ្លៅឡើងឋានសួគ៌ » តាមពាក្យអធិប្បាយខាងលើនេះ តើគួររក្សាព្រលឹងខ្មែរបែបនេះតទៅទៀតឬទេ ?

ព្រលឹងខ្មែរ មួយបែបទៀត ឋិតនៅត្រង់ខ្មែរ ជាជនជាតិប្រលាំងប្រកូវ ព្រោះខ្មែរមានទីតាំងនៅក្នុងប្រទេសមួយដែលរដូវពុំទៀងទាត់ រដូវភ្លៀង រដូវក្តៅ រដូវរងា ពុំច្បាស់លាស់ ពុំដឹងថ្ងៃណា ខែណាពិតប្រាកដ ផ្ទុយពីប្រទេសត្រជាក់ដែលមានរដូវទៀងទាត់ដូចជា៖

- រដូវផ្កាឈើលាស់ ពីថ្ងៃ២១ មីនា ដល់ ២១ មិថុនា
- រដូវក្តៅ ពីថ្ងៃ ២១ មិថុនា ដល់ ថ្ងៃ២២ កញ្ញា
- រដូវស្លឹកឈើជ្រុះ ពីថ្ងៃ២២ កញ្ញា ដល់ ថ្ងៃ២១ ធ្នូ
- រដូវធ្លាក់ទឹកកក ពីថ្ងៃ២១ ធ្នូ ដល់ ថ្ងៃ២១ មីនា

រដូវច្បាស់លាស់បានធ្វើឲ្យផ្នត់គំនិតរបស់ប្រជាពលរដ្ឋ ដែលរស់នៅទីនោះមានបែបផែនច្បាស់លាស់ :

ឧ : ពេលធ្វើការ គឺធ្វើការ

- ពេលដើរលេង គឺដើរលេង
- ពេលរៀន គឺរៀន
- ពេលបរិភោគ គឺបរិភោគ
- ពេលឈប់ គឺឈប់ ... ឥតមានប្រលាំងប្រកូវទេ ដូចជានៅប្រទេសបារាំង យើងពុំអាចដើររកបរិភោគអាហារនៅម៉ោង ៩-១០ យប់បានឡើយ គឺនៅមានតែភេសជ្ជៈប៉ុណ្ណោះ ។

ប្រទេសខ្មែរដែលមានរដូវពុំទៀងទាត់ បានធ្វើឲ្យពលរដ្ឋខ្មែរដែលរស់នៅទីនោះមានផ្នត់គំនិតពុំច្បាស់លាស់ដែរ :

ខ : ពេលធ្វើការ និងពេលដើរលេងលាយឡំគ្នា

- ឈ្លោះគ្នាពេលធ្វើការ ក៏នៅតែឈ្លោះគ្នាពេលនៅផ្ទះ
- ពេលរៀន និងពេលវិស្សមកាលលាយឡំគ្នា
- ពេលបរិភោគមានតាំងពីព្រលឹម ទល់កណ្ដាលអធ្រាត្រដល់ភ្លឺ វិញទៀតផង
- កិច្ចការនៅការិយាល័យ និងកិច្ចការនៅផ្ទះច្របូកច្របល់គ្នា
- ឡានរដ្ឋការ ក៏ដូចជាឡានផ្ទាល់ខ្លួនបញ្ជិះប្រពន្ធ បញ្ជិះកូនទៅរហូតដល់បញ្ជិះស្រី
- ខ្លះពូកែខាងរៀបចំល្ខោន ពូកែបង្រៀន... ស្រាប់តែបានឡើងធ្វើរដ្ឋមន្ត្រី

( ថ្វីដៃមនុស្សឋិតនៅក្នុងវិស័យផ្សេង ៗ គ្នា ) ដើម្បីកែប្រែព្រលឹងបែបនេះ លុះត្រាតែបង្កើតច្បាប់តឹងតែងណាស់ ហើយឧទាហរណ៍មកពីលើ ពុំមែនមកពីក្រោមទេ ។

## បញ្ចប់សេចក្ដី

តាមការអធិប្បាយរួចមកហើយអំពីកិច្ចការស្រាវជ្រាវរកព្រលឹង នៃជនជាតិណាមួយភ្ជាប់ទៅនឹងជនជាតិខ្មែរតាមមូលដ្ឋានភូមិសាស្ត្រ និងប្រវត្តិការណ៍ យើងអាចយកការស្រាវជ្រាវរកព្រលឹងខ្មែរជាគំរូ ដើម្បីស្រាវជ្រាវរកព្រលឹងនៃជនជាតិឯទៃទៀត តើមានទំនាក់ទំនងនិងលក្ខណ: ដាច់គ្នាដូចម្ដេចខ្លះ ទើបយើងដឹងថាព្រលឹងនៃជនជាតិនីមួយ ៗ ពុំមែនសុទ្ធតែល្អទេ ព្រលឹងណាល្អគួររក្សាទុក ឯព្រលឹងពុំល្អគួររំលាយចោល ទើបប្រទេសខ្លះដែលជួបប្រទះព្រលឹងពុំល្អរមែងដោះស្រាយដោយបដិវត្តន៍ ជួនកាលទៀត មានបដិវត្តន៍លើបដិវត្តន៍ដើម្បីរកព្រលឹងល្អបរិសុទ្ធពិតប្រាកដ ។

## ប្រធានទី១០៖

*មនុស្សគោរពច្បាប់ធម្មជាតិ និងមនុស្សត្រួត្រា លើធម្មជាតិ តើករណីណាប្រសើរជាង ?*

*ពន្យល់ ពិភាក្សា និងឧទាហរណ៍ដោយយកតំលៃសីលធម៌បញ្ជាក់ផង ។*

## ផ្តើមសេចក្តី:

មនុស្សកើតមករស់នៅជាមួយធម្មជាតិ ព្រោះសរីរៈរបស់មនុស្សជាភាវៈ គឺជាវត្ថុធាតុនៃធម្មជាតិជាហេតុឲ្យមនុស្សសំរបនិងតំរូវជីវភាពរបស់ខ្លួនតាមធម្មជាតិ ប៉ុន្តែចាប់តាំងពីមនុស្សរកឃើញភ្លើងពេលណាមក មនុស្សមានគំនិតចង់ត្រួតត្រាលើធម្មជាតិ ទើបមតិចែងថា មនុស្សគោរពច្បាប់ធម្មជាតិ និងមនុស្សត្រួតត្រាលើធម្មជាតិ តើករណីណាប្រសើរជាង ? តើករណី ណាប្រកបដោយសីលធម៌ ?

## តួសេចក្តី:

### មតិទី១

« មនុស្សគោរពច្បាប់ធម្មជាតិ »

ច្បាប់ធម្មជាតិមានន័យដូចម្តេច ?

ច្បាប់ធម្មជាតិសំគាល់ដំណើរប្រព្រឹត្តទៅនៃធម្មជាតិ គឺចលនាវិលវល់ក្នុងវដ្តសង្សារនៃភាវៈ ៖

- ព្រះអាទិត្យរះឡើងហើយលិចទៅវិញ ដើម្បីរះឡើងវិញជាថ្មីម្តងទៀត
- រុក្ខជាតិ មនុស្ស សត្វ កើតឡើងហើយស្លាប់ទៅវិញ ដើម្បីទុកកន្លែងដល់កំណើតថ្មីទៀតនៃភាវៈដទៃ
- អ្វីទាំងអស់ក្នុងភាវៈត្រូវតែផ្លាស់ប្តូរ
- អ្វីទាំងអស់ក្នុងវមែងមាន គូតាំងពីប្រុសស្រី ញីឈ្មោល ល្អអាក្រក់ សុខទុក្ខ ឧស្សាហ៍ខ្ជិល ខ្ពស់ទាប ។

ទាំងអស់នេះជាទ្រឹស្តីធម្មជាតិនិយមយល់តាមពុទ្ធសាសនា ។

មនុស្សគោរពច្បាប់ធម្មជាតិ គឺមនុស្សត្រូវសំរបសំរួលជីវភាពរបស់ខ្លួនតាមគំរាយផ្លូវរបស់ធម្មជាតិ ។

គោរពច្បាប់ធម្មជាតិរបស់បុគ្គល គឺសេរីភាព ព្រោះបុគ្គលកើតមកមានសេរីភាពពិតប្រាកដ ប៉ុន្តែសង្គមទេដែលធ្វើឲ្យបាត់បង់សេរីភាព ដើម្បីសង្កត់សង្កិនអ្នកទន់ខ្សោយ ។ ត្រង់ចំណុចនេះ លោករូស្សូ អ្នកប្រាជ្ញបារាំងម្នាក់នៅសតវត្សទី១៨ បានថ្កោលទោសលើ

សង្គមដោយ យល់ថា û ក្មេងកើតមកល្អសោះប៉ុន្តែសង្គមធ្វើឲ្យក្មេងពុករលួយ ™ ។ លោកវ៉ុលទែរ រស់នៅជំនាន់លោករូស្សូ ពុំទំលាក់កំហុសទៅលើសង្គមទេ គឺឲ្យតំលើការអប់រំវិញ ។

គោរពច្បាប់ធម្មជាតិតាមអន្តរបុគ្គល

- អ្នកឆ្លាតបានចំណេញ
- អ្នកប្រសប់រស់នៅបានស្រួលជាងអ្នកមិនប្រសប់
- អ្នកមានប្រាជ្ញគ្រាន់បើជាងអ្នកល្ងង់ ទោះបីប្រាសចាកសីលធម៌ក៏ដោយ
- អ្នកលួចប្រសើរជាងអ្នកមិនចេះលួច

គោរពច្បាប់ធម្មជាតិក្នុងសង្គម

ត្រីស្ពិត្រីធំស៊ីត្រីតូចឬ û មនុស្សជាឆ្កែចចករបស់មនុស្ស ™ តាមទស្សនៈលោក តូម៉ាហុប្ស ទស្សនវិទូអង់គ្លេស ។

ក្នុងធម្មជាតិ គ្មានទេមនុស្សធ្វើល្អ ដោយពុំគិតប្រយោជន៍ផ្ទាល់ខ្លួន ឬប្រយោជន៍អ្វីមួយ គឺមានសុទ្ធតែមនុស្សចាំធ្វើអាជីវកម្មលើមនុស្សផងគ្នា ឲ្យតែមានឱកាស ។ គេយល់ដែនដីសម្រាប់តែមនុស្សខ្លាំងនៅ អ្នកខ្សោយត្រូវតែដកខ្លួនចេញ ហើយកុំតូចចិត្តអ្វី បើចង់រស់នៅបានស្រួលត្រូវខំឲ្យបានជាមនុស្សខ្លាំងជាងអ្នកដទៃ ទោះបីមធ្យោបាយនោះប្រាសសីលធម៌ក៏ដោយ ដូចលួចប្លន់ បំបាត់ បន្លំ គិតយ៉ាងណា ឲ្យតែបានលុយច្រើន ព្រោះកាលណាមានលុយច្រើនហើ ប្រាថ្នាអ្វី ៗ តែងតែបានដូចបំណង ។

## មតិទី២

« មនុស្សត្រួត្រាធម្មជាតិ »

ចាប់តាំងពីមនុស្សរកឃើញភ្លើង មនុស្សមានបំណងត្រួត្រាលើធម្មជាតិព្រោះភ្លើងអាចធ្វើឲ្យភាវៈប្រែប្រួល តាមបំណងរបស់មនុស្សដូចជាសាច់នៅឆៅទៅជាឆ្អិន វត្ថុរាវទៅជារឹង កខ្វក់ទៅជាស្អាត តើមនុស្សមានគំនិតដូចម្តេចក្នុងបំណងត្រួត្រាលើធម្មជាតិ ?

- មិនចង់ឲ្យមនុស្សមានសេរីភាពហួសព្រំដែន ទើបបង្កើតច្បាប់ឡើង
- មិនចង់ឲ្យបុគ្គលខ្លះសប្បាយតែម្នាក់ឯង
- មិនចង់ឲ្យបុគ្គលកសាងសេចក្តីសុខលើគំនរទុក្ខអ្នកដទៃ
- មិនចង់ឲ្យអ្នកខ្លាំងជិះជាន់អ្នកខ្សោយ
- មិនចង់ឲ្យអ្នកមានប្រាជ្ញាធ្វើអាជីវកម្មលើអ្នកល្ងង់
- មិនចង់ឲ្យមនុស្សស្លាប់តាមបែបធម្មជាតិ

- មិនចង់ឲ្យមនុស្សទាំងអស់នៅក្រោមឥទ្ធិពលនៃធម្មជាតិ

ពិតមែនតែមនុស្សចង់ត្រួត្រាលើធម្មជាតិ តែមនុស្សពុំបានសំរេចបំណងរបស់ខ្លួនមួយរយភាគរយទេ គឺបានត្រឹមតែ ៣៥% ប៉ុណ្ណោះដរាបណាមនុស្សពុំទាន់រើបំរះខ្លួនចេញពីសេចក្ដីស្លាប់ ។

ពិភាក្សា :

- មនុស្សត្រូវគោរពច្បាប់ធម្មជាតិ តែត្រូវប្រកបដោយសីលធម៌ គឺត្រូវចៀសវាងករណីដែលមនុស្សអាចធ្វើអាជីវកម្មលើមនុស្សផងគ្នា

- មនុស្សត្រូវរៀបចំខ្លួនត្រួត្រាលើធម្មជាតិ ទោះបីពុំបានតាមបំណងក្ដី ក៏ត្រូវតែខំត្រួត្រាលើធម្មជាតិតទៅទៀត ព្រោះទោះបីមនុស្សនៅតែស្លាប់ក៏ដោយ ក៏ត្រូវតែតស៊ូចំពោះការស្លាប់តាមបែបធម្មជាតិយ៉ាងហោចណាស់ក៏អាចស្វែងរកថ្នាំសង្កូវបន្តអាយុ បានយឺនយូរតទៅមុខទៀតដែរ ដូច្នេះការពិភាក្សារបស់យើងបិតក្នុងករណីបដិសំយោគគឺត្រូវ គោរពតាមច្បាប់ធម្មជាតិផង និងត្រូវស្វែងរកវិធីត្រួត្រាលើធម្មជាតិផង ប៉ុន្តែត្រូវស្វែងរកករណីណាដែលប្រកបដោយសីលធម៌ ប្រាសចាកបាបកម្មទៅលើមនុស្សផងគ្នា ព្រោះអំពើដែលខ្វះសីលធម៌ ទោះបីមានជ័យជំនះមួយរយៈកាលក៏ដោយរមែងបិតនៅជាកម្មវត្ថុនៃការតវ៉ាទាមទារពុំឈប់ឈរ ឆ្ពោះទៅរកអ្វីដែលប្រកបដោយសីលធម៌ ។

បញ្ចប់សេចក្ដី :

រួមសេចក្ដីមក ការអធិប្បាយរួចមកហើយបង្ហាញឲ្យឃើញថា ទ្រឹស្ដីដែលចែងអំពីមនុស្សគោរពច្បាប់ធម្មជាតិ និង មនុស្សត្រួត្រាលើធម្មជាតិ ពុំមានករណីណាមួយប្រសើរជាងករណីដទៃទៀតក្នុងភាពបណ្ដាច់នោះទេ ព្រោះមនុស្សរស់នៅក្នុងការអនុវត្តទ្រឹស្ដីទាំងបែបនេះតាមពេលវេលា ប៉ុន្តែយើងគួរឲ្យតំលៃទៅលើមតិដែលនិយមទ្រឹស្ដីមនុស្សត្រួត្រាលើធម្មជាតិ ដើម្បីឲ្យមនុស្សក្លាយទៅជាម្ចាស់នៃធម្មជាតិ ក្នុងបំណងស្វែងរកសុខុមាលភាពសំរាប់មនុស្សជាតិ នឹងរំដោះមនុស្សឲ្យផុតចេញពីនឹមនៃច្បាប់ធម្មជាតិ ។

## ប្រធានទី១១៖

ព្រលឹងបុគ្គល ព្រលឹងអក្សរសិល្ប៍ ព្រលឹងជនជាតិមានទំនាក់ទំនង និងដាច់ពីគ្នាដូចម្ដេចខ្លះ ?

តើត្រូវធ្វើដូចម្ដេចដើម្បីឲ្យព្រលឹងទាំងបីបានប្រសើរ ?

ពន្យល់ ពិភាក្សា និងឧទាហរណ៍ ។

**ផ្តើមសេចក្តី :**

តាមទ្រឹស្តីធម្មជាតិ ភាវៈទាំងឡាយពុំមានព្រលឹងទាំងអស់ទេ ភាវៈខ្លះមានព្រលឹង ភាវៈខ្លះទៀតពុំមានព្រលឹងទេ ។ ភាវៈណាមានព្រលឹង នឹងមានធាតុរឹងប៉ឹងពុំប្រែប្រួលដោយងាយទេ ដូចជាព្រលឹងបុគ្គល ព្រលឹងអក្សរសិល្ប៍ ព្រលឹងជនជាតិ ។

តើត្រូវធ្វើដូចម្តេចដើម្បីឲ្យព្រលឹងទាំងបីបានល្អប្រសើរ ?

**តួសេចក្តី :**

**១-ពន្យល់ព្រលឹងទាំងបី**

*+ ព្រលឹងបុគ្គល*

តាមចិត្តវិជ្ជា ព្រលឹងបុគ្គល សំគាល់ធាតុអរូបីម្យ៉ាងនៅក្នុងខ្លួនបុគ្គល រឹងប៉ឹងពុំប្រែប្រួល តំណាងខ្លឹមរបស់បុគ្គល ជាអ្នកបញ្ជាឲ្យបុគ្គលធ្វើអ្វី ៗ តាមបំណងរបស់ខ្លួន ខ្លះយល់ថាជាវិញ្ញាណ ឬ មនសិការ របស់បុគ្គល ។ ព្រាហ្មណ៍សាសនា ហៅព្រលឹងថាអាត្មន៍ ពុទ្ធសាសនាហៅ អត្តៈ ឬ សង្ខារ ។ បើបុគ្គលស្លាប់ទៅ ព្រលឹងនឹងចាកចេញពីសរីរៈបុគ្គល ដែលចាស់ទ្រុឌទ្រោម ដើម្បីស្វែងរកកំណើតថ្មី ប៉ុន្តែព្រឹងពុំចេះស្លាប់ទេ ទើបប្លាតុង ទំលាប់ឲ្យឈ្មោះថា អមតភាពនៃព្រលឹង ដែលជាចលនាវិលវល់នៃវដ្តសង្សារ ។

*+ ព្រលឹងអក្សរសិល្ប៍*

តាមទ្រឹស្តីអក្សរសិល្ប៍ ព្រលឹងអក្សរសិល្ប៍សំគាល់គោលគំនិតរបស់ អ្នកនិពន្ធដែលបានកត់ត្រាទុកក្នុងស្នាដៃរបស់ខ្លួនហើយគោលគំនិតនោះ ពុំចេះប្រែប្រួលតាមពេលវេលាតាមទីកន្លែង ពោលគឺ ពុំឋិតនៅក្រោមកត្តានៃកាលអាកាស សម័យកាលណា គោលគំនិតនោះនៅតែត្រូវ ។ ផ្ទុយទៅវិញ អក្សរសិល្ប៍ដែលសំរួលគោលគំនិតតាមព្រឹត្តិការណ៍ តាមទីកន្លែង តាមឥទ្ធិពល នៃប្រយោជន៍ អក្សរសិល្ប៍នឹងត្រូវបាត់បង់ព្រលឹងរបស់ខ្លួន ។ អក្សរសិល្ប៍បារាំងដែលគេចាត់ទុកថាមានព្រលឹងរបស់ខ្លួនគឺ ល្បើក លោក ឡាហ្វុងតែន ឯអក្សរសិល្ប៍ខ្មែរគឺ រឿងទុំទាវ ។

*+ ព្រលឹងជនជាតិ*

តាមប្រជាជាតិវិជ្ជា ព្រលឹងជនជាតិសំគាល់វប្បធម៌ និងអរិយធម៌ របស់ជាតិនោះដែលនៅគង់វង់របៀតមកដល់សព្វថ្ងៃ ទោះបីមានការប្រែប្រួលបន្តិចបន្តួចក្តីតាមកាលអាកាស ក៏ព្រលឹងរបស់

ជនជាតិនីមួយ ៗ នៅរក្សាខ្លឹមរបស់ខ្លួន ព្រោះខ្លឹមសំគាល់ធាតុសំខាន់ ជាងគេពុំចេះប្រែប្រួល ។

### ២- ទំនាក់ទំនងរវាងព្រលឹងទាំងបី

ព្រលឹងទាំងបីនេះមានទំនាក់ទំនងទៅវិញទៅមក ឬមានលក្ខណៈស្របគ្នា ក្នុងករណីដែលព្រលឹងទាំងបីប្រកបដោយលក្ខណៈពុំប្រែប្រួល មានន័យថា ព្រលឹងបុគ្គលក្តី ព្រលឹងអក្សរសិល្ប៍ក្តី និងព្រលឹងជនជាតិក្តី មានលក្ខណៈមិនប្រែប្រួលដូចគ្នា បុគ្គលស្លាប់មែន តែព្រលឹងបុគ្គលនៅដដែល ។ ប្រទេសជាតិឋិតនៅក្នុងស្ថានភាពបែបណាក៏ដោយ ក៏អត្ថបថអក្សរសិល្ប៍នៅតែរក្សាគោលគំនិតរបស់ខ្លួន ដែលជាព្រលឹងអក្សរសិល្ប៍ដដែល ហើយទោះបីប្រទេសជាតិឋិតក្នុងស្ថានភាពលូតលាស់ក្តី ហើយក៏ព្រលឹងជាតិមិនប្រែប្រួលតាមដែរ ។

លក្ខណៈមួយទៀតនៃទំនាក់ទំនងគឺ ខ្លឹមនៃព្រលឹងទាំងបីដូចជា ខ្លឹមរបស់បុគ្គលឋិតនៅត្រង់កិត្តិនាមល្បីល្បាញ ស្នាដៃគួរឲ្យស្ងើចធ្វើឲ្យកេរ្តិ៍ឈ្មោះរបស់បុគ្គលនៅគង់វង់រហូត មានន័យថា ព្រលឹងរបស់បុគ្គលមានខ្លឹមរបស់ខ្លួន ។ ខ្លឹមនៃអក្សរសិល្ប៍ឋិតនៅត្រង់ស្នាដៃដ៏សំខាន់របស់អ្នកនិពន្ធប្រកបដោយវិសេសភាពរបស់ខ្លួនពុំងាយនឹងធ្វើតាមបាន សមនឹងសំដីរបស់សាតូព្រីយ៉ង់ អ្នកនិពន្ធបារាំងសតវត្សទី១៩ ។

បើយើងលើកយកស្នាដៃល្បើករបស់លោក ឡាហ្វុងតែន មកធ្វើឧទាហរណ៍បញ្ជាក់នោះ យើងនឹងឃើញថាខ្លឹមសារនៃអត្ថបទឋិតនៅដូចដើមគ្រប់សម័យកាល ទោះបីយកអត្ថបទនោះនៅអប់រំមនុស្សសម័យណាក៏បានដែរ ។

ខ្លឹមនៃជនជាតិ ឋិតត្រង់សារៈសំខាន់ណាមួយដែលជនជាតិនោះ ប្រកាន់យករហូតមកដល់សព្វថ្ងៃដូចជាខ្លឹមសារនៃព្រលឹងខ្មែរឋិតនៅលើពាក្យសច្ចៈ ( មនុស្សយកសំដី ដំរីគេយកភ្លុក ) ព្រហ្មចរិយ ( សុខចិត្តស្លាប់ខ្លួន កុំឲ្យតែបាត់បង់ព្រហ្មចរិយ ) ។

ទំនាក់ទំនងមួយបែបទៀតឋិតនៅត្រង់លក្ខណៈ ដែលមានភាពបន្តទៅរហូត ដូចបុគ្គលស្លាប់ពិតមែន តែព្រលឹងបុគ្គលនោះពុំស្លាប់ទេ គឺមានជីវិតបន្តទៅទៀត ដោយគ្រាន់តែចាកចេញពីសរីរៈរបស់បុគ្គលដែលស្លាប់ នោះទៅចូលក្នុងសរិរៈ របស់បុគ្គលម្នាក់ទៀតតែប៉ុណ្ណោះ យ៉ាងណាមិញអត្ថបទទុំទាវក្តី អត្ថបទល្បើកឡាហ្វុងតែនក្តី មានជីវិតរហូតមកដល់ សព្វថ្ងៃក៏ដូចជាព្រលឹងរបស់ជនជាតិប្រកបដោយមតិ យោបល់ ផ្នត់គំនិត ចំណង់ចំណូលចិត្ត មនោគមន៍ ស្ថាប័ន មានជីវិតរហូតមកដល់សព្វ ថ្ងៃទោះបីប្រទេសជាតិឋិតក្នុងសភាពបែបណាក៏ដោយ ។

តាមអធិប្បាយរួចមកហើយ យើងបានបង្ហាញអំពីទំនាក់ទំនងនៃព្រលឹងទាំងបី គឺព្រលឹងបុគ្គល ព្រលឹងអក្សរសិល្ប៍ និងព្រលឹងជនជាតិ ។ តទៅទៀតយើងនឹងសាកល្បងសិក្សារកភាពដាច់គ្នានៃព្រលឹងទាំងបីនេះ :

## ៣-ភាពដាច់គ្នារវាងព្រលឹងទាំងបី

- ព្រលឹងបុគ្គលកើតមកពីការអប់រំ ឬពីកំណើត ប៉ុន្តែពេលបុគ្គលស្លាប់ ព្រលឹងធ្វើដំណើរទៅរកភពថ្មី ដោយពុំស្គាល់ព្រលឹងរបស់ខ្លួនទេ

- ព្រលឹងអក្សរសិល្ប៍ជាព្រលឹងរបស់សង្គមព្រោះអក្សរសិល្ប៍ ជាកញ្ចក់ឆ្លុះបញ្ចាំងសង្គមមនុស្សសម័យណាមួយ

- ព្រលឹងជនជាតិជាព្រលឹងធំជាងគេ ព្រោះតំណាងវប្បធម៌ និងអរិយធម៌របស់ជនជាតិដែលនៅគង់វង់ផុយពីបុគ្គល និងសង្គមដែលអាចផ្លាស់ប្តូរតាមធម្មជាតិ និងតាមបដិវត្តន៍ ។

**ពិភាក្សា :**

ពិតមែនតែមានភាពដាច់គ្នាក៏ ទំនាក់ទំនងរវាងព្រលឹងទាំងបីនេះ មានលក្ខណៈប្រសើរជាង ព្រោះព្រលឹងជនជាតិកើតមកព្រលឹងសង្គមដែលមានអក្សរសិល្ប៍ជាតំណាង ចំណែកព្រលឹងសង្គម
ក៏កើតមានមកពីព្រលឹងបុគ្គលម្នាក់ ៗ ដែរ ។

តើត្រូវធ្វើដូចម្តេចដើម្បីឲ្យព្រលឹងទាំងបីបានប្រសើរ ?

- ចំពោះព្រលឹងបុគ្គល គេត្រូវដុសខាត់ស្រាវស្រទេញ ដើម្បីឲ្យបុគ្គលមានពុទ្ធិគ្រប់គ្រាន់ ទើបអាចកសាងអំពើល្អ ស្អាតដៃ និងកិត្តិយសដែលអាចធ្វើឲ្យមរណានាមរបស់បុគ្គលមានជីវិតពុំសាបសូន្យទ ។

- ចំពោះព្រលឹងអក្សរសិល្ប៍ ដើម្បីឲ្យបានប្រសើរ អ្នកនិពន្ធគប្បីប៉ិនសរសេរការពិត ទោះបីអក្សរសិល្ប៍ត្រូវប្រកបដោយបច្ចេកទេសតាមសិល្ប៍វិធីរបស់ខ្លួនក៏ដោយ ក៏មិនត្រូវធ្វេសប្រហែសសច្ចភាពជាដាច់ខាតដូចជាសច្ចភាពនៃព្រឹត្តិការណ៍សម័យលង្វែកតាមរយៈ ប្រាកដភាពនៃរឿងទុំទាវរបស់ភិក្ខុសោម ។

- ចំពោះព្រលឹងជនជាតិ ដើម្បីដុសខាត់ព្រលឹងឲ្យបានប្រសើរគេត្រូវប៉ិនធ្វើបដិវត្តន៍រំលំព្រលឹងចាស់ ដែលឥតប្រយោជន៍ឬសសម័យខ្វះប្រសិទ្ធភាពសំរាប់ការលូតលាស់នៃវប្បធម៌ និងសង្គមធម៌ ដើម្បីកសាងព្រលឹងថ្មីស្របតាមសេចក្តីត្រូវការនៃប្រជាពលរដ្ឋព្រមទាំងស្របតាមចង្វាក់នៃវឌ្ឍនភាពសកលលោក ។

ដើម្បីធ្វើឲ្យព្រលឹងជនជាតិកាន់តែប្រសើរឡើង គេត្រូវថែរក្សាសម្បត្តិវប្បធម៌ និងអរិយធម៌របស់ជនជាតិនោះឲ្យនៅគង់វង់ ឯសម្បត្តិវប្បធម៌សំខាន់ជាងគេគឺ មនុស្ស ព្រោះមនុស្សជាអ្នកថែរក្សាសម្បត្តិ ហើយខ្លួនឯងជាសម្បត្តិវប្បធម៌ធម្មជាតិដូចជាសម្បត្តិវប្បធម៌ធម្មជាតិរបស់ខ្មែរគឺមនុស្សខ្មែរ ពីព្រោះបើមនុស្សខ្មែរចេះតែវិនាសបន្តិចម្តង ៗ ជនជាតិខ្មែរនឹងក្លាយទៅជាជនជាតិ

ភាគតិច ពុំមានសិទ្ធិការពារសម្បត្តិវប្បធម៌របស់ខ្លួន ដែលទ្រទ្រង់នូវព្រលឹងរបស់ខ្លួនបានទេ ។

បញ្ចប់សេចក្តី:

រួមសេចក្តីមក ព្រលឹងបុគ្គល ព្រលឹងអក្សរសិល្ប៍ ព្រលឹងជនជាតិ មានទំនាក់ទំនងគ្នាច្រើនជាងភាពដាច់គ្នា ហើយដើម្បីឲ្យព្រលឹងទាំងបីនេះបានប្រសើរ គេត្រូវចាប់ផ្តើមពីការ **អប់រំបុគ្គល** ឡើងទៅ ព្រោះបុគ្គលជាអ្នកបង្កើតព្រលឹងអក្សរសិល្ប៍ ដើម្បីអប់រំមនុស្សក្នុងប្រទេសណាមួយដែលរួមផ្តុំគ្នាជាជនជាតិ ។ បើព្រលឹងបុគ្គលប្រសើរ ព្រលឹងអក្សរសិល្ប៍ក៏ប្រសើរ យ៉ាងណាមិញព្រលឹងជនជាតិក៏រឹតតែប្រសើរឡើងដែរទើបរៀបចំសង្គមជាតិឲ្យមានយុត្តិធម៌ដែលគេហៅថាយុត្តិធម៌ក្នុងសង្គមមាន សមភាព សេរីភាព ភាតរភាព វឌ្ឍនភាព សុភមង្គល សមប្រកប តាមរបបប្រជាធិបតេយ្យ ។ *តើធ្វើដូចម្តេចទៅ បើសព្វថ្ងៃនេះ ខ្មែរម្នាក់ ៗ គិតតែប្រយោជន៍ផ្ទាល់ខ្លួន គេព្រងើយកន្តើយនឹងប្រយោជន៍ជាតិ តើកាលណាទៅ គេទទួលស្គាល់ព្រលឹងខ្មែរ ?* ប៉ុន្តែទោះបីយ៉ាងនេះក្តី យើងពុំត្រូវមាន *ទុទិដ្ឋិនិយមខ្លាំងពេកទេ យើងត្រូវភ្ញាក់រលឹកប្រកបដោយមនសិការជាតិ* ហើយបើចាប់ផ្តើមធ្វើបដិវត្តន៍ពីបុគ្គលទៅសង្គម ទៅជនជាតិពុំបានសំរេចទេ ត្រូវរៀបចំពីជនជាតិ មកសង្គមវិញរួចហើយពីសង្គមមកបុគ្គលម្នាក់ ៗ រហូតដល់បានសំរេចលទ្ធផលជាវិជ្ជាមាន ។

# ប្រជុំទស្សនវិទូខ្លះ

## + ពីតាគ័រ Pythagore ( ៥៧២ - ៥០០ មុន គ. ស )



ពីតាគ័រ ជាទស្សនវិទូ និងជាគណិតវិទូក្រិច ដែលបានចាប់ផ្តើមយកពាក្យ Philosophie មកប្រើមុនគេប៉ុន្តែលោកបានឲ្យន័យថា « ឆ្ពោះទៅរកការគតិបណ្ឌិត » ។

***ទស្សនវិជ្ជារបស់ ពីតាគ័រ :***

- ក្នុងពិភាពលោក អ្វីទាំងអស់សុទ្ធសឹងជាចំនួន ( Tout est nombre ) សូម្បីតែអាទិទេព ក៏កើតមកពីចំនួនដែរ ។ មនុស្សកើតមកពីចំនួនសាច់ផ្សំនឹងចំនួនឆ្អឹង ផ្សំចំនួនសរសៃ ផ្សំចំនួនឈាម ។

- យល់ថា មនុស្សស្លាប់ទៅហើយកើតវិញ ពោលគឺជឿថា ព្រលឹងជាធាតុ **អមតៈ** ។ ពេលព្រលឹងមកសណ្ឋិតនៅក្នុងសរីរៈបុគ្គល ព្រលឹងមានលក្ខណៈដូចជាជាប់គុកនៅក្នុងសរីរៈ រហូតដល់សរីរៈស្លាប់ទើបព្រលឹងអាចចេញពីសរីរៈបាន ។

- ចំនួនគឺខ្លឹម ( Essence ) អ្វី ៗ ដែលមានចំនួនទើបប្រកបដោយសច្ចភាព ។

- ភាវៈសំខាន់ជាងគេគឺភ្លើង ដែលជាប្រភពនៃពុទ្ធិហើយដែលពីតាគ័រ ដាក់តំណាងលេខ ( ១ ) ។ **តាឡេស** យល់ថា ទឹកជាភាវៈសំខាន់ជាងគេ ឯ**ព្រះពុទ្ធគោតម** យល់ថា ភាវៈសំខាន់ជាគេគឺមហាភូតទាំង៤ ទឹក ដី ភ្លើង ខ្យល់ ។ លេខ ( ២ ) តំណាងស្រី ឬសត្វញី លេខ ( ៣ ) តំណាងប្រុស ឬសត្វឈ្មោលដែលមានកម្លាំងជាងស្រី លេខ (៤) តំណាង

យុត្តិធម៌ លេខ (៥) តំណាង អាពាហ៍ពិពាហ៍ ( ២ + ៣ = ៥ ) លេខ ( ៧ ) តំណាង មនុស្ស ឥតបានការ លេខ ( ១០ ) តំណាង អាទិទេព ។

សីលធម៌របស់ពីតាគ័រ :

- គោរពអាទិទេព
- គោរពវីរជនជាតិ
- គោរពឪពុកម្តាយ
- មនុស្សទាំងអស់ គឺជាបងប្អូន
- តាំងជាម្ចាស់ចិត្តរបស់ខ្លួន
- ស្រឡាញ់យុត្តិធម៌
- អត់ធន់
- មានទ្រព្យសម្បត្តិល្មមតែរស់បានហើយ
- អំពើដែលធ្វើទៅហើយត្រូវរំលឹកឡើងវិញ ដើម្បីពិចារណាឲ្យដឹងខុសត្រូវ ។

## + អឺរ៉ាគ្លីត Héraclite ( ៥៤០ - ៤៨០ មុន គ. ស )



**ទស្សនវិជ្ជា :**

- អ្វីទាំងអស់ក្នុងធម្មជាតិត្រូវតែប្រែប្រួល
- បើមានកើតត្រូវតែមានស្លាប់
- ព្រះអាទិត្យថ្មីរាល់ថ្ងៃ
- -ភាវៈសំខាន់ជាងគេគឺភ្លើង
- អ្វីទាំងអស់កើតមកពីភាពផ្ទុយគ្នា

ឧទាហរណ៍៖ ដើម្បីកុំឲ្យត្រជាក់ ត្រូវរកកម្តៅ

ដើម្បីកុំឲ្យឃ្លាន ត្រូវរកអាហារមកចំអែត
ដើម្បីកុំឲ្យមានទុក្ខ ត្រូវរកសុខ

បង្កើតចលនាពិភពលោក

- គេពុំមុជទឹកពីឯងក្នុងទឹកទន្លេដដែលទេ
- គឺជាទស្សនវិជ្ជា ចលនានិយមសកល ឬទស្សនវិជ្ជាស្វែងរកអនាគត ដូចជាទស្សនវិជ្ជារបស់ព្រះពុទ្ធដែរ ។

## + ដេម៉ូគ្រីត Démocrite ( ៤៦០ - ៣៧០ មុន គ. ស )



**ទស្សនវិជ្ជា :**

ក្នុងពិភពលោក ភាវៈកើតមកពីវត្ថុធាតុអ្វីម្យ៉ាងល្អិត បំបែកពុំបាន ពុំប្រែប្រួល ឋិតថេរ រហូតដែលដេម៉ូគ្រីតឲ្យឈ្មោះថា **អាតូម** បង្កើតបានទ្រឹស្តីមួយឈ្មោះថា **អាតូមនិយម** ( l’ atomisme ) ។ អាតូម បង្កើតឲ្យមាន ភ្លៀង ខ្យល់ព្យុះ កម្តៅ ត្រជាក់ ក្លិន និង អ្វីសព្វយ៉ាង ទាំងអស់រហូតដល់ព្រះអាទិត្យ ព្រះចន្ទ ព្រលឹង ក៏កើតមកពីអាតូមដែរ ។ អាតូម ជាប្រភពនៃពុទ្ធិសព្វយ៉ាង ។

**សីលធម៌ :**

- មនុស្សត្រូវចេះសប្បាយ និងស្វែងរកការសប្បាយ
- L’ essential est resister au mal មានន័យថា សារៈសំខាន់ក្នុងការរស់នៅរបស់មនុស្សគឺ អាចទប់ទល់នឹងអំពើអាក្រក់សព្វបែបយ៉ាង
- Vain et sot de comparer son état avec celui d’un plus heureux que soi មានន័យថា កាលណាគេប្រៀបប្រដូចជីវភាព របស់គេទៅនឹងជីវភាពអ្នកប្រសើរជាងខ្លួន គេជាមនុស្សឥតបានការ និងជាមនុស្សឆ្កួត ។
- Il vaut micux obéir que commander មានន័យថា គោរពបញ្ជាប្រសើរជាងបញ្ជា ។
- Il vaut mieuz subir l’injustice que la commader មានន័យថា ទទួលអំពើអយុត្តិ

ប្រសើរជាងប្រសើរជាងប្រព្រឹត្តអយុត្តិធម៌ ។

- Eviter les querlles surtout avce ses proches មានន័យថា ត្រូវចៀសវាងជំលោះគ្រប់បែបយ៉ាងពិសេសជាមួយអ្នកនៅក្បែរខ្លួន ។
- Il faut avoir des smis  មានន័យថា ត្រូវតែមានមិត្តភក្តិច្រើន ។
- យើងត្រូវស្រឡាញ់គេដើម្បី ឲ្យគេស្រឡាញ់យើងវិញ មិនត្រូវបោះបង់សមត្ថភាព នៃការស្រឡាញ់ទេទោះបីដល់ចាស់ក៏ដោយ ។
- សុខចិត្តឲ្យមានមិត្តសម្លាញ់តិចចុះ មិត្តសម្លាញ់កើតឡើងដោយការជ្រើសរើស គួរជ្រើសរើសមិត្តសម្លាញ់ឲ្យបាហ្មត់ចត់ បើធ្វើទៅបាន គួរជ្រើសរើសសម្លាញ់ណា ដែលមានគោលបំណងសម្រេចប្រយោជន៍ដូចអ្នកដែរ ។
- ត្រូវមានសប្បុរសធម៌ ពុំមែនដើម្បីឲ្យបានគុណតបមកវិញទេ ប៉ុន្តែដើម្បីសប្បាយ ( ត្រូវគិតថាការធ្វើអំណោយអ្នកដទៃ ជាមធ្យោបាយដើម្បីសប្បាយ )
- ត្រូវគោរពចង្វាក់បី  មតិស្រម មតិផ្ទុយ មតិសំយោគ ដែលជាច្បាប់ដ៏ធំទ្រទ្រង់ដំណើរពិភពលោក ។

## + សូក្រាត Socrate ( ៤៧០ - ៣៩៩ មុន គ. ស )



### ទស្សនវិជ្ជារបស់សូក្រាត ច្រើនអប់រំបែបសីលធម៌ :

- ត្រូវយល់ដំណើរប្រព្រឹត្តទៅនៃធម្មជាតិ
- ត្រូវយល់អ្វីដែលនៅជិតយើងមុននឹងយល់អ្វីដែលនៅឆ្ងាយពីយើង
- ត្រូវស្គាល់ខ្លួនឯងសិន
- ត្រូវដុសខាត់ព្រលឹងឲ្យបានប្រសើរជាងដុសខាត់សរីរៈ
- ត្រូវនិយមប្រើថា ខ្ញុំឥតចេះអ្វីសោះ ហើយមិនត្រូវជឿថាគេចេះដែរ ខ្មែរទម្លាប់ប្រើពាក្យ « *បើចង់ចេះ ត្រូវធ្វើល្ងង់* »

- ត្រូវជជែកគ្នាដើម្បីរកការពិត ព្រោះការជជែកគ្នាបែបនេះត្រូវសូក្រាតឲ្យឈ្មោះថា វិធីបង្កើតកូន ដោយសូក្រាត ចេះណែនាំឲ្យអ្នកជជែក ជាមួយរកឃើញលទ្ធផលដោយខ្លួនឯង ។ លទ្ធផលដែលបានមកត្រូវទទួលការរិះគន់សិនទើបទុកជាបានការ បើពុំដូចនោះទេ សូក្រាតនឹងប្រើវិធី **ចំអក** ដែលគេឲ្យឈ្មោះថា ចំអកបែបសូក្រាត

- សូក្រាតពោលថា ពុំមាននរណាម្នាក់កាចដោយចេតនាទេ ។ ទ្រឹស្តីនេះមានន័យថា មនុស្សកើតមកសុទ្ធតែមានបំណងល្អ ហើយភាពស្លូតបូតគឺជាសម្បត្តិរបស់មនុស្ស ប៉ុន្តែបើប្រែជាកាចវិញ គឺពិតជាមានបុព្វហេតុ ដូចជាបុព្វហេតុផ្ទាល់ខ្លួន និងបុព្វហេតុក្រៅខ្លួន ។ បុព្វហេតុផ្ទាល់ខ្លួន គឺភាពកាចសាហាវកើតមកពីសុខភាពពុំសូវល្អ សរីរាង្គពុំប្រក្រតី សរសៃប្រព័ន្ធប្រសាទឋិតនៅក្នុងកន្លែងប្លែកពីធម្មតា ទើបបណ្តាលឲ្យបុគ្គលកាចដោយពុំដឹងខ្លួន ហេតុនេះ គេអាចព្យាបាលជម្ងឺកាចតាមថ្នាំសង្កូវ ។ បុព្វហេតុក្រៅខ្លួន មានបែបផែនជាពុទ្ធិវត្ថុ ដូចជាពុទ្ធិប្រធានជួបប្រទះនឹងអំពើអយុត្តិធម៌ ការសង្កត់សង្កិន ការរំលោភឈ្លានពាន និងជួបប្រទះបញ្ហាអ្វីមួយដែលខ្លួនពុំចូលចិត្ត ក៏បណ្តាលឲ្យពុទ្ធិប្រធានក្លាយទៅជាមនុស្សកាច ។ ប្លាតុង បានប្រឆាំងនឹងគំនិតនេះដោយអះអាងថាមនុស្សកើតមកមានអកប្បកិរិយាប្លែកគ្នា ខ្លះល្អខ្លះអាក្រក់ ខ្លះកាចខ្លះស្លូត ស្របតាមនិស្ស័យ
យ
ធម្មជាតិ របស់មនុស្ស នេះហើយជាច្បាប់ធម្មជាតិ ។ ដូចនេះប្លាតុង ពុំទទួលស្គាល់ថា មនុស្សកើតមកសុទ្ធតែស្លូតទាំងអស់ដូចសូក្រាតពោលទេ ។

- ក្នុងតម្លៃសីលធម៌ សូក្រាតបានចេញមុខប្រឆាំងនឹងពួកសូហ្វីស ដោយចាត់ទុកថាពួកសូហ្វីស ចូលចិត្តយកពាក្យសំដី ទៅប្រើក្នុងផ្លូវខុស ហើយធ្វើអកប្បកិរិយាដូចជាអ្នកចេះច្រើន ។

## + ប្លាតុង Platon ( ៤២៨ - ៣៤៨ មុន គ. ស )



ប្លាតុង ជាទស្សនវិទូក្រិច ដែលល្បីឈ្មោះជាងគេ ព្រមទាំងមានកម្រិតពុទ្ធិខ្ពស់ជាង

សូក្រាត ។ ប្លាតុង មានគ្រូ ៣នាក់ គឺ ក្រាទីល អេរ៉ាគ្លីត និង សូក្រាត ។ ប្លាតុង ចូលចិត្តធ្វើដំណើរ និង ធ្វើនយោបាយព្រមទាំងជាអ្នកផ្តើមបង្កើតគំនិតបណ្ឌិតសភា នៅឆ្នាំ ៣៨៧ មុន គ.ស ប្លាតុង និយមប្រើវិធីបង្កើតគំនិត និងវិធីចំអកដូចសូក្រាតដែរ ។

ពេលកាត់ទោសប្រហាជីវិតសូក្រាត នៅឆ្នាំ ៣៩៩ ប្លាតុងបានរត់ភៀសខ្លួនចេញពីអាតែន ។

**ទស្សនវិជ្ជាប្លាតុង :**

- ប្លាតុង បានបង្កើតទ្រឹស្តីអំពី ឥន្ទ្រិយ ភព និងទ្រឹស្តីអំពី មនោភព ។ ឥន្ទ្រិយ ភព គឺជា ភពនៃពុទ្ធិ ដែលបុគ្គលបានចេះដឹងត្រឹមតែទំនួល អារម្មណ៍ តាមឥន្ទ្រិយារម្មណ៍ ពោលគឺពុទ្ធិ ដែលកើតមកពីភ្នែក ច្រមុះ ត្រចៀក អណ្តាត កាយ និង ចិត្ត ប៉ុន្តែខ្លះគំនិត ។ ចំណែក ឯមនោភព គឺជាភពនៃពុទ្ធិដែលបុគ្គលបានចេះដឹង ដោយសារមនោ ( គំនិត + បញ្ញា + វិចារណ: ) ប៉ុន្តែប្លាតុង ពុំបានផ្តាច់ឥន្ទ្រិយភព ចេញពីមនោភពទេ ។ ពុទ្ធិចាប់ផ្តើមពីឥន្ទ្រិយភព និងមានតម្លៃច្បាស់លាស់ នៅលើមនោភព ។ បើពុទ្ធិមានកម្រិតត្រឹមតែឥន្ទ្រិភព គឺពុទ្ធិក្លែងក្លាយ ព្រោះពុទ្ធិក្នុងឥន្ទ្រិយភព រមែងប្រែប្រួលតាមកាលអាកាស ដូចជាការវិនិច្ឆ័យត្រឹមតែការមើលឃើញដឹងឮពុំគ្រប់គ្រាន់ទេ ត្រូវបន្ថែមសមត្ថភាព ៣ ប្រការរបស់មនោគឺ គំនិត បញ្ញា និង វិចារណ: ។ បដិសំយោគរវាងឥន្ទ្រិយភព និងមនោភព ជាប្រភពនៃទស្សនវិជ្ជាជំនាន់ក្រោយបានសេចក្តីថា ទស្សនវិជ្ជាក្រោយតែងបានលើកយក ភព ទាំងពីរជាវត្ថុសិក្សា គ្រាន់តែមតិមួយឲ្យតម្លៃលើឥន្ទ្រិយភព ខ្លាំងជាង ឯមតិមួយទៀតឲ្យតម្លៃលើមនោភពខ្លាំងជាង ។

- ឥន្ទ្រិយភព ពុំមានសមត្ថភាពស្វែងរកបណ្តាច់បានទេ ចំណែកឯមនោភពទើបអាចស្វែងរកបណ្តាច់បាន ព្រមទាំងអាចស្វែងរកសច្ច:បណ្តាច់បានទៀតផង ។

- ប្លាតុង បានបង្កើតទស្សនវិធីមួយឈ្មោះ បដិសំយោគ ដើម្បីជជែកឆ្លើយឆ្លងគ្នាស្វែងរកពុទ្ធិ ។

*បដិសំយោគជាអ្វី ?*

បដិសំយោគជាទស្សនវិធីមួយ ដែលតម្រូវឲ្យលើកយកទស្សន: ទាំងពីរដោយចេះផ្តាច់គ្នាផង ភ្ជាប់គ្នាផងដើម្បីស្វែងរកតម្លៃពិតប្រាកដ ។

- ទ្រឹស្តីអំពីអនុស្សារណ: អនុស្សារណ:ជាការរំឭកឡើងវិញនូវអំពើផ្សេង ៗ ដែលយើងបានធ្វើរួចមកហើយ ដើម្បីវិនិច្ឆ័យថា អំពើណាជាអំពើល្អ អំពើណាជាអំពើអាក្រក់ ។ អនុស្សារណ:

ជាវិធីស្វែងរកគុណធម៌ខ្ពង់ខ្ពស់ ព្រោះមនុស្សម្នាក់ៗ ត្រូវតែមានការវិនិច្ឆ័យផ្ទាល់ខ្លួន ឯការវិនិច្ឆ័យ

កើតមកពីមនសិការ ។ ការទំលាប់ធ្វើអនុស្សាវរណៈយូរ ៗ ទៅ អាចឲ្យពុទ្ធិប្រធានរំឭកឃើញអតីតកាល ដ៏យូរអង្វែងព្រមទាំងជាព្រភពទ្រឹស្តីចាំជាតិ ( ប្រហែលគ្នានឹងទ្រឹស្តីចាំជាតិរបស់ព្រះពុទ្ធគោតមដែរ ) ព្រោះកាលណាអនុស្សាវរណៈ មានកម្រិតកាន់តែខ្លាំងឡើង ៗ រហូតដល់បុគ្គលអាចផ្តាច់ខ្លួនបាន ពេលនោះបុគ្គលអាចយកអនុស្សាវរណៈមកអនុវត្ត ដើម្បីដឹងជាតិរបស់ខ្លួន ។ អាស្រ័យហេតុនេះហើយបានជាប្លាតុងពោលថា « រៀនទស្សនវិជ្ជា គឺរៀនស្លាប់ » មានន័យថា រៀនផ្តាច់ព្រលឹងចេញពីសរីរៈ ។ កាលណាបុគ្គលម្នាក់ពុំអាចផ្តាច់ព្រលឹងចេញពីសរីរៈ បានទេនោះ តាមប្លាតុង បុគ្គលនោះពុំអាចសិក្សាទស្សនៈវិជ្ជាបានឡើយ ។

- អំពីអមតភាពនៃព្រលឹង តាមទ្រឹស្តីអនុស្សាវរណៈ ប្លាតុងយល់ឃើញថា បុគ្គលជាការផ្សំរវាងសរីរៈ + ព្រលឹង ។ សរីរៈជា សំខតធាតុ ទេ ឯព្រលឹងជាស្ថូល ។ ហេតុនេះ ព្រលឹងពុំមែនជាសំខតធាតុទេ ហើយពុំចេះរលាយពុំចេះស្លាប់ ផ្ទុយពីទស្សនៈរបស់ព្រះពុទ្ធដែលយល់ថា បុគ្គលម្នាក់

ៗ ពុំមានព្រលឹងទេ ។ អ្វីទាំងអស់ដែលទ្រទ្រង់បុគ្គលគឺជា សំខតធាតុ ហេតុនេះ ត្រូវតែផ្លាស់ប្តូរនិង

រលាយទៅវិញ រួចហើយកើតវិញទៀត ។ វិទ្យាសាស្រ្តទំនើបដែលអាចកសាងរូបរាងមនុស្សដូចបេះបិទ មានសរសៃ សាច់ ឈាម ខួរក្បាល បេះដូង សួតដូចមនុស្សធម្មតា ម្តេចក៏មនុស្សប្រភេទនេះដែលកើតឡើងដោយការផ្សំប្រាសចាកវិញ្ញាណ ឥតដឹងអ្វីទាំងអស់ ឥតចេះនិយាយស្តី ប្រើការពុំកើត ជាការបញ្ជាក់ថាបុគ្គលម្នាក់ ៗ ពុំមែនគ្រាន់តែមាន សំខតធាតុ ឬ ខ័ន្ធ ប៉ុណ្ណោះទេ គឺពិតជាមានអ្វីមួយពុំប្រែប្រួលដែលជាស្ថូលរបស់បុគ្គល ចំណែកឯទ្រឹស្តីរបស់ព្រះពុទ្ធគោតម ដែលអះអាងថាក្នុងគោលលទ្ធិមួយអំពី អនត្ត ពុំព្រមទទួលស្គាល់ថា មានព្រលឹង ក៏ពុំប្រាកដជាទ្រឹស្តីដែលជួបប្រទះពិសោធន៍ច្បាស់លាស់នៅឡើយ គឺគ្រាន់ជាការវាយស្ទានតាមទស្សនៈប្រហាក់ប្រហែលនិយម ។

## + អារីស្តូត Aristote (៣៨៤ - ៣២២ មុន គ. ស )



លោក អារីស្តូត ជាទស្សនវិទូក្រិចកើតនៅឆ្នាំ ៣៨៤ មុន គ.ស នៅទីក្រុង Thrace ហើយស្លាប់នៅឆ្នាំ ៣២២ មុន គ.ស ។ អារីស្តូត ជាសាវ័ក ជំនិតរបស់ប្លាតុង ។ ឪពុកលោកជា គ្រូពេទ្យផ្ទាល់របស់ស្តេច Philippe ។

អារីស្តូតជាអ្នកផ្តួចផ្តើម បង្កើតសព្វវិជ្ជា ដោយប្រើមធ្យោបាយទាក់ទងផ្ទាល់ខ្លួននឹងស្តេច Philippe ដើម្បីចេញបទបញ្ជាដល់អ្នកនេសាទទាំងឡាយ ព្រានប្រមាញ់សត្វស្លាប និងសត្វព្រៃព្រមទាំងសត្វទាំងពួងដែលចាប់បាន ឲ្យយកគំរូនីមួយ ៗ ប្រគល់មកអារីស្តូត ដើម្បីរៀបចំសព្វវិជ្ជា ពោលគឺ អារីស្តូតរៀបចំសព្វវិជ្ជាចាប់តាំងពីសត្វឡើងទៅ ព្រោះសត្វច្រើនណាស់ដែលកើតនៅក្នុងស្រុកតែពុំមានស្គាល់ឈ្មោះ ។

នៅឆ្នាំ ៣៣៥ អារីស្តូតបានបង្កើតវិទ្យាល័យមួយ នៅក្រុងអាតែនដែលគេទំលាប់ហៅថា Lycien ។ វិធីបង្រៀននៅក្នុងវិទ្យាល័យនេះមានលក្ខណៈផ្សេងពីវិទ្យាល័យដទៃទៀត ដោយមានការរៀបចំឲ្យគ្រូបង្រៀនសិស្សនៅក្រៅថ្នាក់ច្រើន ជាងនៅក្នុងថ្នាក់ គឺដើរលេងបណ្តើរ បង្រៀនបណ្តើរ ។ ទស្សននិយមការសិក្សាដោយមធ្យោបាយដើរលេងបំបែបនេះមានឈ្មោះថា កំសាន្តសិក្សា ។

## ទស្សនវិជ្ជារបស់អារីស្តូត :

ដោយអារីស្តូត ជាសាវ័ក របស់ប្លាតុង ពោលគំនិតសំខាន់ ៗ ខ្លះក្នុងទស្សនវិជ្ជាទាក់ទងនឹងប្លាតុង ដូចជាទ្រឹស្តីអំពីឥន្ទ្រិយភព ឆ្ពោះទៅរក មនោភព ដើម្បីស្វែងរកកុសល ។ ទស្សនវិជ្ជា បែបនេះត្រូវអារីស្តូតហៅថា **ទស្សនវិជ្ជាអស្តិរូប** ។

អារីស្តូតបានបញ្ជាក់ថា ប្លាតុងយល់ថា មានគំនិតខ្ពង់ខ្ពស់ឋិតដាច់ចេញពីឥន្ទ្រិយភព ប៉ុន្តែចាប់ផ្តើមពីឥន្ទ្រិយភព ។ អារីស្តូត យល់ប្លែកពីប្លាតុងបន្តិចដោយអះអាងថា មនោភព ក៏ឋិតនៅក្នុងឥន្ទ្រិយភពដែរ មានន័យថា នៅក្នុងភាវៈមួយ គេអាចបំបែកគំនិតពីរយ៉ាង :

- គំនិតទាំងឡាយដែលទាក់ទងទៅនឹងឥន្ទ្រិយ
- គំនិតទាំងឡាយដែលទាក់ទងទៅនឹងមនោ

ប៉ុន្តែឥន្ទ្រិយនិងមនោឋិតនៅរួមគ្នា គ្រាន់តែគំនិតមួយបង្ហាញអ្វីដែលយើងឃើញពេលបច្ចុប្បន្ន និងគំនិតមួយទៀតមានទំនោរទៅរកអនាគត ។

អារីស្តូត បានលើកយកភស្តុតាងមកបញ្ជាក់ដូចជា គ្រាប់ផ្លែឈើ ដែលយើងឃើញក្នុងក្នុងបច្ចុប្បន្ន ទៅអនាគតជាមនុស្សចាស់ មនុស្សកំពុងដេក មុខជាភ្ញាក់នៅពេលខាងមុខ ។ តាមការអធិប្បាយខាងលើនេះទស្សនៈរបស់អារីស្តូតអាចបង្កើត បានទស្សនវិជ្ជាមួយថ្មីទៀតដែល

ឲ្យតម្លៃទៅលើតម្លៃ លើចលនាប្រែប្រួល ។

ដើម្បីបញ្ជាក់ទស្សនៈខាងលើនេះឲ្យបានច្បាស់លាស់គឺ ទស្សនៈភ្ជាប់ឥន្ទ្រិយ និងមនោ ឲ្យ ឋិតនៅក្នុងភពតែមួយ អារីស្តូតយល់ថា គំនិតល្អ គំនិតកុសល ឋិតនៅជាមួយនឹងភាវៈ ទើបលោក លើកយកធាតុ ២ នៃទស្សនៈរបស់លោកមកបង្ហាញគឺទ្រឹស្តីអំពីរូបធាតុ និង រាង ។

**រូបជាអ្វី ? រាងជាអ្វី ?**

រូប គឺជារូបធាតុមួយជាបុព្វហេតុបង្កើតភាវៈផ្សេង ៗ ដែលទស្សនវិជ្ជាបានវិភាគរួចមក ហើយ

ចាត់ទុកថា រូបធាតុមានតម្លៃច្បង ព្រោះបានបង្កបង្កើតភាវៈ ដូចជាទស្សនវិទូខ្លះថា រូបធាតុសំខាន់ ជាងគេគឺភ្លើង ឬកម្តៅ ខ្លះថាទឹក ខ្លះថាខ្យល់ ជារូបធាតុបង្កើតចលនា ចំណែកឯព្រះពុទ្ធប្រមូលផ្តុំ រូបធាតុទាំង៤ គឺ ទឹក ដី ភ្លើង ខ្យល់ ជាការបញ្ជាក់ថា ទស្សនវិជ្ជាបែបនេះឲ្យតម្លៃលើរូបធាតុសំខាន់ ជាងអ្វីទាំងអស់ ។

រាង សំគាល់ទំរង់ខាងក្រៅ ដែលភាវៈបានបង្កើតរួចស្រេច គឺជាបំណងចុងក្រោយ ជា សេចក្តីសេចក្តីត្រូវការរបស់មនុស្សទើបអារីស្តូតលើកយកហេតុ ២ មកបង្ហាញ :

- ហេតុកណ្តាល
- ហេតុបញ្ចប់

អារីស្តូតបញ្ជាក់ថា ទស្សនវិទូខ្លះច្រឡំយកហេតុកណ្តាលជាហេតុសំខាន់ជាងគេ តាមពិតគឺ ហេតុបញ្ចប់នេះវិញទេជា ហេតុសំខាន់ជាង ។ ហេតុកណ្តាល គឺរូបធាតុ ដូចជាធាតុផ្សំឲ្យកើតទៅជា ភាវៈ ។

ឧទាហរណ៍ ៖ កំណាត់សំពត់ផ្សេង ៗ ។

ហេតុបញ្ចប់ដែលជាបំណងសំខាន់ជាងគេ គឺរាងរបស់ភាវៈ ដូចជាកំណាត់សំពត់កាត់បាន ជា ខោ និង អាវ ។ ខោ និង អាវ នេះហើយដែលសំខាន់ជាងគេ ។ ដើម្បីឲ្យស្គាល់ថា នេះខោ នេះ អាវ គឺពុំមែនរូបធាតុទេ ប៉ុន្តែគឺជា រាង ដែលជាសារធាតុសំខាន់បំផុត យ៉ាងណាមិញ ដូចជារាង របស់គោអាចធ្វើឲ្យគេស្គាល់ថាជាគោ រាងរបស់ក្របី ផ្ទះ មនុស្ស ... ទ្រឹស្តីបែបនេះមានឈ្មោះថា ទ្រឹស្តីអំពីរាង ។

ដោយហេតុថា រាងជាហេតុបញ្ចប់ និងគោលបំណងរបស់មនុស្ស ទើបអារីស្តូតពន្យល់ថា រាងនេះហើយជាអាទិទេព ព្រោះតំណាងកុសល តំណាងសោភ័ណ ពោលគឺតំណាងអ្វីដែលល្អ ។ ដូចនេះហើយរូបធាតុ អាចបង្កើតរាងបាន រាងនេះហើយដែលអារីស្តូតយល់ថា អាទិទេព ហាក់ បញ្ជាក់ថា ភាវៈមួយមានអាទិទេពមួយសំរាប់ថែភាវៈនោះ ទៅរកសោភ័ណ និងកុសល ។ តាម

សេចក្តីរួចមកហើយនេះ អាទិទេព ហាក់ដូចជាមានភាពពុំច្បាស់លាស់ ស្រពិចស្រពិល ហាក់ដូចជាមានផង ពុំបានផង ទើបគេបង្កើតបានទ្រឹស្តីមួយឈ្មោះ « ស្រពិចស្រពិលនិយម » ។

បន្ទាប់ពីទ្រឹស្តីអំពីរាង អារីស្តូតបានបង្កើតទ្រឹស្តីមួយទៀតបានឈ្មោះថា ត្រ័យវាទនិយម ។

ត្រ័យវាទនិយម : ជាទ្រឹស្តីដែលប្រកបដោយប្រយោគ ៣ ទើបមានន័យដូចជា ៖

- មនុស្សទាំងអស់ត្រូវតែស្លាប់ ( ប្រយោគច្បង )
- សូក្រាតក៏ជាមនុស្ស ( ប្រយោគរង )
- ដូចនេះសូក្រាតត្រូវតែស្លាប់ ( យោបល់ )

នេះជាត្រ័យវាទនិយមបែបសព្វថ្ងៃឯកវិធី ៖ សព្វ → ឯក

- សូក្រាតត្រូវតែស្លាប់
- សូក្រាតក៏ជាមនុស្ស
- ដូចនេះមនុស្សទាំងអស់ត្រូវតែស្លាប់

បញ្ជាក់ គោលបំណងរបស់អារីស្តូត ដែលបានបង្កើតទ្រឹស្តីត្រ័យវាទនិយម គឺចង់រក្សាឈ្មោះសូក្រាត ឲ្យឋិតក្នុងភាព អមតៈ ព្រោះអារីស្តូត បានជ្រើសរើសយកឈ្មោះសូក្រាតជារូបធាតុដើម និងជាប្រធាននៃទ្រឹស្តីនេះ ។ ម្យ៉ាងទៀតគឺបំណងមិនចង់ឲ្យសាវ័កទាំងឡាយ ដែលនៅជាប់ជំពាក់ផ្លូវសញ្ជេតនាជាមួយសូក្រាត នៅស្រណោះសូក្រាតខ្លាំងពេក ព្រោះធម្មតាមនុស្សពុំអាចចៀសរួចពីសេចក្តីស្លាប់បានឡើយ គ្រាន់តែមួយស្លាប់ក្នុងកិត្តិយស មួយទៀតស្លាប់គ្មានន័យ ។ ចំណែកឯសូក្រាតពិតជាស្លាប់ក្នុងកិត្តិនាមល្បីល្បាញ ព្រោះរហូតមកដល់សព្វថ្ងៃនេះកេរ្តិ៍ឈ្មោះរបស់សូក្រាតឋិតនៅជា អមតៈ ។

## សីលធម៌របស់អារីស្តូត :

សីលធម៌របស់អារីស្តូត គឺជាគុណធម៌ផ្លូវកណ្តោល ឬ មជ្ឈិមមគ្គ ៖

- កុំក្លាហានពេក កុំកំសាកពេក
  + សេចក្តីក្លាហាន
- កុំចង់បានពេក តែមិនត្រូវមិនរវីរវល់សោះទេ
  + សេចក្តីប្រមាណ
- បំភ្លេចប្រយោជន៍ខ្លួន តែមិនត្រូវតាំងចិត្តជាអត្តទត្តទេ
  + យុត្តិធម៌

បន្ទាប់មកទៀត អារីស្តូតបានលើកយកសីលធម៌ផ្សេង ៗ មកពន្យល់ :

សីលធម៌របស់រដ្ឋ គឺការចៀសវាងដាច់ខាតមិនឲ្យអំណាចរដ្ឋ បង្ខិតបង្ខំពលរដ្ឋ ឲ្យធ្វើអ្វីមួយដែលគេមិនពេញចិត្ត ។

ហេតុនេះ អំណាចរដ្ឋសព្វថ្ងៃដែលបង្ខិតបង្ខំពលរដ្ឋឲ្យធ្វើទាហាន ដែលគេមិនពេញចិត្ត បញ្ជាក់ថារដ្ឋប្រាសចាកសីលធម៌ ។

- សីលធម៌ម្យ៉ាងទៀតឋិតនៅត្រង់អារីស្តូតបញ្ជាក់ថា កើតមកជា មនុស្សត្រូវតែចេះធ្វើនយោបាយ ឯអ្នកពុំចេះធ្វើនយោបាយគឺជាសត្វ ។
- សីលធម៌ អប់រំឲ្យចេះស្រឡាញ់មនុស្សជាតិ
- សីលធម៌គាំទ្រអ្នកចេះដឹងទាំងឡាយ ដែលគេចាត់ទុកថាជាបណ្ឌិត ទោះបីមានកំហុសមានកំហុសដូចម្តេចក៏ដោយ ច្បាប់រដ្ឋត្រូវចៀសវាងការប្រហារជីវិត មនុស្ស ។ អារីស្តូត រំលើកឡើងវិញ នូវអនុស្សាវរីយដ៏អាប់អួរក្នុងពេលប្រហាជីវិតសូក្រាត ។

ហេតុនេះ ការប្រហារជីវិតនិសិត្ស សិស្សនិងបុគ្គលិកគ្រូបង្រៀនកាលព្រឹត្តិការណ៍ ១៧ មីនា ១៩៧៣ ជាឧក្រិដ្ឋកម្មមួយដ៏ជូរចត់នៅប្រទេសខ្មែរ ។

## + មជ្ឈធាតុនិយម



អ្នកបង្កើតទ្រឹស្តីនេះ ឈ្មោះ ពារ៉ុង Pyrrhon ( ៣៦៥ - ២៧៥ មុន គ. ស ) ។

លោក ពារ៉ុង បានពន្យល់ថា បញ្ហាមនុស្សឋិតនៅក្នុងភាព អាថ៌កំបាំង មិនត្រូវជឿថាមនុស្សណាម្នាក់ ស្រឡាញ់ដោយស្មោះត្រង់ទេ ឯបុគ្គលខ្លួនឯងក៏មិនត្រូវទុកចិត្តលើខ្លួនឯងដែរ ទើបលោកនិយមប្រើពាក្យថា « *កុំបញ្ជាក់ពីអ្វីឲ្យសោះ និងកុំនិយាយការពិតឲ្យសោះ* » ។ លោក ពារ៉ុង ពោលទៀតថា « *ត្រូវចាត់ទុកសច្ចភាព គ្រាន់តែជាទំលាប់មួយ* » ។

ឧទាហរណ៍៖ រសជាតិទឹកឃ្មុំ សំរាប់ខ្លួនឯង មិនត្រូវចាត់ទុកថាមនុស្សទាំងអស់ សុទ្ធតែចូល
ចិត្តទឹកឃ្មុំនោះទេ ចំណែកឯអ្នកចូលចិត្តទឹកឃ្មុំថ្ងៃនេះ ពុំមែនមានន័យថាថ្ងៃស្អែកក៏ចូលចិត្តទឹកឃ្មុំដែរនោះទេ ។

ដើម្បីទ្រទ្រង់ទ្រឹស្តីនេះឲ្យបានច្បាស់លាស់ លោកពារ៉ុង អប់រំមនុស្សឲ្យចេះប្រុងប្រយ័ត្ននិងសង្ស័យជាឯរាបដូចជា ៖

- ពេលទៅលេងលើភ្នំ មិនត្រូវគិតថាភ្នំមិនចេះបាក់នោះទេ ។
- ពេលឡើងដើមឈើ មិនត្រូវគិតថា មែកឈើមិនចេះបាក់នោះឡើយ ។
- ពេលឡើងជិះរទេះ មិនត្រូវគិតថាកង់រទេះមិនចេះរបូតនោះដែរ ។

បន្ទាប់មកទៀត ទ្រឹស្តីមជ្ឈធាតុនិយម ប្រឆាំងនិងបណ្តាច់ ពោលគឺមិនត្រូវជឿថាមានអ្វីដែលខ្ពង់ខ្ពស់ដាច់គេ ប្រសើរជាងគេ ល្អជាងគេ ឬអាក្រក់ជាគេ មានន័យថាអ្វីទាំងអស់តែងតែមានល្អ មានអាក្រក់លាយឡំគ្នា ព្រមទាំងត្រូវយល់អ្វីដែលគ្រាន់តែប្រហាក់ប្រហែលបានហើយ ទើបទ្រឹស្តីរបស់ ពារ៉ុង បង្កើតបានចលនាទស្សនវិជ្ជាមួយឈ្មោះ *«ទ្រឹស្តីប្រហាក់ប្រហែលនិយម»* ។

## + ដេកាត Descarte ( ១៥៩៦ - ១៦៥០ )



ដេកាត ជាទស្សនវិទូ ដែលបានទុកស្នាដៃច្រើនដូចជា :

- ស្នាដៃវិទ្យាសាស្ត្រក៏មានច្រើនដែរ ពិសេសត្រង់ដេកាត យល់ស្របតាម ក្លាលីលេ ដែលរកឃើញថា ផែនដីវិល ។ កំពុងតែរៀបចំបោះពុម្ពសៀវភៅមួយឈ្មោះ Traite du monde មានន័យថា ក្បួនបំភ្លឺអំពីពិភពលោក ហើយក្នុងស្នាដៃនោះ លោកក៏បានរកឃើញថា ផែនដីវិលដែរ ស្រាប់តែនៅឆ្នាំ ១៦៣៣ តុលាការកាត់ទោសប្រហារជីវិតលោក ក្លាលីលេ ដែលបានសរសេរផ្សាយផ្ទុយនឹងសាសនាគ្រីស្តថា ផែនដីវិល ។ ការផ្សាយដំណឹងបែបនេះ អាចធ្វើឲ្យខូចតម្លៃ

សាសនា ហើយធ្វើឲ្យគ្រិស្តបរិស័ទ រសាយជំនឿពីសាសនាទៀតផង ។ ដេកាត ត្រូវបង្ខំចិត្តផ្អាក ការផ្សាយ ស្នាដៃនោះ ។

## ទស្សនវិជ្ជា :

ទស្សនវិជ្ជារបស់ដេកាតមានឈ្មោះថា ដេកាតនិយម ដែលជាប្រព័ន្ធទស្សនវិជ្ជា វិចារណនិយម ជុំវិញការចោទ និងដោះស្រាយបញ្ហាប្រកបដោយវិចារណៈដូចជា ៖

- វិចារណនិយមអំពីឯកសព្វភាព
- វិចារណនិយមអំពីសព្វឯកភាព
- វិចារណនិយមអំពី សហជញ្ញាណ

ដេកាត យល់ថាមមានខ្លឹម ជាហេតុដឹកនាំឲ្យដេកាតយល់ថាមានអាទិទេព ឯវត្ថុមានយល់ អាទិទេពកើតឡើងតាមការពិចារណា ដូចជាការពិចារណាមួយមានឈ្មោះ បើធម្មជាតិកើតមាន ឡើង ត្រូវតែមានអ្នកបង្កើត ឯអ្នកបង្កើតនោះគឺជាអាទិទេព ។

ចំពោះបញ្ហាបុគ្គល ដេកាតពន្យល់ថាបុគ្គលជាការផ្សំរវាងសរីរៈ និងព្រលឹង ហើយ ធាតុទាំងពីរនេះ មានសម្ព័ន្ធដ៏ជិតស្និទ្ធទៅវិញទៅមក មានន័យថា បើសរីរៈចង់បានអ្វីព្រលឹងក៏ចង់ បាននោះដែរ យ៉ាងណាមិញបើព្រលឹងប្រាថ្នាអ្វី ក៏បញ្ជាឲ្យសរីរៈធ្វើអំពើនោះដែរ ហេតុនេះបើខុស គឺខុសទាំងអស់គ្នា បើត្រូវគឺត្រូវទាំងអស់គ្នា មានន័យថាអំពើទាំងឡាយរបស់មនុស្ស សុទ្ធសឹង ប្រព្រឹត្តទៅប្រកបដោយឆន្ទៈ ខុសពីទស្សនវិជ្ជាសព្វថ្ងៃ ដែលចែកឆន្ទៈជា ៣ ផ្នែកគឺ ៖ ឆន្ទកម្ម បដិឆន្ទៈ និង ឆន្ទៈ ។

សីលធម៌ របស់ដេកាត ឋិតនៅត្រង់ដេកាតអប់រំឲ្យចេះសព្វគ្រប់ដើម្បីស្វែងរក សច្ចភាព ។

## + ជនលោក John Locke ( ១៦៣២ - ១៧០៤ )



ជនលក ជាទស្សនវិទូអង់គ្លេសដែលចាប់ផ្តើមមានគំនិតទស្សនវិជ្ជាពីអាយុ ៣៨ឆ្នាំ ។ ពីមុនជនលក ស្អប់ទស្សនវិជ្ជាខ្លាំងណាស់ លោកចូលចិត្តរស់នៅតាមធម្មតាដូចគេដូចឯង និងមិនចូលចិត្តនិយាយទ្រឹស្តីណាដែលទាក់ទនឹងទស្សនវិជ្ជា ជាហេតុបណ្តោលឲ្យ ជនលក ស្អប់ដេកាត ប្រឆាំងនិងទ្រឹស្តីរបស់ដេកាតនៅក្នុងបរិយាកាសមួយ ដែលមតិមហាជនកំពុងតែសរសើរដេកាត ។

ជនលក ខំសរសេរយ៉ាងច្រើនដើម្បីរកភស្តុតាងប្រឆាំង នឹងទស្សនវិជ្ជាដេកាត ។ ស្នាដៃទាំងឡាយដែល ជនលក ខំផ្ចិតផ្ចង់បានធ្វើឲ្យ ជនលក ក្លាយជាទស្សនវិទូដោយពុំដឹងខ្លួន ។

### ទស្សនវិជ្ជារបស់ជនលក :

គឺជាប្រព័ន្ធទស្សនវិជ្ជាពិសោធនិយម ព្រោះជនលក ប្រឆាំងនឹងដេកាតដោយយកការការពិសោធជាធំ ស្របគ្នានឹងគំនិតរបស់ប្លាតុងដែរ ។ ហើយប្រឆាំងនឹងពុទ្ធិពីកំណើត ដោយអះអាង

ថាមនុស្សកើតមកឥតចេះដឹងអ្វីទាំងអស់ក្រៅពី សភាវគតិ របស់ខ្លួន ទើបជនលក បង្កើតទ្រឹស្តីមួយរបស់ខ្លួន ថា« ក្មេងកើតមកដូចជាទំព័រក្រដាស ស ដែលគេអាចគូសវាស ផាត់ពណ៌លើក្រាដាសនោះតាមចិត្តចង់ » ។ គំនិតនេះបានធ្វើឲ្យ ជនលក ក្លាយជាគរុកោសល្យវិទូ ដោយហេតុជនលកឲ្យតម្លៃលើការអប់រំ ។

គំនិត ជនលក មានន័យផ្ទុយពីគំនិតរបស់រូស្សូដែលពន្យល់ថា ៖ ក្មេងកើតមកល្អរួចស្រេចតាមធម្មជាតិ ប៉ុន្តែសង្គមមនុស្សធ្វើឲ្យក្មេងពុករលួយ ។ ចំណែកឯ វ៉ុលតែរ ដែលគាំទ្រទស្សនៈរបស់ជនលក បានប្រឆាំងនឹងរូស្សូតាមទ្រឹស្តីថា ៖ « ក្មេងកើតមកមិនជាល្អមិនជាអាក្រក់អាស្រ័យលើការអប់រំ » ។

- ជនលក បានឲ្យតម្លៃលើ វិចារណ ដើម្បីតំរង់ទិសការពិសោធ ឲ្យប្រសើរ ព្រោះការពិសោធឯកឯងខ្វះវិចារណៈ អាចនាំឲ្យខាតបង់ ពេលវេលា និងអាចដឹកនាំទៅរកផ្លូវខុស ។
- ជនលក ប្រឆាំងនឹងទ្រឹស្តីអំពីខ្លីមដូចតូម៉ាហុប្បដែរ ។

+ តូម៉ាហុប្ស Thomas Hobbes ( ១៥៨៨ - ១៦៧៩ )



តូម៉ាហុប្ស ជាទស្សនវិទូអង់គ្លេស កើតមុនដេកាត ៨ឆ្នាំ ។ តូម៉ាហុប្ស រស់នៅជំនាន់ក្លាលីលេ គឺទាន់ការកាត់ទោសប្រហាជីវិតក្លាលីលេ ដោយគេយកទៅដុតទាំងរស់ ព្រោះក្លាលីលេបានរកឃើញផែនដីវិលផ្ទុយពីគម្ពីរសាសនាគ្រីស្ត ដែលអះអាងថា ផែនដីសំប៉ែតឥតវិលទេ ស្របគ្នានឹងយោបល់ពុទ្ធសាសនាដែរ ។

តូម៉ាហុប្ស បានសរសេរស្នាដៃមួយឈ្មោះ Léviathan ដែលនៅក្នុងនោះ គេអាចកត់សំគាល់ទ្រឹស្តីមួយឈ្មោះ Phomme est loup pour home មានន័យថា មនុស្សជាឆ្កែចចករបស់មនុស្ស ទ្រឹស្តីនេះមានទំនោរទៅរកទស្សនៈទុទិដ្ឋិនិយម អប់រំមិនឲ្យជឿមនុស្សទាំងអស់ ក្រៅពីខ្លួនឯង ។

## ទស្សនវិជ្ជារបស់តូម៉ាហុប្ស

- ហុប្សឲ្យតម្លៃលើឥន្ទ្រីយារម្មណ៍ ដែលហុប្សយល់ថាជាប្រភពនៃវិទ្យាសាស្ត្រ ។
- ហុប្សជាទស្សនវិទូ នាមនិយម ព្រោះហុប្សយល់ថាអ្វី ៗ ក្នុងធម្មជាតិគ្រាន់តែជាឈ្មោះ ឬជានាម ឬជាសញ្ញា ដែលមនុស្សកំណត់សំគាល់ប៉ុណ្ណោះ ហេតុនេះមិនត្រូវយកចិត្តទុកដាក់ថា ជាខ្លឹមឲ្យសោះ ។
- ហុប្ស ប្រឆាំងនឹងទ្រឹស្តីអំពីខ្លឹម ដោយអះអាងថា ក្នុងធម្មជាតិ គ្មានខ្លឹមទេ អ្វីទាំងអស់គ្រាន់តែជាឈ្មោះស្របគ្នានឹងទស្សនៈរបស់ព្រះពុទ្ធគោតមដែរ ព្រោះព្រះពុទ្ធគោតមអះអាងថា ភាវៈឥតមានខ្លឹមទេ អ្វីទាំងអស់គ្មានសារៈសំខាន់ឡើយ សុទ្ធសឹងប្រែប្រួលតាមច្បាប់ធម្មជាតិក្នុងទ្រឹស្តី « អនិច្ចំ ទុក្ខំ អនត្តា » ។
- បើ ហុប្ស មិនជឿថាមានខ្លឹម គឺមិនជឿថាមានព្រលឹងដែរ ហើយពុំជឿថាមនុស្សស្លាប់ទៅកើតវិញទេ ។ កំណើតរបស់សត្វលោកទាំងឡាយគឺជាជីវិតបន្ត ៗ គ្នា ស្របតាមទស្សនវិជ្ជាថ្មីមួយឈ្មោះថា ជីវិតនិយម ដែលលើកយកមកបង្ហាញ ដោយលោក Barthez ( 1734 - 1808 ) និង អធិប្បាយយ៉ាងក្បោះក្បាយដោយលោក ប៊ែរសុន ( Bergson 1859 - 1941 ) ។

ជីវិតនិយម ជាទ្រឹស្តីពន្យល់អំពីជីវិតសត្វលោកដែលមានភាពបន្តទៅទៀតបែបជាសរីរៈ ខ្លះព្រលឹងខ្លះ ឬជាការផ្សំរវាងធាតុ និងមនោ ។ ខ្លះយល់ថាជារូបរាងបុគ្គល ដែលធ្វើឲ្យគេនឹករលឹកឃើញ ខ្លះទៀតយល់ថាជាចិត្តគំនិត ឬ ព្រលឹងរបស់បុគ្គលនេះវិញទេដែលមានភាពបន្តទៅទៀត ។

- ទស្សនវិជ្ជាម្យ៉ាងទៀត របស់ហុប្សគឺអប់រំមនុស្សកុំឲ្យទុកចិត្តមនុស្សព្រោះគ្មានមនុស្សណាល្អទេ ។ មនុស្សស្លាប់ទៅឥតកើតវិញទេហេតុនេះ ពេលរស់នៅត្រូវតែឆ្លៀតឲ្យបានប្រសើរ ឲ្យបានទ្រព្យសម្បត្តិច្រើន ឲ្យបានសប្បាយច្រើន ព្រោះការសប្បាយមានតែម្តង មានតែពេលរស់នៅ ហើយបើយើងមិនចេះឆ្លៀតលើគេ គេមុខជាឆ្លៀតមកលើយើងវិញ ។

សីលធម៌របស់តូម៉ាហុប្ស :

- ត្រូវចេះសំរបសំរួលតាមធម្មជាតិ ប៉ុន្តែត្រូវឲ្យតម្លៃលើសកម្ម ។

ការរស់នៅតាមធម្មជាតិល្អប្រសើរគឺ លទ្ធិភាពប្រឆាំងនឹងគំនិតណា ដែលនាំឲ្យកើតឲ្យកើតវឹករវរ ។ ដើម្បីឲ្យបានសន្តិភាពពិតប្រាកដ មនុស្សត្រូវចុះកិច្ចព្រមព្រៀងរវាងគ្នានិងគ្នា ពោលគឺត្រូវមានកិច្ចសន្យាសង្គម ហើយគំនិតនេះបានត្រូវរូស្សូយកលំនាំតាមដើម្បីកែប្រែសង្គមបារាំង ឲ្យទទួលខុសត្រូវចំពោះមនុស្សទាំងអស់ ដែលរស់នៅក្នុងសង្គម ។

- បើចង់ធ្វើនយោបាយ ហុប្សបានពន្យល់ថា ត្រូវគិតយ៉ាងណាឲ្យបានល្បីឈ្មោះសិន ។
- បើច្បាប់សង្គមបានត្រឹមត្រូវហើយ មនុស្សត្រូវតែគោរពច្បាប់ ។
- សាសនា ជាមធ្យោបាយរបស់អ្នកធំ ដើម្បីកំហែងគំរាមអ្នកតូច អ្នកទន់ខ្សោយព្រមទាំងជាក្បួនបញ្ឆោតមនុស្សល្ងង់ ។ គំនិតនេះបានធ្វើឲ្យ ហុប្សជួបប្រទះសត្រូវជាច្រើន ពីសំណាក់ពួកទំនោរនិយមសាសនា ដែលមានចំណងតាមព្យាបាទ ។

+ ហ្សង់ប៉ុលសាត្រ Jean Paul Sartre




ហ្សង់ប៉ូលសាត្រ កើតនៅឆ្នាំ ១៩០៥ នាក្រុងប៉ារីស ហើយត្រូវជាកូនកំព្រាឪពុកតាំងពីកើតមក ។ លោកបានប្រឡងចូលសាលាគរុវិជ្ជាជាន់ខ្ពស់នៅឆ្នាំ ១៩២៥ ។

- នៅឆ្នាំ ១៩២៨ លោកប្រឡងជាប់លេខ ១ ផ្នែកមហាបរិញ្ញាប័ត្រទស្សនវិជ្ជា រួចហើយលោកចាប់បង្រៀននៅខេត្តរហូតដល់បានមកប្រៀននៅទីក្រុងប៉ារីស ។ ពេលនោះហើយដែលលោកចាប់ផ្តើមសរសេរសៀវភៅ ដូចជាសៀវភៅទី១ មានឈ្មោះថា « La Nausée » មានន័យថាកំអួតសង្គម ព្រមទាំងស្នាដៃផ្សេង ៗ ទៀត ដូចជា Les Mouches le Diable et le bon dieu ច្រើននិយាយរិះគន់សង្គម ហើយអប់រំបុគ្គលម្នាក់ ៗ ឲ្យយល់នូវតម្លៃខ្លួនឯង ទើបលោកចាប់ផ្តើមពិចារណាគំនិតមួយមានឈ្មោះថា Existence ដែលលោកឲ្យន័យថា ៖

existence = la situation de l’homme dans le monde ( ស្ថានរបស់មនុស្សក្នុងសកលលោក )

## ទស្សនវិជ្ជារបស់ហ្សង់ប៉ូលសាត្រ :

ចលនាគំនិតរបស់ហ្សងប៉ូលសាត្រ មានប្រភពមកពីប្រទេសជាតិឆ្លងកាត់សង្គ្រាមយ៉ាងសាហាវ បណ្តាលឲ្យជីវភាពប្រជាពលរដ្ឋវេទនាយ៉ាងសំបើម ចំណែកឯអ្នកមានគិតតែសន្សំទ្រព្យសម្បត្តិ ដោយឃោសនាឲ្យតម្លៃលើវិទ្យាសាស្ត្រ ឯមនុស្សមួយពួកទៀតវិលវល់ក្នុងទ្រឹស្តីវិចារណនិយម ដែលលោកប៉ែរស៊ុន បានប្រឆាំងរួចម្តងហើយ ទើបហ្សង់ប៉ូលសាត្រ ចាប់ផ្តើមពិចារណា ពីស្ថានភាពរបស់មនុស្ស ពោលគឺការរស់នៅរបស់មនុស្សបច្ចុប្បន្ន ដែលសាត្រឲ្យឈ្មោះ « existence » ហើយក៏ចាប់ផ្តើមបង្កើតប្រព័ន្ធទស្សនវិជ្ជាមួយមានឈ្មោះ Existenlialisme ដែលជាទ្រឹស្តីឲ្យតម្លៃ លើការរស់នៅបច្ចុប្បន្នរបស់មនុស្សក្នុងឋានៈជា មនុស្សបុថុជ្ជន ទាំងអស់នេះជាគំនិតមួយបិតនៅជុំវិញការរស់នៅរបស់មនុស្ស គិតយ៉ាងណាឲ្យបានរស់ កុំគិតឧត្តមគតិខ្លាំងពេក ទើបគេអាចប្រើពាក្យបាលីថា ភវៈ ឬ អត្ថិភាព ខ្មែរថា គិតយ៉ាងណាឲ្យបានរស់ ។

ដូច្នេះពាក្យ Exiatenlialisme អាចបកប្រែជាពាក្យបាលីថា ភវនិយម ឬ អត្ថិភាពនិយម ខ្មែរថា « រស់និយម » ។

ភវនិយម ឬរស់និយម ជាប្រព័ន្ធទស្សនវិជ្ជាមួយ ដែលចោទនិងដោះស្រាយជុំវិញបញ្ហារស់នៅរបស់មនុស្ស តើឲ្យមនុស្សរស់នៅរបៀបណា ? ធ្វើយ៉ាងណាដើម្បីរស់នៅបាន ? ត្រូវពឹងពាក់គេ ឬទេ ? តើត្រូវជឿថា ព្រះអាទិទេពអាចជួយយើងឲ្យរស់នៅបានដែរ ឬទេ ? សង្គមមនុស្សអាចធ្វើឲ្យដំណើរជីវិត របស់មនុស្សយើងបានប្រព្រឹត្តទៅសមរម្យ ឬទេ ? តើសាសនា អាចធ្វើឲ្យមនុស្សរស់បាន ឬទេសព្វថ្ងៃនេះ ? បើគ្មានសាសនា មនុស្សរស់បានឬទេសព្វថ្ងៃនេះ ?

ទាំងអស់នេះជាបុព្វហេតុធ្វើឲ្យ ហ្សង់ប៉ូលសាត្រ បង្កើតទ្រឹស្តីដូចទៅ ៖

- ការរស់នៅជាងខ្លឹម

តាមទ្រឹស្តីនេះ សាត្រពុំបដិសេធចោលខ្លឹមទាំងអស់ទេ គឺជឿថាមខ្លឹមដែរ គ្រាន់តែឲ្យតម្លៃលើការរស់នៅប្រសើរជាងខ្លឹម ។

តើមានន័យដូចម្តេច ?

នេះជាទស្សនៈមួយប្រឆាំងនឹងគំនិតណា ដែលឲ្យតម្លៃលើអ្វីដែលប្រសើរ អ្វីដែលខ្ពង់ខ្ពស់ អ្វីដែលល្អប្រហួស អ្វីដែលជាគ្រឿងតុបតែង ឥតប្រយោជន៍ អ្វីដែលជាគ្រឿងប្រើប្រាសហួសពីសេចក្តីត្រូវការរបស់មនុស្ស ។ ដោយហេតុតែមានគំនិតប្រឆាំងនឹងខ្លឹម ប្រឆាំងនឹងអ្វីដែលល្អប្រសើរ ទើបហ្សង់ប៉ូលសាត្រ ពុំព្រមទៅទទួលរង្វាន់ណូបែល អក្សរសិល្ប៍នៅឆ្នាំ ១៩៦៤ .។ មតិខ្លះយល់ថា បានជាហ្សង់ប៉ូលសាត្រពុំព្រមទៅទទួលរង្វាន់ណូបែល មកពីលោកពុំចូលចិត្តណូបែល

( ១៨៣៣ - ១៨៩៦ ) ដែលជាសេដ្ឋីមួយរូបសញ្ជាតិស៊ុយអែត មានសម្បត្តិស្តុកស្តម ដោយហេតុតែណូបែលចេះធ្វើគ្រឿងផ្ទុះលក់ បានចំណេញច្រើន ។ គំនិតនេះគ្រាន់តែជាសម្មតិកម្មប៉ុណ្ណោះ ។ តាមពិតជាការប្រឆាំងនឹងអ្វីដែលខ្ពង់ខ្ពស់ដែលផ្តាច់គេ ។ បើ ហ្សង់ប៉ូលសាត្រ ទៅទទួលរង្វាន់ណូបែល គឺមានន័យថា ហ្សង់ប៉ូលសាត្រ ទទួលស្គាល់លក្ខណៈល្អប្រសើរ លក្ខណៈខ្ពង់ខ្ពស់ដាច់គេ ផ្ទុយនឹងប្រព័ន្ធទស្សនវិជ្ជា របស់លោក ដែលជាប្រព័ន្ធទស្សនវិជ្ជាមួយឲ្យន័យលើអ្វីដែលមានតម្លៃត្រឹមតែរស់ ។ ហេតុនេះ មនុស្សត្រូវគិតយ៉ាងណាដោះស្រាយជីវភាព របស់ខ្លួនត្រឹមតែរស់បានហើយ កុំត្រូវការអ្វីហួសពីត្រឹមតែរស់ ដើម្បីចៀសវាងកុំឲ្យមានវិបត្តិក្នុងការរស់នៅ កុំឲ្យមានអយុត្តិធម៌ក្នុងសង្គម កុំឲ្យមនុស្សសាងសុភមង្គលលើគំនរទុក្ខអ្នកដទៃ ... ទាំងអស់នេះជាសេចក្តីត្រូវការរបស់មនុស្ស ប៉ុន្តែតាមការសង្កេតទៅ មនុស្សដែលបិតនៅក្នុងសភាវគតិនៅឡើយ ចូលចិត្តចង់មានបានហួសហេតុ ទោះបីទឹកភ្នែកអ្នកដទៃក្លាយជាឈាមក៏ដោយ ។ ដោយហេតុតែចង់ឲ្យការរស់នៅរបស់ខ្លួនបានប្រសើរ គេត្រូវបន្ទាបការរស់នៅរបស់អ្នកដទៃ ជាហេតុធ្វើឲ្យមនុស្សទន់ខ្សោយមើលឃើញជីវិតឥតន័យ រស់នៅសំរាប់តែបំរើគេ ។ ទស្សនៈ ទាំងអស់នេះ បិតនៅជុំវិញការរស់នៅរបស់មនុស្ស គឺការរស់នៅប្រឆាំងនិងភាពប្រសើរ ដែលគេឲ្យឈ្មោះថា ខ្លឹម ។ ដើម្បីឲ្យការរស់នៅប្រកបដោយសុខសន្តិភាព មនុស្សទាំងអស់មិនត្រូវប្រាថ្នាខ្លឹមទេ ត្រូវប្រាថ្នាអ្វីត្រឹមតែរស់នៅបានហើយ ។ បើប្រៀបធៀបមកទស្សនៈរស់និយមរបស់ខ្មែរ យើងអាចប្រដូចមកទ្រឹស្តីមួយរបស់ខ្មែរ « កកក៏បាយ មេម៉ាយក៏ស្រី កន្ទុយបារីក៏ថ្នាំ » មានន័យថាកុំប្រាថ្នាម្ហូបអាហារល្អពេក ឲ្យតែរស់បានហើយ ចំណែកឯប្រពន្ធវិញកុំប្រាថ្នាល្អពេក ឲ្យតែយល់ព្រមរស់នៅជាមួយ គឺជាគោលដៅរបស់មនុស្ស ។

- ការរស់នៅប្រឆាំងនិងវិទ្យាសាស្ត្រ ព្រោះវិទ្យាសាស្ត្រគ្រាន់តែជាមធ្យោបាយរបស់ពួកអ្នកមាន ដើម្បីប្រមូលទ្រព្យសម្បត្តិពីអ្នកក្រ ហើយធ្វើឲ្យអ្នកមានកាន់តែមានឡើង អ្នកក្រកាន់តែក្រទៅ ។

- ការរស់នៅប្រឆាំងនឹងសាសនា ប៉ុន្តែហ្សងប៉ូលសាត្រ សង្កត់លើសាសនាណាដែលជឿថាមានអាទិទេព និងអ្នកតំណាងអាទិទេព ។ អាទិទេពក្តី អ្នកតំណាងអាទិទេពក្តី សុទ្ធសឹងតែជាល្បិចបោកប្រាសមនុស្ស ហើយមិនគិតដល់ការរស់នៅរបស់មនុស្សទេ ហេតុនេះមនុស្សត្រូវពឹងលើសមត្ថភាពផ្ទាល់ខ្លួន កសាងសុភមង្គលខ្លួនឯង ដែលហ្សង់ប៉ូលសាត្រ និយមប្រើពាក្យថា « l'en-soi » ព្រោះ *គ្មាននរណាជួយខ្លួនឯងជាខ្លួនឯងទេ* ។

ក្នុងសៀវភៅមួយឈ្មោះ « les Mouckes » សាត្រសរសេរថា ill n'y a plus rien au ciel, ni bien ni mal, ni personne pour me donner des. Je suis homme, et chaque homme doit inventer son chemin …

ទស្សនខាងលើនេះមានលក្ខណៈស្របគ្នា និងពុទ្ធសាសនា ខ្លះ និងខុសខ្លះ ស្របគ្នាក្នុងករណីដែលអប់រំឲ្យពឹងខ្លួនឯង ប៉ុន្តែខុសគ្នាត្រង់ពុទ្ធសាសនា មាននិយាយអំពីពលិកម្មដោយសុខចិត្តពិបាកខ្លួនឯង ដើម្បីឲ្យអ្នកដទៃបានសុខ ចំណែកទ្រឹស្តីរបស់និយម របស់សាត្រអប់រំមិនឲ្យមានពលិកម្មទេ មនុស្សត្រូវកសាងខ្លួនឯងដើម្បីសេចក្តីសុខខ្លួនឯង គ្មានទេវតា ឬ អាទិទេពឯណាជួយយើងទេ ។ ចំណុចទ្រឹស្តីត្រង់នេះបានធ្វើឲ្យគេចោទប្រកាន់សាត្រថា ជាទស្សនវិទូ រស់និយមអទេវៈ ។

រួមសេចក្តីមក ទ្រឹស្តីរស់និយមរបស់សាត្របានទាក់ទងមួយផ្នែកទៅនឹងទ្រឹស្តីរបស់កាមុស ត្រង់កាមុស លើកយកជីវិតឥតន័យ មកបង្ហាញដោយបញ្ជាក់ថាជីវភាពរបស់មនុស្សហាក់ដូចជាមានដំណើរ ប្រព្រឹត្តទៅដដែល ៗ ពីព្រលឹមដល់យប់នៅដដែល ៗ ដូចជាបរិភោគពេលព្រឹក ពេលថ្ងៃត្រង់ ពេលល្ងាចតែប៉ុណ្ណឹង ហើយបើគិតឃើញថាជីវិតរបស់ខ្លួនមានតែប៉ុណ្ណោះ គួរធ្វើអត្តឃាតទៅប្រសើរជាង ។ អត្តឃាតកម្មប្រភេទនេះមានឈ្មោះថា អត្តឃាតកម្ម បែបទស្សនវិជ្ជា ។

សង្កេត ហេតុអ្វីបានជាសព្វថ្ងៃនេះខ្មែរបានភ្ញាក់ផ្អើល ភ្ញាក់រលឹក ចាប់អារម្មណ៍នឹងទ្រឹស្តីទស្សនវិជ្ជា របស់ហ្សង់ប៉ូលសាត្រ និង អាល់ប៊ែរកាមុស ខ្លាំងម្ល៉េះ ?

ទ្រឹស្តីរបស់ទស្សនវិទូ ទាំងពីរនេះមានកំណើតឡើងក្រោយសង្គ្រាមលោកលើកទី២ បណ្តាលឲ្យប្រជាពលរដ្ឋបារាំងជួបប្រទះការរស់នៅដ៏សែនវេទនា ។ ផលវិបាកនៃសង្គ្រាមបន្ទាបកំរិតជីវភាពរស់នៅរបស់មនុស្ស ទើបទ្រឹស្តី «រស់និយម» របស់ហ្សង់ប៉ូសាត្រ បានធ្វើឲ្យមតិភាគច្រើនទទួលស្គាល់ថាជាទ្រឹស្តីជួយដោះស្រាយទុក្ខសោកប្រកបដោយប្រសិទ្ធិភាពរបស់ពលរដ្ឋបារាំងនៅសម័យនោះ ព្រោះទ្រឹស្តី «រស់និយម» របស់សាត្រ អប់រំមនុស្សឲ្យគិតត្រឹមតែការរស់នៅបានហើយ កុំប្រាថ្នាជីវភាពខ្ពង់ខ្ពស់ ។

**+ អាល់ប៊ែរ កាមុស Albert Camus ( ១៩១៣ - ១៩៦០ )**



អាល់ប៊ែរ កាមុស ជាទស្សនវិទូបារាំង ប៉ុន្តែមានកំណើត នៅប្រទេសអាល់ហ្សេរីព្រោះឪពុកម្តាយជាប់បំពេញបេសកម្មនៅប្រទេសអាល់ហ្សេរី ។ កាមុស ជាកូនអ្នកក្រមួយរូបដែលអាចរៀនសូត្របានដោយសាតែរដ្ឋឲ្យអាហារូបករណ៍ ។ កំពុងរៀបចំប្រឡងមហាបរិញ្ញាប័ត្រផ្នែកទស្សនវិជ្ជា ស្រាប់តែកើតជម្ងឺរបេង កាមុសក៏វិលមកប្រកបរបរកសិុសរសេរកាសែតមួយឈ្មោះប្រយុទ្ធ ។

បន្ទាប់មក លោកក៏ចាប់ផ្តើមបញ្ចេញស្នាដៃរបស់លោកដូចមានស្នាដៃជាច្រើន ៖

- l’étranger ( ជនចំលែក ឬ ជនពុំចុះសំរុង នឹងជីវិត )
- le mythe de sisyphe
- la peste
- l’homme révolté
- le malentendu
- les justes

ស្នាដៃទាំងអស់នេះ ភាគច្រើននិយាយពីជីវិតឥតន័យ បង្កើតបានទស្សនវិជ្ជា មួយរបស់កាមុសឈ្មោះ ឥតន័យនិយម ។

## ទស្សនវិជ្ជារបស់ អាល់ប៊ែរ កាមុស :

គឺជាប្រព័ន្ធទស្សនវិជ្ជាមួយបែបដែលអធិប្បាយអំពី ជីវិតឥតន័យ អ្វីទាំងអស់សុទ្ធតែគ្មានន័យ ព្រោះមនុស្សចាញ់បោកសង្គមមនុស្ស បើបុគ្គលម្នាក់មិនឆ្លាតខំកសាងជីវភាពរបស់ខ្លួនទេបុគ្គលនោះនឹងត្រូវចាញ់បោកគេមិនខាន ។ តាមកាមុស មនុស្សចិត្តអាក្រក់ណាស់ គ្មានមនុស្សណាធ្វើល្អ ដោយសុទ្ធចិត្តចំពោះអ្នកដទៃទេ ។ អំពើល្អក្តី អំពើអាក្រក់ក្តី សុទ្ធសឹងជាមធ្យោបាយរបស់មនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ដើម្បីចំរាញ់យកផលគ្មានសីលធម៌ គ្មានការរាប់អានគ្នា គេឃើញតែម្នាក់ដើរខ្សែលើម្នាក់ ។ គំនិតនេះកើតមានឡើងក្រោយសង្គ្រាមលោកលើកទីពីរ ក្នុងបរិយាកាសមួយដែលសង្គមមនុស្សកំពុងកើតវិបត្តិដណ្តើមគ្នារស់របហូតចាប់ឆ្កែចាប់កណ្តុរជាអាហារ ។ សព្វថ្ងៃនេះ គេបានបញ្ចូលប្រព័ន្ធទស្សវិជ្ជា ឥតន័យនិយម ចូលក្នុងចលនារស់និយមរបស់លោក ហ្សង់ប៉ូលសាត្រ ដោយហេតុតែចលនាគំនិតទាំងពីរនេះ ប្រឆាំង និងការរស់នៅរបស់សង្គមពុំប្រកបដោយសីលធម៌ ។ ម្នាក់ ៗ ខំរកមធ្យោបាយបង្កើនទ្រព្យសម្បត្តិ ដោយកសាងសេចក្តីសុខលើគំនរទុកអ្នកដទៃ ហ្សង់ប៉ូលសាត្រប្រឆាំងនឹងសង្គមតាមទ្រឹស្តី « l’existence Précède l’essence » មានន័យថាការរស់នៅប្រសើរជាអ្វី ៗ ដែលខ្ពង់ខ្ពស់ ។ មនុស្សមិនត្រូវប្រាថ្នាអ្វីដែលខ្ពស់ពេកទេ ត្រូវគិតត្រឹមតែការរស់នៅរបស់ខ្លួនបានហើយ ព្រោះមហិច្ឆិតាអាចធ្វើឲ្យមនុស្សកសាងសេចក្តីសុខលើគំនរទុកអ្នកដទៃ ។ អាស្រ័យហេតុនេះហើយបានជាហ្សង់ប៉ូលសាត្រ ពុំទៅទទួលរង្វាន់ណូបែល ។

ទំនាក់ទំនងរវាង ហ្សង់ប៉ូលសាត្រ និងអាល់ប៊ែកាមុស ឋិតនៅត្រង់ហ្សង់ប៉ូលសាត្រ ចោទប្រកាន់ថា កាមុស ហាក់ដូចជាយល់បញ្ហាសង្គមតាមបែបចលនាទស្សនវិជ្ជា រស់និយម ដែរ ប៉ុន្តែអាល់ប៊ែរកាមុស បែរជាសរសេររឿងបុគ្គល ដោយយកបុគ្គលម្នាក់តំណាងសង្គម ហើយពុំបានលើកយកសង្គមតែម្តងមកបង្ហាញទេ ដូចជាករណីរឿង l’étranger ឬជនចំលែកម្នាក់ពុំចុះសំរុងនឹងជីវិត ព្រោះតែមិនបានយំសោកនៅពេលគេបញ្ចុះសពម្តាយ ។ នេះជារឿង បុគ្គលម្នាក់ ។ ហ្សង់ប៉ូលសាត្រ ចង់ឲ្យអាល់ប៊ែរកាមុស និយាយពីសង្គមធំ ៗ ដូចរឿងរបស់លោកឈ្មោះថា la Nausée មានន័យថា កំអួតសង្គម ។

រួមសេចក្តីមក ទោះបីមានទស្សនៈប្លែកគ្នាខ្លះរវាងទស្សនវិជ្ជា ឥតន័យនិយម និងទស្សនវិជ្ជារស់និយម ក៏ចលនា ទស្សនវិជ្ជាទាំងពីរនេះចោទ និងដោះស្រាយអំពីការរស់នៅដូចគ្នាពោលគឺ រស់នៅសំខាន់ជាងអ្វីទាំងអស់ ។ កាលណា គេចង់ពន្យល់ពីបញ្ហាជាតិមាតុភូមិ ឧត្តមគតិគោលគំនិតអ្វី ៗ ទាំងអស់ គេត្រូវគិតពីការរស់នៅច្បងគេ គឺបញ្ហាក្រពះ ចំណែកឯការដោះស្រាយប្លែកគ្នាឋិតនៅត្រង់ហ្សង់ប៉ូលសាត្រ អប់រំមនុស្សឲ្យប្រយុទ្ធតទៅទៀត ឯអាល់ប៊ែរកាមុស អប់រំមនុស្សឲ្យធ្វើអត្តឃាតកម្ម ។ អត្តឃាតកម្មនេះ ត្រូវមានឈ្មោះថា អត្តឃាតកម្មបែបទស្សនវិជ្ជា ។